# អភិធម្មត្ថសង្គហៈ

# បរិច្ឆេទទី ៧


រៀបរៀងដោយ

**ភិក្ខុ អគ្គធីរោ គង់ សុមិត្ត**


ព.ស. ២៥៥៥

ឈ្មោះសៀវភៅ **អភិធម្មត្ថសង្គហៈ បរិច្ឆេទទី ៧**

រៀបរៀងដោយ ភិក្ខុ **អគ្គធីរោ គង់ សុមិត្ត**

ផ្ទៀងផ្ទាត់ដោយ ភិក្ខុ ធម្មបាលោ សាន សប្បាយ

ភិក្ខុ វជិរប្បញ្ញោ គូ សុភាព

ភិក្ខុ ឆោម វិបុល

សាមណេរ ញ៉ិប យ័ន្ត

កាលបរិច្ឆេទ ព.ស. ២៥៥៥

ស្ថានទីធ្វើ ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន

"គល់ទទឹង" សង្កាត់ព្រែកថ្មី

ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ

# សម្ដែងព្រះអភិធម្ម នៅឋានតាវត្តិង្ស

កាលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ចាំព្រះវស្សាទី៧ នៅឋានតាវត្តិង្សទេវលោក ក្នុងគ្រាដែលបានសំដែងយមកបាដិហារ្យផ្ចាញ់ពួកតិរ្ថិយរួចហើយ បានគង់លើសិលាសនៈ ឈ្មោះបណ្ឌុកម្ពល ក្រោមដើមបារិឆត្ត ទ្រង់ព្រះសិរីសោភា ដូចព្រះអាទិត្យឧទ័យឡើងលើភ្នំយុគន្ធរ ដែលពួកនៃទេវតាទាំងឡាយក្នុងម៉ឺនចក្រវាឡបានមកប្រជុំគ្នា ហែហមសម្ដេចព្រះបរមសាស្ដាចារ្យ ទ្រង់ធ្វើសន្ទុសិតទេវបុត្រដែលធ្លាប់ជាពុទ្ធមាតា ឱ្យជាប្រធាននៃពួកទេវតាទាំងឡាយ ហើយត្រាស់កថាមគ្គព្រះអភិធម្មថា "**កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា**"ជាដើម ទ្រង់សម្ដែងដោយន័យនេះ ជាប់តរហូតអស់មួយព្រះវស្សា ដោយតេជៈនៃព្រះសព្វញ្ញុតញ្ញាណនោះ ។ ក៏កាលដែលទ្រង់សម្ដែងធម៌នោះ ក្នុងវេលាភិក្ខាចារទ្រង់និម្មិតព្រះពុទ្ធនិមិត្តដោយទ្រង់អធិដ្ឋានថា "ព្រះពុទ្ធនិមិត្ត

នេះ ចូរសម្ដែងធម៌ ឈ្មោះប៉ុណ្ណោះ ដរាបដល់តថាគតមក” ហើយក៏ស្ដេចយាងទៅព្រៃហេមពាន្ត ទ្រង់ទំពាឈើស្ទន់ ឈ្មោះនាគលតា ខ្ពុរព្រះឱស្ឋក្នុងស្រះអនោតត្ត នាំបិណ្ឌបាត អំពីឧត្តរកុរុទ្វីប បានធ្វើភត្តកិច្ចក្នុងរោងជំទូលាយហើយ ។ ព្រះសារីបុត្រទៅធ្វើវត្តចំពោះព្រះសាស្ដាក្នុងទីនោះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ជាទេវតារបស់ទេវតា ជាអ្នកនាំវិសេសអង្គនោះ កាលទ្រង់សំដែងអភិធម្មណា ដល់ទេវតាទាំងឡាយហើយ ក៏បានត្រាស់ប្រាប់ដល់ព្រះសារីបុត្តត្ថេរ អ្នកឧបដ្ឋាកព្រះមហេសីជាម្ចាស់ ក្នុងអនោតត្តស្រះ ដោយន័យ (សង្ខេប)ទៀតថា “ម្នាលសារីបុត្រ ថ្ងៃនេះតថាគតបានសម្ដែងធម៌ឈ្មោះប៉ុណ្ណោះ អ្នកចូរប្រាប់ដល់(ភិក្ខុ ៥០០) ជាកូនសិស្សរបស់អ្នក” ព្រះថេរៈបានស្ដាប់ហើយ ក៏បាននិមន្តមកកាន់លំនៅឋាន ហើយប្រាប់ដល់ភិក្ខុទាំងឡាយ, ព្រះអភិធម្មនោះ ដែលភិក្ខុទាំងឡាយបានទ្រទ្រង់ចាំទុកហើយ ដោយប្រការយ៉ាងនេះ ។

# ជីវប្រវត្តិសង្ខេប

ភិក្ខុ **គង់-សុមិត្ត** គង់នៅពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន គល់ទទឹង

ញោមប្រុស ឈ្មោះ គង់-តិក(ស្លាប់) ញោមស្រី ឈ្មោះ ហុក-តាង រស់នៅក្នុងភូមិវិត ឃុំព្រែកខ្ពប ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។

កើតនៅថ្ងៃព្រហស្បតិ៍ ៩ កើត ខែមិគសិរ ឆ្នាំ ថោះ ព.ស. ២៥១៩ - គ.ស. ១៩៧៦ ។ មានបងប្អូន ៧ នាក់ គឺ ប្រុស ៥ នាក់ ស្រី ២ នាក់. ជាកូនពៅ

ក្នុងកុមារ បានចូលរៀនសាលារដ្ឋ (ក្តាំងផា និងព្រែកហ្លួង)ដល់ថ្នាក់ទី ៨ ។

ក្នុងព.ស.២៥៣៧ មានអាយុ១៩ឆ្នាំ បួសជាសាមណេរ ក្នុងសំណាក់ឧបជ្ឈាយ៍ ព្រះនាម ឡុយ-លឿង វត្តស្លាកែត មកគង់នៅវត្តក្តាំងផា ខេត្តបាត់ដំបង ។

ព.ស. ២៥៣៨ មានអាយុគ្រប់ ២០ បានឧបសម្បទាជាភិក្ខុភាវៈ ។ ព.ស. ២៥៣៩ មកគង់នៅវត្តសមសាន្ត (ខេត្តបាត់ដំបង) រៀនវិន័យ-អភិធម្ម ។ ព.ស. ២៥៤០ មកនៅវត្តនិគ្រោធវន ខេត្តកណ្តាល រៀនធម៌វិន័យបន្ត ។ ព.ស. ២៥៤១ ចេញទៅគង់នៅវត្តខេមវន (ខេត្តកំចាម) បង្រៀនធម៌វិន័យ ។ ព.ស. ២៥៤៥ បានត្រឡប់មកវត្តនិគ្រោធវនវិញហើយលាសិក្ខា បានខិតខំ រៀបចំ និងជួយសរសេរសៀវភៅធម៌-វិន័យ ។ ព.ស. ២៥៤៦ បានបួសជាសាមណេរវិញទៀត ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ ព្រះនាម យី-ទិត វត្តកោះក្របី ឃុំព្រែកថ្មី ស្រុកគៀនស្វាយ ខេត្តកណ្តាល បានជួយបង្រៀនព្រះវិន័យដល់ព្រះសង្ឃ ក្នុងវត្តនិគ្រោធវន ។ ព.ស. ២៥៤៧ បានឧបសម្បទាជាភិក្ខុ បានបង្រៀនព្រះវិន័យដល់ព្រះសង្ឃ បង្រៀនអភិធម្មដល់ដូនជី ក្នុងវត្តនិគ្រោធវន និងខិតខំរៀបចំសៀវភៅធម៌-វិន័យរហូតមក ។

# អភិធម្មត្ថសង្គហកថា

គម្ពីរអភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ព្រះអនុរុទ្ធាចារ្យ បានចងក្រងឡើង ។

អភិធម្មត្ថសង្គហៈ មាន ៩ បរិច្ឆេទ គឺ

បរិច្ឆេទទី១ ចិត្តសង្គហវិភាគ ការសម្ដែងសង្គ្រោះនិងចែកចិត្ត ៨៩ ឬ១២១

បរិច្ឆេទទី២ ចេតសិកសង្គហវិភាគ ការសម្ដែងសង្គ្រោះនិងចែកចេតសិក ៥២

បរិច្ឆេទទី៣ បកិណ្ណកសង្គហៈ ការសម្ដែងសង្គ្រោះនិងចែកបកិណ្ណក ៦ ពួក

បរិច្ឆេទទី៤ វិថីសង្គហវិភាគ ការសម្ដែងសង្គ្រោះនិងចែកវិថីចិត្ត

បរិច្ឆេទទី៥ វិថីវិមុត្តសង្គហវិភាគ ការសម្ដែងសង្គ្រោះនិងចែកវិថីវិមុត្ត

បរិច្ឆេទទី៦ រូបសង្គហវិភាគ-និព្វានបរមត្ថ ការសម្ដែងសង្ខេបរូបនិងនិព្វាន
 និងចែករូបនិងនិព្វាន

បរិច្ឆេទទី៧ សមុច្ចយសង្គហវិភាគ ការសម្ដែងសង្គ្រោះនិង
 ចែកពួកធម៌ជាក្រុម ៗ

បរិច្ឆេទទី៨ បច្ចយសង្គហវិភាគ ការសម្ដែងសង្គ្រោះនិង
 ចែកបច្ច័យ១២ និង២៤

បរិច្ឆេទទី៩ កម្មដ្ឋានវិភាគ ការសម្ដែងចែកកម្មដ្ឋាន
 ៤០ និងវិបស្សនា ។

សៀវភៅអភិធម្មនេះ ព្រះអនុរុទ្ធាចារ្យបានប្រមូលចងក្រងអំពីបិដក និងអដ្ឋកថា ហើយបានចែកជាបរិច្ឆេទតាមប្រភេទនៃបរមត្ថធម៌ ដើម្បីងាយស្រួលក្នុងការសិក្សា គឺបរិច្ឆេទទី១ សម្ដែងចិត្តបរមត្ថ, បរិច្ឆេទទី២ សម្ដែងចេតសិកបរមត្ថ, បរិច្ឆេទទី៣, ៤, ៥ សម្ដែងចិត្តបរមត្ថ និងចេតសិកបរមត្ថរួមគ្នា, បរិច្ឆេទទី ៦ សម្ដែងរូបបរមត្ថ, និងនិព្វានបរមត្ថ, បរិច្ឆេទទី៧, ៨, ៩ សម្ដែងបរមត្ថទាំង ៤ រួមគ្នា ។

# បុព្វកថា

សៀវភៅអភិធម្មនេះ ខ្ញុំបានសរសេរក្នុងព.ស. ២៥៤៥ ចប់នៅក្នុងព.ស. ២៥៤៧ ។ ព.ស. ២៥៥២ បានរៀបចំជាសៀវភៅធំ ឈ្មោះថា អភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ។ ព.ស. ២៥៥៥ ដោយសេចក្តីត្រូវរបស់អ្នកសិក្សា ក៏បានចែកតាមបរិច្ឆេទនីមួយ ៗវិញ ដើម្បីងាយកាន់សិក្សា ។

ការរៀបចំសៀវភៅអភិធម្មត្ថសង្គហៈនេះ បានចប់សព្វគ្រប់ ហើយ បើមានពាក្យឬសេចក្តីណានៅខុស ក៏សូមអភ័យទោស និងសូមមេត្តាកែ សម្រួលផងចុះ ។

គម្ពីរព្រះអភិធម្ម ជាគម្ពីរដែលសម្តែងឡើងនូវធម៌ពិត គឺ សច្ចធម៌ បរមត្ថធម៌ និងបង្ហាញនូវផ្លូវបដិបត្តិឆ្ពោះទៅរកទីរំលត់ទុក្ខ គឺ ព្រះនិព្វាន ។ សត្វលោកដែលកើតមកសុទ្ធតែមានអវិជ្ជា និងតណ្ហាគ្រប់គ្នា មានតែព្រះពុទ្ធនិងព្រះបច្ចេកពុទ្ធទេ ដែលអាចត្រាស់ដឹងនូវធម៌ពិត កម្ចាត់អវិជ្ជាបានដោយខ្លួនព្រះអង្គឯង ក្រៅពីនោះ ត្រូវតែអាស្រ័យ

ព្រះពុទ្ធ ដែលទ្រង់មានព្រះទ័យមហាករុណាសម្តែងប្រាប់ ទើបអាចយល់ដឹងស្គាល់ធម៌ពិត និងបានឃើញផ្លូវបដិបត្តិដល់ព្រះនិព្វានជាទីរំលត់ទុក្ខបាន ។

កាលបើពុទ្ធបរិស័ទទាំងអស់ សិក្សានូវព្រះអភិធម្មបានយល់ដឹងហើយ បញ្ញាក៏កើតឡើង បានឃើញនូវសភាវធម៌ពិតទាំងដែលយើងសព្វថ្ងៃបានជួប បានទាន់ព្រះធម៌កំពុងឋិតនៅសម្រាប់ក្រេបជញ្ជក់ធម្មរស ហើយធ្វើឱ្យយើងមានសម្រស់ក្នុងជីវិត មិនឋិតនៅក្នុងភាពស្ងិតស្រពោន និងសម្រេចមគ្គផលតាមឧបនិស្ស័យដែលយើងបានសន្សំមក, ព្រោះហេតុដូច្នេះទើបខ្ញុំព្យាយាមរៀបចំសៀវភៅនេះឡើង ។ ម្យ៉ាងទៀត សៀវភៅនេះ ក៏ដូចជាសាវ័កមួយអង្គដែលឈ្លាសវៃនាំយកព្រះពុទ្ធដីកាមកប្រាប់ ហើយពន្យល់សេចក្តីនោះ ឱ្យយើងបានយល់ដឹងឬចាត់ថា ជាគ្រូក៏បាន ។

ការរៀបចំសៀវភៅធម៌នេះ ជាបុណ្យកុសលមួយ

យ៉ាងល្អប្រសើរ ដែលខ្ញុំព្រះករុណា អាត្មាភាព និងពុទ្ធបរិស័ទទាំងឡាយ បានរួបរួមសាមគ្គីជួយឧបត្ថម្ភ ដោយកម្លាំងកាយចិត្ត និងថវិកា ជាចេតនាមហាកុសលថ្នាក់ធម្មទាន និងធម្មបូជា យ៉ាងពេញចិត្តគ្រប់ ៗគ្នា ។ ដោយអំណាចនៃបុណ្យនេះ នឹងនាំឱ្យបានទទួលនូវសេចក្ដីសុខ ជាពិសេស គឺ បាននូវបញ្ញាដែលជាពន្លឺញ៉ាំងជីវិតឱ្យរុងរឿងគ្រប់ ៗ ជាតិ រហូតដល់បានលះបង់នូវមន្ទិលគឺ កិលេស ដែលយើងគ្រប់ ៗ គ្នាចង់បាននូវ ការត្រាស់ដឹងនូវសច្ចធម៌ ឃើញច្បាស់នូវព្រះនិព្វាន ដែលជាទីបំផុតទុក្ខ ។ ម្យ៉ាងទៀត បញ្ញានេះឯង អាចឱ្យសម្រេចតាមសេចក្ដីប្រាថ្នានោះបាន ។

ខ្ញុំព្រះករុណាអាត្មាភាព សូមអនុមោទនានូវបុណ្យកុសលរបស់ពុទ្ធបរិស័ទ ទាំងអស់ ដែលបានឧបត្ថម្ភថវិកាជាធម្មទាន និងការខិតខំសិក្សានេះ ។ ម្យ៉ាងទៀត សូមពុទ្ធ

បរិស័ទទាំងអស់ អនុមោទនាយកនូវបុណ្យដែលខ្ញុំព្រះករុណាអាត្មាភាព បានរៀបចំបោះពុម្ពព្រះអភិធម្មនេះផងចុះ ។ សូមឱ្យពុទ្ធបរិស័ទទាំងអស់ មានបញ្ញា ភ្លឺថ្លាមោះមុត ជាគ្រឿងត្រាស់ដឹងនូវសច្ចធម៌ សូមបានសម្រេចនូវសម្បត្តិលោកិយៈ និងលោកុត្តរៈ មានចិត្តល្អបរិសុទ្ធរួចផុតចាកទុក្ខដល់ព្រះនិព្វានគ្រប់ ៗ គ្នា កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអនុមោទនា !!!

ថ្ងៃ១៥កើត ខែស្រាព ឆ្នាំថោះ ត្រីស័ក ព.ស.២៥៥៥

# ឯកសារពិគ្រោះ

| អក្សរកាត់ | អក្សរពេញ | ភាគគម្ពីរ |
|---|---|---|
| សំយុ. និទា. | សំយុត្តនិកាយ និទានវគ្គ | បិដកភាគ ៣២ |
| អង្គុ. ចក្ក. | អង្គុត្តរនិកាយ ចតុក្កនិបាត | បិដកភាគ ៤២ |
| អង្គុ. ទស. | អង្គុត្តរនិកាយ ទសកនិបាត | បិដកភាគ ៥០ |
| អភិ. សង្គ. | អភិធម្ម ធម្មសង្គណី | បិដកភាគ ៧៨. ៧៩. |
| អភិ. វិភ. | អភិធម្ម វិភង្គ | បិដកភាគ ៨០. ៨១. ៨២. |

សម្មោហវិនោទនី អដ្ឋកថានៃអភិធម្ម វិភង្គ

អភិធានប្បទីបិកាសូចិ វិភាវិនីដីកា,

លេខដែលនៅបន្ទាប់គឺ ខាងដើមជាភាគគម្ពីរ កណ្តាលជាលេខឃ្នាប ខាងចុងជាលេខទំព័រ ឧទាហរណ៍ : ៥០. ១៣/៣៦ គឺ បិដកភាគ ៥០ លេខឃ្នាប ១៣ ទំព័រ ៣៦ ។

# បញ្ជីមាតិកា អភិធម្មត្ថសង្គហៈ

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**

*សម្ដេចព្រះអភិធម្ម នៅឋានតាវត្តិង្ស* … … … … … ក

*ជីវប្រវត្តិសង្ខេបគ* … … … … … … … … … … … … គ

*អភិធម្មត្ថសង្គហកថា* … … … … … … … … … … … ង

*បុព្វកថា* … … … … … … … … … … … … … … … … ឆ

*ឯកសារវិគ្រោះ* … … … … … … … … … … … … … ជ

*បញ្ជីមាតិកា* … … … … … … … … … … … … … … ឌ

**អភិធម្មត្ថសង្គហៈ បរិច្ឆេទទី ៧ សមុច្ចយសង្គហវិភាគ**

*សង្គហគាថាទី១* … … … … … … … … … … … … … ១

*សមុច្ចយសង្គហៈ មាន ៤ មាតិកា* … … … … … … … … ១

*អធិប្បាយ សមុច្ចយសង្គហៈ ៤* … … … … … … … … … ២

*១- អកុសលសង្គហៈ* … … … … … … … … … … … … ៤

*សង្គហគាថាទី២-៣* … … … … … … … … … … … … ៤

*អធិប្បាយ អកុសលសង្គហៈ មាន ៩ កង* … … ៥

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**


អធិប្បាយ អាសវៈ គ្រឿងត្រាំ ... ... ... ... ... ១០

អធិប្បាយ ឱឃកិលេសដូចអន្លង់ទឹក ... ... ... ១៤

អធិប្បាយ យោគកិលេស ... ... ... ... ... ... ១៥

អធិប្បាយ គន្ថៈ ... ... ... ... ... ... ... ... ... ... ១៥

អធិប្បាយ ឧបាទាន ... ... ... ... ... ... ... ... ១៧

អធិប្បាយ នីវរណៈ ៥ ... ... ... ... ... ... ... ១៨

អធិប្បាយ អនុស័យកិលេស ... ... ... ... ... ២២

អធិប្បាយ សញ្ញោជនៈ ... ... ... ... ... ... ... ២៥

អធិប្បាយ កិលេស ១០ ... ... ... ... ... ... ... ២៨

សំនួរ-ចម្លើយ ... ... ... ... ... ... ... ... ... ... ... ... ៣៥

ក្នុងអារម្មបទ ... ... ... ... ... ... ... ... ... ... ... ៣៥

អកុសលសង្គហៈ ... ... ... ... ... ... ... ... ... ៣៧

២- មិស្សកសង្គហៈ ... ... ... ... ... ... ... ... ... ... ៦១

សង្គហគាថាទី៤-៥ ... ... ... ... ... ... ... ... ... ... ... ៦៣

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ

អធិប្បាយ មិស្សកសង្គហៈ ៧ ... ... ... ... ... ... ៦៤
អធិប្បាយ អង្គឈាន ៧ ... ... ... ... ... ... ... ៦៤
អធិប្បាយ អង្គមគ្គ ១២ ... ... ... ... ... ... ... ៦៨
អធិប្បាយ ឥន្ទ្រិយ ២២ ... ... ... ... ... ... ... ៧៣
អធិប្បាយ ពលៈ ៩ ... ... ... ... ... ... ... ... ៨០
អធិប្បាយ អធិបតិ ៤ ... ... ... ... ... ... ... ៨២
អធិប្បាយ អាហារ ៤ ... ... ... ... ... ... ... ... ៨៥
មិស្សកៈ មានសភាវៈ ៥៣ ... ... ... ... ... ... ... ... ៩០
សង្គ្រោះធម៌ចូលក្នុងឋាន ៧ ... ... ... ... ... ... ... ៩២
សំនួរ-ចម្លើយក្នុងមិស្សកសង្គហៈ ... ... ... ... ... ... ៩៤
សម្តែងអង្គធម៌របស់អាហារ ៤ តាមលំដាប់ ... ... ៩៧
ពួកទី ៣ ពោធិបក្ខិយសង្គហៈ ... ... ... ... ... ... ... ... ១១៦
សង្គហគាថាទី៦-៧ សម្តែងសភាវធម៌ ... ... ... ... ១១៨
សង្គហគាថាទី៨-៩ សម្តែងឋានពោធិបក្ខិយៈ ... ... ១១៩

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**

អធិប្បាយ សតិប្បដ្ឋាន ៤ ... ... ... ... ... ... ១២០
អធិប្បាយ សម្មប្បធាន ៤ ... ... ... ... ... ... ១២២
អធិប្បាយ ឥទ្ធិបាទ ៤ ... ... ... ... ... ... ... ១២២
អធិប្បាយ ពោជ្ឈង្គៈ ៧ ... ... ... ... ... ... ... ១២៤
សំនួរ-ចម្លើយ ក្នុងពោធិបក្ខិយសង្គហៈ ... ... ... ... ១២៨
ពួកទី ៤ សព្វសង្គហៈ ... ... ... ... ... ... ... ... ... ១៥៣
សង្គហគាថាទី១០-១៤ ... ... ... ... ... ... ... ... ១៥៥
អធិប្បាយ ខន្ធ ៥ ... ... ... ... ... ... ... ... ... ១៥៧
អធិប្បាយ ឧបាទានក្ខន្ធ ... ... ... ... ... ... ... ១៦០
អធិប្បាយ អាយតនៈ ១២ ... ... ... ... ... ... ១៦២
អធិប្បាយ ធាតុ ១៨ ... ... ... ... ... ... ... ... ១៦៦
អធិប្បាយ អរិយសច្ចៈ ៤ ... ... ... ... ... ... ១៧២
សំនួរ-ចម្លើយក្នុងសព្វសង្គហៈ ... ... ... ... ... ... ... ១៨៥

# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ៧ សមុច្ចយសង្គហវិភាគ

*នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។*

### សង្គហគាថា

១ ទ្វាសត្តតិវិធា វុត្តា វត្ថុធម្មា សលក្ខណា

តេសន្ទានិ យថាយោគំ បវក្ខាមិ សមុច្ចយំ ។

*វត្ថុធម៌ ( សភាវធម៌ ) ព្រមទាំងលក្ខណៈ ៧២ យ៉ាង ខ្ញុំបានពោលទុកហើយ. ឥឡូវនេះ ខ្ញុំនឹងពោលសង្គហៈដែលឈ្មោះថា សមុច្ចយៈនៃវត្ថុធម៌ទាំង ៧២ នោះ តាមសមគួរដល់ការប្រកបតទៅ ។*

### សមុច្ចយសង្គហៈ មាន ៤ មាតិកា

*១-អកុសលសង្គហៈ ការសង្គ្រោះអកុសល មាន៩*

*២-មិស្សកសង្គហៈ ការសង្គ្រោះមិស្សកធម៌ មាន៧*

*៣-ពោធិបក្ខិយសង្គហៈ ការសង្គ្រោះពោធិបក្ខិយ*

ធម៌ មាន ៣៧

៤-សព្វសង្គហៈ ការសង្គ្រោះធម៌ទាំងពួង មាន៥ ។

## អធិប្បាយ សមុច្ចយសង្គហៈ ៤

__ក្នុងអភិធម្មវិភាវិនីដីកា__ អធិប្បាយថា ៖

វត្ថុធម៌ គឺ សភាវធម៌ ៧២ ប្រភេទ ព្រមទាំងលក្ខណៈ មានការគិតជាដើម ជាលក្ខណៈ ដែលលោកអាចារ្យបានពោលទុកហើយ ដោយអំណាចនៃចិត្ត ១ចេតសិក ៥២ និប្ផន្នរូប ១៨ និងនិព្វាន ១ ។ ឥឡូវនេះខ្ញុំនឹងពោលសមុច្ចយៈ គឺ កងនៃការរួបរួម ដែលផ្សេងដោយសង្គហៈ មានអកុសលជាដើម នៃសភាវធម៌ទាំងនោះ តាមដែលប្រកបជាមួយគ្នាបាន ដោយសមគួរដល់ការប្រកបដោយអំណាចនៃសមុច្ចយធម៌នីមួយ ៗ ។

**១អកុសលសង្គហៈ** មានវចនត្ថៈថា **អកុសលានមេវ សភាគធម្មវសេន សង្គហោ = អកុសលសង្គហោ** ប្រែថា សង្គហៈនៃអកុសលតែម្យ៉ាង ដោយអំណាចនៃសភាគធម៌

ឈ្មោះថា **អកុសលសង្គហៈ ។**

២មិស្សកសង្គហៈ *មានវចនត្ថៈថា* ***កុសលាទិវសេន មិស្សកានំ សង្គហោ = មិស្សកសង្គហោ*** *: សង្គហៈនៃធម៌ ដែលលាយគ្នា ដោយអំណាចនៃកុសលធម៌ជាដើម ឈ្មោះថា* ***មិស្សកសង្គហៈ ។***

៣ ពោធិបក្ខិយសង្គហៈ *មានវចនត្ថៈថា*

***សច្ចាភិសម្ពោធិសង្ខាតស្ស អរិយមគ្គស្ស បក្ខេ ភវានំ ពោធិបក្ខិយានំ ធម្មានំ សតិប្បដ្ឋានាទិភេទានំ សភាគត្ថវសេន សង្គហោ = ពោធិបក្ខិយសង្គហោ*** *ប្រែថា សង្គហៈនៃពោធិបក្ខិយធម៌ទាំងឡាយ ដែលនៅក្នុងផ្នែកនៃអរិយមគ្គ ពោលគឺការត្រាស់ដឹងសច្ចៈ ដោយអំណាចអត្ថមានចំណែកស្មើគ្នានៃធម៌ទាំងឡាយ ដែលផ្សេងដោយធម៌ មានសតិប្បដ្ឋានជាដើម ឈ្មោះថា* ***ពោធិបក្ខិយសង្គហៈ ។***

៤សព្វសង្គហៈ *មានវចនត្ថៈថា* ***ខន្ធាទិវសេន សព្វេ សង្គហោ = សព្វសង្គហោ*** *ប្រែថា សង្គហៈនៃធម៌ទាំងអស់ ដោយអំណាចនៃខន្ធជាដើម ឈ្មោះថា* ***សព្វសង្គហៈ ។***

# ១. អកុសលសង្គហៈ

## សង្គហគាថា

២. អាសវោឃា ច យោគា ច តយោ គន្ថា ច វត្ថុតោ
ឧបាទានា ទុវេ ធម្មា អដ្ឋ នីវរណា សិយុំ ។
៣. ឆឡេវានុសយា ហោន្តិ នវ សញ្ញោជនា មតា
កិលេសា ទសេតិ វុត្តោយំ នវធា បាបសង្គហោ ។

*បាបសង្គហៈ (គឺ អកុសលសង្គហៈ) នេះ លោកពោលទុក ដោយសភាវៈ ៩ កង គឺ អាសវៈ ឱឃៈ យោគៈ និងគន្ថៈ នីមួយ ៗ មាន ៣. ឧបាទាន លោកពោលទុក ២ យ៉ាង. នីវរណៈមាន ៨ យ៉ាង. អនុស័យ មានត្រឹមតែ ៦ យ៉ាង. សញ្ញោជនៈ ពោលទុក ៩ យ៉ាង. កិលេសពោលទុក ១០ យ៉ាង ។*

## អធិប្បាយ អកុសលសង្គហៈ មាន ៩ កង

**១-អាសវៈ** កិលេសជាគ្រឿងដេកត្រាំនៅក្នុងសន្តាន មាន ៤ គឺ ៖

**១ កាមាសវៈ** គ្រឿងដេកត្រាំ គឺ កាម

**២ ភវាសវៈ** គ្រឿងដេកត្រាំ គឺ ភព

**៣ ទិដ្ឋាសវៈ** គ្រឿងដេកត្រាំ គឺ ទិដ្ឋិ

**៤ អវិជ្ជាសវៈ** គ្រឿងដេកត្រាំ គឺ អវិជ្ជា

**២-ឱឃៈ** កិលេសដូចអន្លង់ទឹក មាន ៤ គឺ ៖

**១ កាមោឃៈ** អន្លង់ គឺ កាម

**២ ភវោឃៈ** អន្លង់ គឺ ភព

**៣ ទិដ្ឋោឃៈ** អន្លង់ គឺ ទិដ្ឋិ

**៤ អវិជ្ជោឃៈ** អន្លង់ គឺ អវិជ្ជា[១]

---

១. អាសវៈ ឱឃៈ យោគៈ មានក្នុងធម្មសង្គណី ភាគ ៧៩ ទំព័រ ២៦៧ និង ២៧៥ ។

៣- **យោគៈ**[១] កិលេសប្រកបសត្វទុកក្នុងវដ្ដ មាន៤ គឺ

**១ កាមយោគៈ** គ្រឿងប្រកប គឺ កាម

**២ ភវយោគៈ** គ្រឿងប្រកប គឺ ភព

**៣ ទិដ្ឋិយោគៈ** គ្រឿងប្រកប គឺ ទិដ្ឋិ

**៤ អវិជ្ជាយោគៈ** គ្រឿងប្រកប គឺ អវិជ្ជា

៤- **គន្ថៈ** កិលេសចងសត្វ មាន ៤ គឺ ៖

**១ អភិជ្ឈាកាយគន្ថៈ** គ្រឿងចងកាយ គឺ អភិជ្ឈា

**២ ព្យាបាទកាយគន្ថៈ** គ្រឿងចងកាយ គឺ ព្យាបាទ

**៣ សីលព្វតបរាមាសកាយគន្ថៈ** គ្រឿងចងកាយ គឺ សីលព្វតបរាមាសៈ

**៤ ឥទំសច្ចាភិនិវេសកាយគន្ថៈ** គ្រឿងចងកាយ គឺ សេចក្ដីប្រកាន់មាំថា វត្ថុនេះពិត ។

---

១. មានក្នុងអង្គុត្តរនិកាយ-ចតុក្កនិបាត យោគសូត្រ ៤២/២៣ ។

៥- **ឧបាទាន** គ្រឿងប្រកាន់មាំ មាន ៤ គឺ ៖

**១ កាមុបាទាន** គ្រឿងប្រកាន់មាំក្នុងកាម

**២ ទិដ្ឋុបាទាន** គ្រឿងប្រកាន់មាំក្នុងទិដ្ឋិ

**៣ សីលព្វតុបាទាន** គ្រឿងប្រកាន់មាំក្នុងសីលនិងវត្ត

**៤.អត្តវាទុបាទាន** គ្រឿងប្រកាន់មាំក្នុងវាទថា ខ្លួន

៦- **នីវរណៈ** គ្រឿងរាំងអំពើល្អ មាន ៦ យ៉ាង គឺ

**១ កាមច្ឆន្ទៈ** សេចក្តីពេញចិត្តក្នុងកាម

**២ ព្យាបាទៈ** សេចក្តីបៀតបៀនប្រទូសរ៉ាយ

**៣ ថីនមិទ្ធៈ** សេចក្តីងោកងក់ រួញរា

**៤ ឧទ្ធច្ចកុក្កុច្ចៈ** សេចក្តីរវើរវាយ ក្តៅក្រហាយចិត្ត

**៥ វិចិកិច្ឆា** សេចក្តីសង្ស័យ

**៦ អវិជ្ជា** សេចក្តីមិនដឹង

៧- **អនុសយ** កិលេសដេកសម្ងំក្នុងសន្ដាន មាន៧ គឺ

**១ កាមរាគានុសយ** អនុស័យ គឺ កាមរាគៈ

**២ ភវរាគានុសយ** អនុស័យ គឺ ភវរាគៈ

**៣ បដិឃានុសយ** អនុស័យ គឺ បដិឃៈ

**៤ មានានុសយ** អនុស័យ គឺ មានះ

**៥ ទិដ្ឋានុសយ** អនុស័យ គឺ ទិដ្ឋិ

**៦ វិចិកិច្ឆានុសយ** អនុស័យ គឺ ការសង្ស័យ

**៧ អវិជ្ជានុសយ** អនុស័យ គឺ អវិជ្ជា ។

៨- **សញ្ញោជនៈ** ១០ មាន ២ ន័យ គឺ ៖

**សុត្តន្តន័យ**[១] មាន ១០ : ១.សក្កាយទិដ្ឋិ ២.វិចិកិច្ឆា ៣.សីលព្វតបរាមាសៈ ៤.កាមឆន្ទៈ ៥.ព្យាបាទៈ ៦.រូបរាគៈ ៧.អរូបរាគៈ ៨.មានៈ ៩.ឧទ្ធច្ចៈ ១០.អវិជ្ជា

**អភិធម្មន័យ**[២] មាន ១០ : ១.កាមរាគៈ ២.បដិឃៈ

---

១. អង្គុ. ទស. នាថករណវគ្គ. ៥០. ១៣/៣៦ ។ ២. អភិ. វិភ. ខុទ្ទកវត្ថុវិភង្គ. ៨២. ២៦៣/២៦១ ។

៣.មានះ ៤.ទិដ្ឋិ ៥.វិចិកិច្ឆា ៦.សីលព្វតបរាមាសៈ ៧.ភវរាគៈ ៨.ឥស្សា ៩.មច្ឆរិយៈ ១០.អវិជ្ជា

៩- **កិលេស** គ្រឿងសៅហ្មង មាន ១០ គឺ ៖

១ លោភកិលេស គ្រឿងសៅហ្មង គឺ លោភៈ

២ ទោសកិលេស គ្រឿងសៅហ្មង គឺ ទោសៈ

៣ មោហកិលេស គ្រឿងសៅហ្មង គឺ មោហៈ

៤ មានកិលេស គ្រឿងសៅហ្មង គឺ មានះ

៥ ទិដ្ឋិកិលេស គ្រឿងសៅហ្មង គឺ ទិដ្ឋិ

៦ វិចិកិច្ឆាកិលេស គ្រឿងសៅហ្មង គឺ វិចិកិច្ឆា

៧ ថីនកិលេស គ្រឿងសៅហ្មង គឺ ថីនៈ

៨ ឧទ្ធច្ចកិលេស គ្រឿងសៅហ្មង គឺ ឧទ្ធច្ចៈ

៩ អហិរិកកិលេស គ្រឿងសៅហ្មង គឺ អហិរិកៈ

១០ អនោត្តប្បកិលេស គ្រឿងសៅហ្មង គឺ អនោត្តប្បៈ

បណ្តាអកុសលធម៌ ៩ កង មានអាសវៈជាដើម,

តណ្ហាដែលមានកាមភពនោះ ជាអារម្មណ៍ បណ្ឌិតប្រាជ្ញាយក ដោយឈ្មោះថា កាមភព នៅក្នុងអកុសលសង្គហៈនេះ ។ ទិដ្ឋិគតៈដែលប្រព្រឹត្តទៅហើយយ៉ាងនោះ លោកហៅថា **សីលព្វតបរាមាសៈ ឥទំសច្ចាភិនិវេសៈ និងអត្តវាទុបាទាន ។**

## អធិប្បាយអាសវៈ គ្រឿងត្រាំ

**អាសវ** មានវចនត្ថៈថា **បុព្វកោដិយា អបញ្ញាយនតោ ចិរបារិវាសិយត្ថេន វណតោ វា វិសន្ទមានបូតិយា វិយ ចក្ខាទិតោ វិសយេសុ វិសន្ទនតោ អាសវា :** ឈ្មោះថា អាសវៈ ដោយអត្ថថា ត្រាំនៅយូរ ព្រោះមិនប្រាកដខាងដើម ឬព្រោះហូរចេញពីទ្វារ ៦ មានចក្ខុទ្វារជាដើម ទៅក្នុងអារម្មណ៍ទាំងឡាយ ដូចជារបស់ស្អុយហូរចេញពីមុខដំបៅ ដូច្នោះ ។

ម្យ៉ាងទៀតថា **ភវតោ អា ភវគ្គំ ធម្មតោ អា គោត្រភុំ សវន្តិ បវត្តន្តីតិ អាសវា :** ធម៌ពួកណា រមែងហូរ

គឺ ប្រព្រឹត្តទៅ បើពោលអំពីភពដល់ភវគ្គ ព្រហ្មជាកំណត់ បើពោលអំពីធម៌ដល់គោត្រភូជាកំណត់ ព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា **អាសវៈ** ។

ពិតមែន ពួកធម៌មានលោភៈជាដើមនោះ រមែងប្រព្រឹត្តទៅក្នុងភវគ្គព្រហ្ម ដែលមានទីកើតឡើងផង និងជាអារម្មណ៍ផង និងក្នុងគោត្រភូដែលជាអារម្មណ៍ ក៏យ៉ាងនេះឯង ។

បណ្ឌិតគប្បីសន្និដ្ឋានថា "កាលធម៌ដទៃ គឺ មានៈ វិចិកិច្ឆា និងឧទ្ធច្ចៈជាដើមមាន, ធម៌ គឺ មានៈជាដើមទាំងនេះឯង ក៏មិនត្រូវជំទាស់ ដោយសភាពជាអាសវៈ ព្រោះជាធម៌ជ្រួតជ្រាប ផ្សព្វផ្សាយចូលទៅ ។ ដោយអំណាចការប្រកាន់ថា ជាអត្តា ជារបស់ជាប់ដោយអត្តា ព្រោះជាគ្រឿងត្រាំដោយអត្តថា ធ្វើឱ្យស្រវឹង" ។

## ១- កាមាសវ

**កាមាសវៈ** មានវចនត្ថៈថា **កាមេតីតិ = កាមោ :** ធម្មជាតិណា រមែងចង់បាន ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា កាម បានដល់ កាមតណ្ហា ។ អាសវៈ គឺ កាម ឈ្មោះថា កាមាសវៈ បានដល់ កាមរាគៈ ។

## ២- ភវាសវ

**ភវាសវ** មានវចនត្ថៈថា **រូបារូបភវេសុ ឆន្ទរាគោ ភវាសវោ :** សេចក្តីតម្រេក ដោយអំណាចសេចក្តីពេញចិត្តក្នុងរូបភព និងអរូបភព ឈ្មោះថា ភវាសវៈ បានដល់ ការជាប់ចិត្តនៅក្នុងឈាន ។

រាគៈសហគតដោយសស្សតទិដ្ឋិនោះ លោកសង្គ្រោះចូលក្នុងភវាសវៈ នេះដូចគ្នា ។

រាគៈ ៣ ប្រភេទ គឺ

១.កាមរាគៈ ២.ឆន្ទរាគៈ ៣.សស្សតទិដ្ឋិសហគតរាគៈ,

ភវៈទី ១ ប្រព្រឹត្តទៅនៅក្នុងឧប្បត្តិភពទាំងឡាយ,
ភវៈទី ២ ប្រព្រឹត្តទៅនៅក្នុងកម្មភព,
ភវៈទី ៣ សហគតដោយភវទិដ្ឋិ ។

កាលរួមកាមភវៈ និងភវាសវៈ ចូលគ្នា ហៅថា តណ្ហា ទើបមានអង្គធម៌ តែ ៣ ប៉ុណ្ណោះ ។

## ៣- ទិដ្ឋាសវៈ

ទិដ្ឋិ ៦២ ឈ្មោះថា **ទិដ្ឋាសវៈ** ។

## ៤-អវិជ្ជាសវៈ

ការមិនដឹងនូវឋាន ៨ គឺ ក្នុងសច្ចៈ ៤ មានទុក្ខសច្ចៈជាដើម, ក្នុងខន្ធ អាយតនៈ និងធាតុ ដែលជាចំណែកខាងដើម ១ មិនដឹងធម៌នោះ នៅក្នុងចំណែកខាងចុង ១ មិនដឹងទាំងក្នុងចំណែកខាងដើម និងក្នុងចំណែកខាងចុង ១ មិនដឹងក្នុងបដិច្ចសមុប្បាទ ១ ឈ្មោះថា **អវិជ្ជាសវៈ** ។

## អធិប្បាយ ឱឃកិលេសដូចអន្លង់ទឹក

**ឱឃៈ** មានវចនត្ថៈថា ៖

**ឱត្ថរិត្វា ហរណតោ ឱហននតោ វា ហេដ្ឋា កត្វា ហរណតោ ឱសីទាបនតោ ឱឃោតិ វុច្ចតិ ជលប្បវាហោ :** អន្លង់ទឹក លោកហៅថា ឱឃៈ ព្រោះគ្របសង្កត់នូវសត្វ និងសង្ខារ ហើយផាត់នាំទៅ ឬព្រោះឱ្យលិចចុះ គឺ ធ្វើឱ្យលិចចុះក្រោម ហើយបន្សាត់ទៅ បានដល់ ការធ្វើឱ្យលិចចុះ ។

ពួកធម៌មានលោភៈជាដើមនេះ គ្របសង្កត់នូវសត្វទាំងឡាយ ហើយនាំទៅ គឺ ដូចជាធ្វើឱ្យសត្វទាំងឡាយ លិចចុះក្នុងវដ្តៈ ព្រោះដូច្នោះ ពួកធម៌មានលោភៈជាដើមនោះ ទើបឈ្មោះថា **ឱឃៈ** ព្រោះដូចនឹងអន្លង់ទឹក ។ ក្នុងឱឃនិទ្ទេសនេះ អាសវៈប៉ុណ្ណោះ លោកហៅថា ឱឃៈ ព្រោះមានអត្ថដូចដែលពោលមកហើយ ។

## អធិប្បាយ យោគកិលេស

**យោគៈ** មានវចនត្ថៈថា ៖

**វដ្ដស្មឹ ភវយន្តកេ វា សត្តេ កម្មវិបាកេន ភវន្តរាទីហិ ទុក្ខេន វា សត្តំ យោជេន្តីតិ យោគា យោជ្ជាវុត្តធម្មា :** អាសវធម៌ ៤ ដូចដែលពោលហើយ ក្នុងកាលមុននុ៎ះឯង ឈ្មោះថា យោគៈ ព្រោះអត្ថថា ប្រកបសត្វទុកក្នុងវដ្ដៈ ឬក្នុងយន្ត (ម៉ាស៊ីនគ្រឿងវិលទៅ) គឺ ភពជាប់ជានិច្ច ដោយវិបាកនៃកម្ម ឬប្រកបទុកដោយភពដទៃ (មានភព៣ កំណើត ៤ និងគតិ៥)ជាដើម ឬប្រកបសត្វទុកជាមួយនឹងទុក្ខ ។

## អធិប្បាយ គន្ថៈ

**គន្ថៈ** មានវចនត្ថៈថា ៖

**នាមកាយេន រូបកាយំ បច្ចុប្បន្នកាយេន វា អនាគាមិកាយំ គន្ថេន្តិ ទុប្បមុញ្ចំ វេឋេន្តីតិ = កាយគន្ថា :**

ធម៌ពួកណា រមែងចងរូបកាយទុកជាមួយនាមកាយ ឬចងកាយដែលមិនទាន់មកដល់ទុកជាមួយកាយបច្ចុប្បន្ន គឺរមែងទាក់រួបរឹតទុកធ្វើឱ្យស្រាយចេញបានលំបាក ព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា **កាយគន្ថៈ ។**

***គោសីលាទិនា សីលេន វតេន តទុភយេន ច សុទ្ធីតិ ឯវំ បរតោ អសភាវតោ អាមសនំ បរាមាសោ*** : ការប្រកាន់ដោយប្រការដទៃ គឺ ប្រកាន់ខុសយ៉ាងនេះថា "សេចក្ដីបរិសុទ្ធិ(នៃសង្សារ)បាន ដោយសីល និងវត្ត, មានសីល និងវត្ត ដូចសត្វគោជាដើម និងដោយការប្រកាន់ទាំងពីរយ៉ាងនោះ" ឈ្មោះថា **បរាមាសៈ ។**

***ឥទមេវ សច្ចំ មោឃមញ្ញន្តិ អភិនិវិសនំ ទឡ្ហគ្គាហោ ឥទំ សច្ចាភិនិវេសោ*** : ការប្រកាន់មាំ គឺ ការប្រកាន់មាំថា "វត្ថុនេះប៉ុណ្ណោះពិត វត្ថុដទៃទទេ (មិនពិត)" ឈ្មោះថា ***ឥទំសច្ចាភិនិវេសៈ ។***

## អធិប្បាយ ឧបាទាន

**ឧបាទាន** មានវចនត្ថៈថា **មណ្ឌូកំ បន្នគោ វិយ ភុសំ ទឡ្ហំ អារម្មណំ អាទិយន្តីតិ = ឧបាទានានិ** : ធម៌ពួកណា រមែងប្រកាន់អារម្មណ៍យ៉ាងខ្ជាំងមុតមាំ ដូចពស់រឹតកង្កែប ព្រោះហេតុនោះ ធម៌ពួកនោះ ទើបឈ្មោះថា **ឧបាទាន** ។ សេចក្តីប្រកាន់មាំ គឺ កាមឈ្មោះថា **កាមុបាទាន** ។

ម្យ៉ាងទៀត ឈ្មោះថា **កាមុបាទាន** ព្រោះអត្ថថា ប្រកាន់មាំនូវកាមទាំងឡាយ បានដល់ លោភចេតសិកដែលកើតនៅក្នុងលោភមូលចិត្ត ៨ ។

**ឥមិនា មេ សីលវតាទិនា សំសារសុទ្ធីតិ ឯវំ សីលវតាទីនំ គហណំ សីលព្វតុបាទានំ** : ការប្រកាន់នូវសីល និងវត្ត ដោយគិតយ៉ាងនេះថា "សេចក្តីបរិសុទ្ធិ(រួច) ចាកពីសង្សាររបស់យើង នឹងមានដោយសីល និងវត្តជាដើមនេះ" ឈ្មោះថា **សីលព្វតុបាទាន** បានដល់ ទិដ្ឋិចេតសិកក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ (វៀរទិដ្ឋិដែលជាសីលព្វតបរាមាស

និងអត្តវាទទិដ្ឋិ ) ។

**វទន្តិ ឯតេនាតិ = វាទោ** ដែលឈ្មោះថា វាទៈ ព្រោះអត្ថថា ជាហេតុពោល ។

សភាវៈដែលជាហេតុពោលថា អត្តា, ពួកអន្យតិត្ថិយ បានកំណត់ទុក ២០ យ៉ាង ដោយអត្តាដែលបែងចេញពីខន្ធមាន ១០ និងមិនបែកចេញពីខន្ធ មាន ១០ ឈ្មោះថា **អត្តវាទ** ។ អត្តវាទៈនោះឯង ជាឧបាទាន ព្រោះដូច្នោះ ទើបឈ្មោះថា អត្តវាទុបាទាន បានដល់ ទិដ្ឋិចេតសិក នៅក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ។

## អធិប្បាយ នីវរណៈ ៥

**នីវរណៈ** មានវចនត្ថៈថា : **ឈានាទិវសេន ឧប្បជ្ជនកំ កុសលចិត្តំ និសេធេន្តិ តថា តស្ស ឧប្បជ្ជិតុំ ន ទេន្តីតិ = នីវរណា** : ធម៌ពួកណា រមែងហាមកុសលចិត្ត ដែលកើត

ឡើងដោយអំណាចនៃឈានជាដើម គឺ រមែងមិនឱ្យកុសលចិត្តនោះ កើតឡើងដោយអាការយ៉ាងនោះ ព្រោះហេតុនោះ ធម៌ពួកនោះ ឈ្មោះថា **នីវរណៈ ។**

ម្យ៉ាងទៀត ឈ្មោះថា នីវរណៈ ព្រោះអត្ថថា បិទបាំងនូវបញ្ញាចក្ខុ ។

កាម ពោលគឺ សេចក្តីតម្រេកដែលចងព័ន្ធទុក ក្នុងកាមគុណ ៥ នុ៎ះឯង ជាឆន្ទៈ ព្រោះអត្ថថា ពេញចិត្ត ព្រោះហេតុនោះ ទើបឈ្មោះថា **កាមឆន្ទៈ ។** កាមឆន្ទៈនុ៎ះឯង ជានីវរណៈ ព្រោះហេតុនោះ ទើបឈ្មោះថា **កាមឆន្ទនីវរណៈ** បានដល់ លោភចេតសិកនៅក្នុងលោភមូលចិត្ត ៨ ។

**ព្យាបជ្ជតិ វិនស្សតិ ឯតេន ចិត្តន្តិ = ព្យាបាទោ :** ចិត្តរមែងក្តៅក្រហាយ គឺ រមែងវិនាសដោយសភាវៈនេះ ព្រោះហេតុនោះ សភាវៈនោះ ឈ្មោះថា **ព្យាបាទៈ**, បានដល់ទោសៈ ៩ យ៉ាង ដោយមានអាឃាតវត្ថុផ្សេង ៗ ដែល

ប្រព្រឹត្តទៅដោយន័យជាដើមថា "គេបានប្រព្រឹត្តធ្វើវត្ថុដែលមិនជាប្រយោជន៍ដល់យើង" ជាហេតុឱ្យកើតឡើង ឬទោសៈ ១០ យ៉ាង រួមជាមួយនឹងសេចក្តីក្រោធ ដែលមិនមែនជាឋានៈ ។ ព្យាបាទនោះឯង ជានីវរណៈ ព្រោះហេតុនោះ ទើបឈ្មោះថា **ព្យាបាទនីវរណៈ** បានដល់ ទោសចេតសិក នៅក្នុងទោសមូលចិត្ត ២ ។

នីវរណៈ គឺ ថីនៈ មិទ្ធៈ ឈ្មោះថា **ថីនមិទ្ធនីវរណៈ** ។

នីវរណៈ គឺ ឧទ្ធច្ចៈ កុក្កុច្ចៈ ឈ្មោះថា **ឧទ្ធច្ចកុក្កុច្ចនីវរណៈ** ។

សួរថា "ធម៌ដែលមានសេចក្តីផ្សេងគ្នា គឺ ថីនៈ ជាមួយនឹងមិទ្ធៈ, ឧទ្ធច្ចៈជាមួយនឹងកុក្កុច្ចៈ នីវរណៈទាំងនេះនីមួយ ៗមានធម៌ ២ យ៉ាង, ព្រោះហេតុអ្វី បានជាព្រះមានព្រះភាគទ្រង់ត្រាស់ទុក ដោយរួមជានីវរណៈមួយយ៉ាង ៗ វិញហ្ន៎ ?" ។

ឆ្លើយថា "ព្រោះធម៌ទាំងនេះ មានកិច្ច មានអាហារ

និង ជាធម៌ដែលមានបដិបក្ខ ដូចគ្នា" ។

ពិតមែន ថីនៈ និងមិទ្ធៈ មានការធ្វើចិត្តឲ្យរួញរា ជាកិច្ចដូចគ្នា, ឧទ្ធច្ចៈ និងកុក្កុច្ចៈ មានការធ្វើមិនឱ្យចិត្តស្ងប់ ជាកិច្ចដូចគ្នា ។

មួយទៀត ធម៌ ២ ខាងដើម មានភាពខ្ជិលច្រអូស និងរមួលកាយ( ខ្ជិល ) ជាអាហារ គឺ ជាហេតុ, ធម៌ ២ ខាងក្រោយ មានការនឹករឭកដល់សេចក្ដីវិនាសញាតិជាដើម ជាអាហារ ។

មួយទៀត វីរិយៈ ជាបដិបក្ខដល់ធម៌ ២ ខាងដើម, សមថៈ ជាបដិបក្ខ ដល់ធម៌ ២ យ៉ាង ខាងក្រោយ ព្រោះហេតុនោះ ទើបព្រះបូរាណាចារ្យពោលថា ៖

បណ្ដានីវរណៈទាំងនេះ ឧទ្ធច្ចៈ កុក្កុច្ចៈ និងថីនៈ
មិទ្ធៈ ព្រះជិនស្រីទ្រង់សម្ដែងចូលគ្នាតែមយ៉ាង
ប៉ុណ្ណោះ ព្រោះមានកិច្ច អាហារ និងជា

បដិបក្ខ ដូចគ្នា ព្រោះឧទ្ធច្ចៈ កុក្កុច្ចៈជាដើមទាំង
នោះ មានការរួញរា និងការមិនស្ងប់ជាកិច្ច
មានសេចក្តីពត់កាយ និងត្រិះរិះដល់ញាតិជា
ហេតុ មានសេចក្តីព្យាយាមនិងសេចក្តីស្ងប់ទាំង
នេះ ជាបដិបក្ខ ។

អង្គធម៌ បានដល់ ថីនមិទ្ធចេតសិក នៅក្នុង
អកុសលសសង្ខារិក ៥, ឧទ្ធច្ចចេសិក នៅក្នុងអកុសលចិត្ត
១២ និងកុក្កុច្ចចេតសិក នៅក្នុងទោសមូលចិត្ត ២ ។

## អធិប្បាយអនុស័យកិលេស

***អនុសយៈ*** មានវចនត្ថៈថា ***អប្បហីនត្ថេន អនុ អនុ សន្តានេ សេន្តីតិ = អនុសយា :*** ធម៌ពួកណា រមែង
ដេកត្រាំជាប់ក្នុងសន្តាននៃសត្វ ដោយអត្ថថា មិនអាចលះបាន
ព្រោះហេតុនោះ ធម៌ពួកនោះ ទើបឈ្មោះថា ***អនុស័យ,***

អធិប្បាយថា អនុស័យនោះ មានហេតុដ៏សមគួរ រមែងកើតឡើង ។

ពិតមែន កិលេសដែលមិនទាន់លះបាន គួរដល់ការកើតឡើង ក្នុងកាលមានការបានហេតុ ដូចដេកត្រាំជាប់នៅក្នុងសន្តាន ព្រោះហេតុនោះ កិលេសដែលលោកកំណត់ទុកដូច្នោះ ទើបហៅថា អនុស័យ ។ ក៏កិលេសទាំងនោះ ដែលជាអនាគត ហៅថា អនុស័យ, ដោយនិប្បរិយាយ សូម្បីដែលជាអតីតនិងបច្ចុប្បន្ន លោកក៏ហៅថា អនុស័យដូចគ្នាព្រោះមានឱកាស រមែងកើតឡើង ជាសភាវៈ (ធម្មតា) ។ ពិតណាស់ សេចក្តីផ្សេងគ្នាដោយកាលនៃកិលេសទាំងនោះមិនមាន, មានតែសេចក្តីផ្សេងគ្នានៃសភាវៈប៉ុណ្ណោះ ។

សួរថា ប្រសិនជាកិលេស ដែលឈ្មោះថា អនុស័យព្រោះអត្ថថា មិនអាចលះបាននោះសោត កិលេសទាំងអស់ដែលលះមិនបាន ក៏គួរ ហៅថា អនុស័យដែរឬ ?

ឆ្លើយថា ពួកយើងមិនពោលថា ដែលឈ្មោះថា អនុស័យ មិនមែនដោយហេតុត្រឹមតែលះមិនបានទេ តាមពិត ពួកយើងពោលថា កិលេសដែលមានកម្លាំង ដោយអត្ថថា មិនទាន់លះបោលបាន ឈ្មោះថា អនុស័យ ។ ក៏ការដល់ភាពមានកម្លាំងនៃអនុស័យ មានរាគានុស័យជាដើម មិនបានទូទៅដល់កិលេសដទៃទៀតឡើយ ។

## អនុស័យ ៧ គឺ

**១, កាមរាគៈ** ឈ្មោះថា កាមរាគានុស័យ បានដល់ លោភចេតសិក នៅក្នុងលោភមូលចិត្ត ៨

**២, ភវរាគានុស័យ** បានដល់ លោភចេតសិក នៅក្នុងទិដ្ឋិវិប្បយុត្តចិត្ត ៤

**៣, បដិឃានុស័យ** បានដល់ ទោសចេតសិក នៅក្នុងទោសមូលចិត្ត ២

**៤, មានានុស័យ** បានដល់ មានចេតសិក នៅក្នុងទិដ្ឋិគតវិប្បយុត្ត លោភមូលចិត្ត ៤

***៥, ទិដ្ឋានុស័យ*** បានដល់ ទិដ្ឋិចេតសិក នៅក្នុងទិដ្ឋិគតសម្បយុត្ត លោភមូលចិត្ត ៤

***៦, វិចិកិច្ឆានុស័យ*** បានដល់ វិចិកិច្ឆាចេតសិក នៅក្នុងវិចិកិច្ឆាសម្បយុត្តមោហមូលចិត្ត ១

***៧, អវិជ្ជានុស័យ*** បានដល់ មោហចេតសិក នៅក្នុងអកុសលចិត្ត ១២ ។

## អធិប្បាយ សញ្ញោជនៈ

***សញ្ញោជនៈ*** មានវចនត្ថៈថា ***សំយោជេន្តិ ពន្ធន្តីតិ = សញ្ញោជនោ*** : ធម៌ពួកណា រមែងចងសត្វទុកក្នុងវដ្តៈ ព្រោះហេតុនោះ ធម៌ពួកនោះ ទើបឈ្មោះថា ***សញ្ញោជនៈ*** (ឬ សំយោជនៈ) ។

សញ្ញោជនៈ នៅក្នុងព្រះសុត្តន្តៈ និងក្នុងព្រះអភិធម្ម ចែកជា ២ ពួក ដោយអំណាចនៃភូមិដែលកើត គឺ ៖

***១-ឱរម្ភាគិយសញ្ញោជនៈ*** សំយោជនៈជាចំណែក

ខាងក្រោម ។

**២-ឧទ្ធម្ភាគិយសញ្ញោជនៈ** សំយោជនៈជាចំណែកខាងលើ ។

## សំយោជនៈ ១០ ក្នុងព្រះសុត្តន្តៈ

ឱរម្ភាគិយសញ្ញោជនៈ ៥ គឺ ១.ទិដ្ឋិ ២.វិចិកិច្ឆា ៣.សីលព្វតបរាមាសៈ ៤.កាមឆន្ទៈ ៥.ព្យាបាទៈ

ឧទ្ធម្ភាគិយសញ្ញោជនៈ ៥ គឺ ១.រូបរាគៈ ២.អរូបរាគៈ ៣.មានះ ៤.ឧទ្ធច្ចៈ ៥.អវិជ្ជា

## សញ្ញោជនៈ ១០ ក្នុងព្រះអភិធម្ម

ឱរម្ភាគិយសញ្ញោជនៈ ៧ គឺ ១.កាមរាគៈ ២.បដិឃៈ ៣.ទិដ្ឋិ ៤.សីលព្វតបរាមាសៈ ៥.វិចិកិច្ឆា ៦.ឥស្សា ៧.មច្ឆរិយៈ ។

ឧទ្ធម្ភាគិយសញ្ញោជនៈ ៣ គឺ ១.មានះ ២.ភវរាគៈ ៣.អវិជ្ជា ។

## អន្តធម៌សញ្ញោជនៈ រួមមាន ២ ន័យ

១, **កាមរាគៈ** គឺ លោភចេសិក នៅក្នុងលោភមូលចិត្ត៨

២, **រូបរាគៈ អរូបរាគៈ** គឺ លោភចេសិក នៅក្នុងទិដ្ឋិគត

វិប្បយុត្តចិត្ត ៤

៣, **បដិឃៈ** គឺ ទោសចេតសិក នៅក្នុងទោសចិត្ត ២

៤, **មានៈ** គឺ មានចេតសិក នៅក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត៤

៥, **ទិដ្ឋិ សីលព្វតបរាមាសៈ** គឺ ទិដ្ឋិចេតសិក នៅក្នុង

ទិដ្ឋិគតសម្បយុត្តចិត្ត ៤

៦, **វិចិកិច្ឆា** គឺ វិចិកិច្ឆាចេតសិក នៅក្នុងវិចិកិច្ឆាសម្បយុត្ត១

៧, **ឥស្សា** គឺ ឥស្សាចេតសិក នៅក្នុងទោសមូលចិត្ត ២

៨, **មច្ឆរិយៈ** គឺ មច្ឆរិយចេតសិក នៅក្នុងទោសមូលចិត្ត ២

៩, **ឧទ្ធច្ចៈ** គឺ ឧទ្ធច្ចចេតសិក នៅក្នុងអកុសលចិត្ត ១២

១០, **អវិជ្ជា** គឺ មោហចេតសិក នៅក្នុងអកុសលចិត្ត ១២

សញ្ញោជនៈ ក្នុងព្រះសូត្រ និងព្រះអភិធម្ម កាលរួម

គ្នា ទើងបានអន្តធម៌ តាមដែលពោលមកហើយនេះ កាលចែក

គ្នាក្នុងព្រះសូត្រ បានអង្គធម៌ ត្រឹមតែ ៧ គឺ ១.លោភៈ ២.ទោសៈ ៣.មានះ ៤.ទិដ្ឋិ ៥.វិចិកិច្ឆា ៦.ឧទ្ធច្ចៈ ៧.មោហចេតសិក

ចំណែកនៅក្នុងព្រះអភិធម្ម អង្គធម៌ មាន ៨ គឺ ១.លោភៈ ២.ទោសៈ ៣.មានះ ៤.ទិដ្ឋិ ៥.វិចិកិច្ឆា ៦.ឥស្សា ៧.មច្ឆរិយៈ ៨.មោហចេតសិក

## អធិប្បាយកិលេស ១០

*កិលេស* មានវចនត្ថៈថា ៖

***កិលិស្សន្តិ ឧបតប្បន្តិ ឯតេហីតិ = កិលេសា :*** សត្វរមែងសៅហ្មង គឺ រមែងក្តៅក្រហល់ក្រហាយដោយធម៌នោះ ព្រោះហេតុនោះ ធម៌នោះ ទើបឈ្មោះថា **កិលេស ។**

<u>ក្នុងវិភាវិនីដីកា</u>ថា ចិត្តរមែងសៅហ្មង គឺ រមែងក្តៅក្រហាយ ឬ ត្រូវរុករានដោយធម៌នេះ ព្រោះហេតុនោះ ធម៌

នោះ ឈ្មោះថា **កិលេស ។**

## អង្គធម៌កិលេស ១០

**១, លោភៈ** គឺ លោភចេតសិក នៅក្នុងលោភមូលចិត្ត ៨

**២, ទោសៈ** គឺ ទោសចេតសិក នៅក្នុងទោសមូលចិត្ត ២

**៣, មោហៈ** គឺ មោហចេតសិក នៅក្នុងអកុសលចិត្ត ១២

**៤, មានៈ** គឺ មានៈចេតសិក នៅក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត៤

**៥, ទិដ្ឋិ** គឺ ទិដ្ឋិចេតសិក នៅក្នុងទិដ្ឋិគតសម្បយុត្តចិត្ត៤

**៦, វិចិកិច្ឆា** គឺ វិចិកិច្ឆាចេតសិក នៅក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១

**៧, ថីនៈ** គឺ ថីនចេតសិក នៅក្នុងអកុសលសសង្ខារិកចិត្ត ៥

**៨, ឧទ្ធច្ចៈ** គឺ ឧទ្ធច្ចចេតសិក នៅក្នុងអកុសលចិត្ត ១២

**៩, អហិរិកៈ** គឺ អហិរិកចេតសិក នៅក្នុងអកុសលចិត្ត ១២

**១០, អនោត្តប្បៈ** គឺ អនោត្តប្បចេតសិក នៅក្នុងអកុសលចិត្ត ១២

## កិលេស ១.៥០០

អារម្មណ៍ដែលជាហេតុឱ្យកិលេសកើត មាន ១៥០ គឺ ចិត្ត ១, ចេតសិក ៥២, និប្ផន្នរូប ១៨, និងលក្ខណរូប ៤ រួម ៧៥ ។ អារម្មណ៍ ៧៥ នេះ កើតក្នុងសន្តាន ២ គឺ អជ្ឈត្តសន្តាន និងពហិទ្ធសន្តាន ទើបរួមបានជាអារម្មណ៍ ១៥០, ហើយគុណនឹងកិលេស ១០ ត្រូវជាកិលេស ១.៥០០ ដូច្នេះឯង ។

## តណ្ហា ១០៨

-តណ្ហាក្នុងអារម្មណ៍៦ គឺ ១.រូបតណ្ហា ២.សទ្ទតណ្ហា ៣.គន្ធតណ្ហា ៤.រសតណ្ហា ៥.ផោដ្ឋព្វតណ្ហា ៦.ធម្មតណ្ហា ។

-តណ្ហា ៣ គឺ កាមតណ្ហា ភវតណ្ហា និង វិភវតណ្ហា ។

-តណ្ហាក្នុងអារម្មណ៍ ៦ គុណនឹងតណ្ហា ៣ ជាតណ្ហា ១៨ ។

-តណ្ហា ១៨ កើតក្នុងសន្តាន ២ ជាតណ្ហា ៣៦ ។

-តណ្ហា ៣៦ កើតក្នុងកាល ៣ មានអតីតកាលជាដើម រួមជាតណ្ហា ១០៨ ដោយប្រការ ដូច្នេះ ។

## អធិប្បាយគាថាទី ២ ជាដើម

អាសវៈ ឱឃៈ យោគៈ និងគន្ថៈ នីមួយ ៗ មាន (លោភៈ ទិដ្ឋិ អវិជ្ជា) ៣ យ៉ាង ដោយវត្ថុធម៌ គឺ ដោយសភាវធម៌ តាមន័យដែលព្រះមានព្រះភាគត្រាស់ទុក ។ **ឧបាទាន** ត្រាស់ទុក ២ យ៉ាងប៉ុណ្ណោះ (ដោយសភាវៈ) ដោយអំណាចនៃតណ្ហានិងទិដ្ឋិ, **នីវរណៈ** មាន ៨ ព្រោះចែកថីនៈ និងមិទ្ធៈ, ឧទ្ធច្ចៈ និងកុក្កុច្ចៈ ចេញជាមួយយ៉ាង ៗ, **អនុស័យ** មានត្រឹមតែ ៦ ប៉ុណ្ណោះ ព្រោះរួមកាមរាគានុស័យនិងភវរាគានុស័យចូលជាមួយគ្នាដោយសភាពជាតណ្ហា, **សញ្ញោជនៈ** លោកពោលទុក ៩ យ៉ាង ព្រោះរួមសញ្ញោជនៈដែលជាទិដ្ឋិ និងសីលព្វតបរាមាសៈ តាមដែលត្រាស់ទុកក្នុងព្រះសូត្រ និងព្រះអភិធម្មទាំង ២ ចូលជាមួយយ៉ាង ៗ,

ចំណែកកិលេស មាន ១០ យ៉ាង ទាំងដោយព្រះសូត្រ និង ព្រះអភិធម្ម ។ ខ្ញុំពោលអកុសលសង្គហៈ ទុក ៩ យ៉ាង ដោយប្រការដូច្នេះ ។

## សង្គ្រោះអង្គធម៌ (អកុសលចេតសិក) ១៤ មានលោភៈជាដើម គឺ

| | |
|---|---|
| -លោភៈ បាន៩ឋាន | -មានះ និងឧទ្ធច្ចៈ បាន៣ឋាន |
| -ទិដ្ឋិ បាន៨ឋាន | -ថីនៈ បាន២ឋាន |
| -អវិជ្ជា បាន៧ឋាន | -កុក្កុច្ចៈ មិទ្ធៈ អហិរិកៈ អនោត្តប្បៈ |
| -បដិឃៈ បាន៥ឋាន | ឥស្សា និគូហនា (មច្ឆរិយៈ) |
| -វិចិកិច្ឆា បាន៤ឋាន | ៦ នេះ សង្គ្រោះបាន១ឋាន ។ |

ធម៌ ១៤ សង្គ្រោះចូលក្នុងអកុសលសង្គហៈ ៩ យ៉ាង នេះ ដោយប្រការដូច្នេះ ។

## អធិប្បាយ ធម៌ ១៤ ចូលក្នុងឋាន ៩

**១, លោភចេតសិក** សង្គ្រោះចូលក្នុងអកុសល ៩ ឋាន

២, **ទិដ្ឋិចេតសិក** សង្គ្រោះចូលក្នុងអកុសល ៨ ឋាន (វៀរនីវរណៈ)

៣, **មោហចេតសិក** សង្គ្រោះចូលក្នុងអកុសល ៧ ឋាន (វៀរគន្ថៈ និងឧបាទាន) ។

៤, **ទោសចេតសិក** សង្គ្រោះចូលក្នុងអកុសល ៥ ឋាន (វៀរអាសវៈ ឱឃៈ យោគៈ ឧបាទាន) ។

៥, **វិចិកិច្ឆាចេតសិក** សង្គ្រោះចូលក្នុងអកុសល ៤ ឋាន គឺ អនុស័យ នីវរណៈ សំយោជនៈ កិលេស ។

៦, **ឧទ្ធច្ចចេតសិក** សង្គ្រោះក្នុងអកុសល ៣ ឋាន គឺ នីវរណៈ សំយោជនៈ កិលេស ។

៧, **មានចេតសិក** សង្គ្រោះចូលក្នុងអកុសល ៣ ឋាន គឺ អនុស័យ សំយោជនៈ កិលេស ។

៨, **ថីនចេតសិក** សង្គ្រោះចូលក្នុងអកុសល ២ ឋាន គឺ នីវរណៈ និងកិលេស ។

៩, **មិទ្ធចេតសិក** សង្គ្រោះក្នុងអកុសល ១ឋាន គឺ នីវរណៈ

១០, កុក្កុច្ចចេតសិក សង្គ្រោះក្នុងអកុសល ១ឋាន គឺនីវរណៈ

១១, ឥស្សាចេតសិក សង្គ្រោះចូលក្នុងអកុសល ១ ឋាន គឺ សញ្ញោជនៈ

១២, មច្ឆរិយចេតសិក សង្គ្រោះចូលក្នុងអកុសល ១ ឋាន គឺ សញ្ញោជនៈ

១៣, អហិរិកចេតសិក សង្គ្រោះចូលក្នុងអកុសល ១ ឋាន គឺ កិលេស

១៤, អនោត្តប្បចេតសិក សង្គ្រោះចូលក្នុងអកុសល ១ ឋាន គឺ កិលេស

**ចប់ អកុសលសង្គហៈទី១**

# សំនួរ-ចម្លើយ

## ក្នុងអារម្ភបទ

១- សំ. ចូរប្រែគាថាដែលសម្តែងដល់អនុសន្ធិ និង បដិញ្ញា មាន ទ្វាសត្តតិ វៃធា វុត្តា ជាដើម និងរាប់ចំនួនវត្ថុធម៌ ៧២ មកផង ,

ចំ. គាថានេះ ប្រែថា វត្ថុធម៌ គឺ ធម៌ដែលមានសភាពរបស់ខ្លួនដោយពិត ៧២ ប្រការនោះ ខ្ញុំបានសម្តែងទៅហើយ ឥឡូវនេះ នឹងសម្តែងសមុច្ចយសង្គហៈ គឺសង្គហៈដែលរួបរួមធម៌ផ្សេង ៗ របស់វត្ថុធម៌ ៧២ ប្រការនោះ តាមដែលនឹងចូលគ្នាបាន ។

ចំនួនវត្ថុធម៌ ៧២ ប្រការនោះ មានដូច្នេះ ចិត្តទាំងអស់រាប់យក១ ចេតសិក៥២ និប្ផន្នរូប១៨ និព្វាន១ រួមជា ៧២ ។

២- សំ. សមុច្ចយសង្គហៈ មានន័យយ៉ាងណា ?

ចូរលើកវចនត្ថៈឡើងសម្តែងផង និងការចែកវត្ថុធម៌ ៧២ នោះចេញជាប៉ុន្មានពួក ? អ្វីខ្លះ ? ចូរសម្តែងអត្ថន័យ

របស់ពួកធម៌នោះ ៗផង

ចំ. សមុច្ចយសង្គហៈ មានន័យថា បរិច្ឆេទដែលសម្តែងការប្រមូលបរមត្ថធម៌ទាំង ៤ មានសភាពចូលគ្នាបាន ឈ្មោះថា សមុច្ចយសង្គហៈ ។

មានវចនត្ថៈ សម្តែងថា ៖

សហ ឧច្ចីយន្តេ ឯត្ថាតិ = សមុច្ចយោ វា សំបិណ្ឌេត្វា ឧច្ចីយន្តេ ឯតេនាតិ = សមុច្ចយោ បរិច្ឆេទដែលឈ្មោះថា សមុច្ចយៈ ព្រោះជាបរិច្ឆេទដែលសម្តែងការប្រមូលបរមត្ថធម៌ទាំង ៤ ប្រការ ព្រមគ្នា ឬបរិច្ឆេទដែលឈ្មោះថា សមុច្ចយៈ ព្រោះជាហេតុនៃការប្រមូលបរមត្ថធម៌ ដែលមានសភាពចូលគ្នាបាន ឱ្យនៅជាពួក ៗ ។

ព្រះអនុរុទ្ធាចារ្យ សម្តែងការចែកនូវវត្ថុធម៌ ៧២ នោះជា ៤ ពួក គឺ

១-អកុសលសង្គហៈ ការសង្គ្រោះអកុសល ៩

២-មិស្សកសង្គហៈ ការសង្គ្រោះមិស្សកធម៌ ៧

៣-ពោធិបក្ខិយសង្គហៈ ការសង្គ្រោះពោធិបក្ខិយធម៌ ៣៧

៤-សព្វសង្គហៈ ការសង្គ្រោះធម៌ទាំងពួង មាន៥ ។

## អកុសលសង្គហៈ

៣-សំ. ធម៌ ៩ ពួកក្នុងអកុសលសង្គហៈនោះ មានអ្វីខ្លះ ? ចូរសម្ដែងអង្គធម៌ផង

ចំ. ធម៌ ៩ ពួកក្នុងអកុសលសង្គហៈនោះ គឺ

១. អាសវៈ ។ល។ ៩. កិលេស

ពួកធម៌និមួយ ៗនោះ មានអង្គធម៌ ដូចតទៅនេះ

១. អាសវៈ មាន ៤ គឺ ។ល។

២. ឱឃៈ មាន ៤ គឺ ។ល។

៣. យោគៈ មាន ៤ គឺ ។ល។

៤. គន្ថៈ មាន ៤ គឺ ។ល។

៥. ឧបាទាន មាន ៤ គឺ ។ល។

៦. នីវរណៈ មាន ៦ គឺ ។ល ។

៧. អនុស័យ មាន ៧ គឺ ។ល ។

៨. សញ្ញោជនៈ មាន ១០ គឺ ។ល ។

៩. កិលេស មាន ១០ គឺ ។ល ។

៤- សំ. ចូរប្រែគាថា ដែលសម្តែងដល់អង្គធម៌ក្នុងអកុសលសង្គហៈទាំង ៩ ពួក តើមានវចនត្ថៈសម្តែងយ៉ាងណា ?

ចំ. គាថាដែលសម្តែងដល់អង្គធម៌ក្នុងអកុសលសង្គហៈ ទាំង ៩ ពួកនោះ មានសេចក្តីប្រែដូច្នេះ

១. អាសវៈ ឱឃៈ យោគៈ និងគន្ថៈ ទាំង ៤ នេះ មួយយ៉ាង ៗ មានអង្គបរមត្ថ ៣, ឧបាទាន មានអង្គបរមត្ថ ២ នីវរណៈ មានអង្គបរមត្ថ ៨ ។

២. អនុស័យ មានអង្គបរមត្ថ ៦, សញ្ញោជនៈ មានអង្គបរមត្ថ ៩, កិលេស មានអង្គបរមត្ថ ១០ អ្នកសិក្សាទាំងឡាយ គប្បីជ្រាបនូវការសម្តែងអកុសលសង្គហៈទាំង ៩

ពួកដូច្នេះ ។

មានវចនត្ថៈរបស់ពាក្យថា អកុសលសង្គហៈនោះ មានការសម្ដែងដូច្នេះ

ឯកន្តាកុសលជាតិកានំ ឱយតុក្កាទីនំ សង្គហោតិ = អកុសលសង្គហោ ប្រែថា ពួកដែលសង្គ្រោះសភាវធម៌ផ្សេង ៗ មានឱឃៈជាដើម ដែលជាអកុសលជាតិសុទ្ធ ៗ ដូច្នោះ ទើបឈ្មោះថា អកុសលសង្គហៈ ។

៥- សំ. លោកធ្លាប់បានស្ដាប់មកហើយថា ព្រះអរហន្ត ទាំងឡាយ មិនមានអាសវៈឡើយ ទើបបានឈ្មោះថា ខីណាសវៈ ប្រែថា អ្នកសូន្យចាកអាសវៈ ដូច្នោះលោកចូរពណ៌នារឿងអាសវៈ ឱ្យបានល្អិតល្អន់ និងត្រឹមត្រូវតាមអត្ថន័យមកមើល ?

ចំ. រឿងអាសវៈ មានការពណ៌នាដូច្នេះ

ពាក្យថា អាសវៈ ដោយអត្ថថា វត្ថុដែលត្រាំទុកនៅ

យូរ បានដល់ សុរា តែក្នុងទីនេះពាក្យថា អាសវៈ បានដល់ លោភៈ ទិដ្ឋិ មោហៈ ដែលមានសភាពដូចសុរា ព្រោះតាមធម្មតាសុរានោះ ជាវត្ថុ ដែលត្រាំទុកនៅយូរ ៗ ។ល។ ដូច្នោះ ទើបទ្រង់មិនសម្តែងអកុសលចេតសិកដទៃ ៗថា ជាអាសវៈ

៦. សំ. ចូរអធិប្បាយ ឱឃៈ និងយោគៈ ព្រមទាំងលើក វចនត្ថឡើងសម្តែងផង

ចំ. ពាក្យថា ឱឃៈ មានន័យថា ធម្មជាតិដែលគ្របសង្កត់នូវសត្វទាំងឡាយ និងធ្វើឱ្យសត្វទាំងឡាយឱ្យលិចចុះក្នុងវដ្តសង្សារ ដរាបដល់អបាយភូមិ ដូចគ្នានឹងអន្លង់ទឹក ។

អធិប្បាយថា ធម្មតាអន្លង់ទឹក កាលមានវត្ថុ ឬសត្វណា ធ្លាក់ចូលទៅក្នុងអន្លង់ទឹកនោះហើយ ទឹកនោះ រមែងពន្លិចជ្រមុជនូវវត្ថុ ឬសត្វទាំងឡាយនោះឱ្យលិចចុះ មិនមានឱកាសនឹងអណ្តែតឡើងមកបានឡើយ ដូច្នោះ ក្នុងទីនេះ ធម្មជាតិ ដែលដូចគ្នានឹងអន្លង់ទឹកនោះ មាន ៤ យ៉ាង គឺ

១ លោភៈ ដែលមានសភាពពេញចិត្តក្នុងកាមគុណារម្មណ៍ ហៅថា កាមោឃៈ ។

២ លោភៈ ដែលមានសភាពពេញចិត្តក្នុងរូបភព អរូបភព រូបឈាន អរូបឈាន ហៅថា ភវោឃៈ ។

៣ ទិដ្ឋិ ដែលមានសភាពយល់ឃើញខុសក្នុង រូបនាម ខន្ធ៥ ថា មានខ្លួន ជាយើង ជាគេ ជាស្រី ជាប្រុស ជាដើម ហៅថា ទិដ្ឋោឃៈ ។

៤ មោហៈ ដែលមានសភាពមិនដឹងតាមសេចក្តីពិតរបស់រូបនាម ខន្ធ៥ ដែលមិនមែនខ្លួន មិនមែនយើង មិនមែនគេ មិនមែនស្រី មិនមែនប្រុស ជាដើម ហៅថា អវិជ្ជោឃៈ ។

ដូច្នោះ បុថុជ្ជនទាំងឡាយ ដែលនៅមានជីវិត ប្រព្រឹត្តទៅនៅក្នុងលោកនេះ ដែលនៅមានសេចក្តីត្រេកអរពេញចិត្ត ក្នុងកាមគុណ និងមានសេចក្តីយល់ឃើញខុស សេចក្តីវង្វេងទាំងនេះ សូម្បីថា ភពនេះ នឹងកើតមកជាមនុស្ស ទេវតា មាន

សក្កិខ្ពស់ហើយ ក៏ដោយ ក៏នៅលិចចុះក្នុងសង្សារវដ្តនុ៎ះឯង ហើយទឹងក៏អាចលិចចុះក្នុងអបាយភូមិបានទៀតផង, ចំណែកឯអ្នកបានឈាននោះ សូម្បីថា មិនមានសេក្តីត្រេកអរ ពេញចិត្តក្នុងកាមគុណក៏ពិតមែន តែក៏មានសេក្តីត្រេកអរ ពេញចិត្តក្នុងសេចក្តីសុខ ដែលជាប់ទាក់ទងនឹងឈាន និងការកើតជាព្រហ្មទាំងសេចក្តីយល់ឃើញខុស សេចក្តីវង្វេង ក៏នៅមានដូច្នោះ ឈានលាភីបុគ្គលទាំងឡាយ សូម្បីបានអត្តភាពមកជាមនុស្ស ទេវតា ព្រហ្មហើយក៏ដោយ ក៏នៅតែឈ្មោះថា ជាអ្នកត្រូវលិចចុះក្នុងអន្លង់នៃវដ្តសង្សារនោះឯង មិនងាយមានឱកាស ដែលទឹងឆ្លងឡើងមកឱ្យដល់ព្រះនិព្វាន បានទេ, ទាំងមានពេលដែលទឹងត្រូវទៅលិចុះក្នុងអបាយភូមិ បានទៀតផង, រាប់តាំងពីកពទីបីជាដើមទៅ ប្រសិនបើថា អ្នក( បានឈាន )នោះ មិនមានសម្បត្តិ ៥ យ៉ាង គឺ

១. បុព្វេ កតបុញ្ញតា ជាអ្នកបានធ្វើបុណ្យទុក ក្នុងកាលមុន

២ បដិរូបទេសវាស បានទៅក្នុងប្រទេសដែលមាន
សទ្ធម្មនិងសប្បុរស

៣ សប្បុរិសូបនិស្សយ បានសេពគប់នឹងសប្បុរស

៤ អត្តសម្មាបណិធិ តម្កល់កាយ វាចា ចិត្ត ឱ្យតាំង
នៅក្នុងអំពើល្អ

ទាំងនេះ ក៏ព្រោះថា ព្រហ្មទាំងឡាយ កាលដែលចុតិចាកព្រហ្មលោកមកកើតជាមនុស្ស ឬ ទេវតា រមែងមានសេចក្ដីយល់ឃើញខុសច្រើនជាងមុន បុគ្គលធម្មតាសាមញ្ញលំបាកនឹងលះបង់ឱ្យអស់ទៅបាន ដូច្នោះ សេចក្ដីយល់ឃើញខុសផ្សេង ៗ មានសស្សតទិដ្ឋិជាដើម ដែលមានប្រាកដនៅក្នុងលោកសព្វថ្ងៃនេះ ក៏ជាប់មកពីបុគ្គលទាំងនេះ ជាអ្នកដឹកនាំប្រកាសប្រាប់យ៉ាងច្រើន ហេតុនោះ មនុស្ស ទេវតា ដែលប្រាសចាកសម្បត្តិ ៤ យ៉ាង ដូចពោលមកនេះហើយ កាលស្លាប់ហើយ ក៏ត្រឡប់លិចចុះ ទៅកើតក្នុងអបាយភូមិ បាន

ទៀត ដោយអំណាចនៃទិដ្ឋោឃៈ និងអវិជ្ជោឃៈ ដែលមាននៅក្នុងចិត្តសន្តានរបស់ខ្លួននោះឯង ។

ចំណែកអ្នកដែលបានសម្រេចជាព្រះសោតាបន្ន និងព្រះសកទាគាមី សូម្បីបានកំចាត់សេចក្តីយល់ឃើញខុសអស់រលីងទៅហើយក៏ដោយ តែក៏នៅមានសេចក្តីវង្វេងពេញចិត្តក្នុងកាមគុណារម្មណ៍នៅឡើយ ដោយហេតុនេះ ទើបត្រូវលិចនៅក្នុងអន្លង់នៃកាមសុគតិភូមិ តែមិនមានការត្រឡប់លិចចុះទៅ ដរាបដល់អបាយភូមិទេ សម្រាប់ព្រះអនាគាមីនោះ ក៏នៅមានសេក្តីវង្វេង មានសេក្តីពេញចិត្តក្នុងសុខដែលជាប់ទាក់ទងនឹងឈាន និងឋានព្រហ្ម ដូចជាអ្នកលិចនៅក្បែរ មាត់ច្រាំងដែលមានទឹកត្រឹមចង្កេះ ដោយន័យដូចពោលមកហើយនេះ, លោភៈ ទិដ្ឋិ មោហៈ ទើបឈ្មោះថា ឱឃៈ ។

មានវចនត្ថសម្តែងថា ៖

អវត្ថរិត្វា ហនន្តីតិ = ឱឃា, វា អវហនន្តិ

ឱសីទាបេន្តីតិ = ឱឃា , ឱឃារិយាតិ = ឱឃា ធម្មាតិណា ឱឃៈ រមែងពន្លិចបៀតបៀននូវសត្វទាំងឡាយ ធម្មជាតិនោះ ឈ្មោះថា ឱឃៈ (បានដល់អន្លង់ទឹក) ឬ ធម្មជាតិណា ធ្វើឱ្យសត្វទាំងឡាយលិចចុះ ធម្មជាតិនោះ ឈ្មោះថា ឱឃៈ, ធម៌ ពួកណា រមែងពន្លិចបៀតបៀននូវសត្វទាំងឡាយ និងធ្វើឱ្យសត្វទាំងឡាយលិចចុះ ក្នុងវដ្តសង្សារ ជរាបដល់អបាយភូមិ ដូចគ្នានឹងអន្លង់ទឹក ដូច្នោះធម៌ពួកនោះ ឈ្មោះថា ឱឃៈ (បានដល់ លោភៈ ទិដ្ឋិ មោហៈ) ។

ចំណែកពាក្យថា យោគៈនោះ មានន័យថា ធម្មជាតិដែលប្រកបសត្វទាំងឡាយទុកឱ្យជាប់នៅក្នុងវដ្តទុក្ខ មិនឱ្យផុតទៅបាន ។

អធិប្បាយថា ធម្មតាសត្វទាំងឡាយ ដែលនៅវិលវល់កើតស្លាប់ ៗ ក្នុងវដ្តទុក្ខនេះ មិនមានឱកាសដែលនឹងរួចផុតទៅបាននោះ ក៏ព្រោះជាប់ដោយអំណាចយោគៈទាំង ៤ នេះឯង គឺ

១ លោភៈ ដែលមានសភាពពេញចិត្តក្នុងកាម

គុណារម្មណ៍ ហៅថា កាមយោគៈ

២ លោភៈ ដែលមានសភាពពេញចិត្តក្នុងរូបភព អរូបភព រូបឈាន អរូបឈាន ហៅថា ភវយោគៈ

៣ ទិដ្ឋិ ដែលមានសភាពយល់ឃើញខុស ក្នុងរូបនាម ខន្ធ៥ ថា មានខ្លួន ជាយើង ជាគេ ជាស្រី ជាប្រុស ជាដើម ហៅថា ទិដ្ឋយោគៈ

៤ មោហៈ ដែលមានសភាពមិនដឹងតាមសេក្តីពិត របស់រូបនាម ខន្ធ៥ ដែលមិនមែនខ្លួន មិនមែនយើង មិនមែនគេ មិនមែនស្រី មិនមែនប្រុសជាដើម ហៅថា អវិជ្ជយោគៈ ។

មានសេចក្តីប្រៀបធៀបមកថា ដូចជ័រដែលប្រកបវត្ថុពីរឱ្យជាប់គ្នា មិនឱ្យរបូតផុតចេញពីគ្នាយ៉ាងណា លោភៈ ទិដ្ឋិ មោហៈ ក៏ប្រកបសត្វទាំងឡាយ ទុកឱ្យជាប់នៅក្នុងវដ្តទុក្ខ មិនឱ្យផុតទៅបាន, ដូច្នោះ លោភៈ ទិដ្ឋិ មោហៈ ដូចជ័រ វត្ថុមួយប្រៀបដូចសត្វទាំងឡាយ វត្ថុមួយទៀត ប្រៀបដូចភព ជាតិ

ផ្សេង ៗ គឺវដ្តទុក្ខ ។ មួយទៀត ប្រៀបដូចគោ ដែលគេទឹម
នឹងរទេះ កាលគោដើរទៅផ្លូវណា ក៏ត្រូវទាញ យករទេះជាប់
ទៅជានិច្ចយ៉ាងណា សត្វទាំងឡាយដែលវិល វល់នៅក្នុងវដ្ត
ទុក្ខ មិនអាចផុតទៅបាននោះ ក៏ព្រោះត្រូវ ប្រកបដោយលោភៈ
ទិដ្ឋិ មោហៈ យ៉ាងនោះ, គោប្រៀបដូចសត្វទាំងឡាយ, រទេះ
ប្រៀបដូច កាមភព រូបភព អរូបភព ដែលជាវដ្តទុក្ខ, ខ្សែ
ដែលចងគោឱ្យជាប់នឹងរទេះ ប្រៀបដូច នឹង លោភៈ ទិដ្ឋិ
មោហៈ ។

ដូច្នោះ ការប្រកបសត្វទាំងឡាយឱ្យជាប់នៅក្នុងវដ្ត ទុក្ខ
របស់យោគៈ ទាំង៤ ក៏ដូចគ្នានឹងឱឃៈ៤ ដូចដែលបាន
ពោលមកហើយនោះ ព្រះពុទ្ធទើបទ្រង់សម្តែងលោភៈ ទិដ្ឋិ
មោហៈ ទាំង ៣ នេះ ថា ជាយោគៈ ។

មានវចនត្ថៈ សម្តែងថា ៖

វដ្តស្មឹ សត្តេ យោជេន្តីតិ = យោគា ធម៌ពួកណា
ដែលប្រកបសត្វទាំងឡាយ ឱ្យជាប់នៅក្នុងវដ្តទុក គឺ

ភពផ្សេង ៗ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា យោគៈ ។

៧- សំ. ចូរប្រែ និងអធិប្បាយក្នុងវចនត្ថៈដូចតទៅនេះ

**កាយំ គន្ថេន្តីតិ = កាយគន្ថា វា កាយេន**

**កាយំ គន្ថេន្តីតិ = កាយគន្ថា**

ចូរសម្តែងសេចក្តីផ្សេងគ្នារវាងអភិជ្ឈា ព្យាបាទ ដែលជាមនោទុច្ចរិត និងអភិជ្ឈា ព្យាបាទដែលជាគន្ថៈ ។

ចំ. ពាក្យប្រែវចនត្ថនោះ មានដូច្នេះ

ធម៌ពួកណា ចងគឺក្រៀកទុកនូវនាមកាយ ដូច្នោះ ធម៌ពួកនោះ ឈ្មោះថា កាយគន្ថៈ ឬធម៌ពួកណា ចងគឺក្រៀកទុកក្នុងនោះនាមកាយ រូបកាយក្នុងបច្ចុប្បន្នភព និងនាមកាយ រូបកាយក្នុងអតីតភព ដូច្នោះ ធម៌ពួកនោះ ឈ្មោះថា កាយគន្ថៈ ។

អធិប្បាយ ពាក្យថា គន្ថៈ សំដៅដល់ គ្រឿងចងសត្វទុកដោយអាការៈដែលជាប់ទាក់គ្នា ដូចច្រវាក់ដែក ធម្មតា

ប្រវាក់ដែកជាកងទាក់គ្នា រយើងរយោងជាប់គ្នា ជាខ្សែវែង យ៉ាងណា លោភៈ ទោសៈ ទិដ្ឋិ ទាំង ៣ នេះ ។ល។ គឺ នាមកាយ រូបកាយ ដែលបានដល់សត្វទាំងឡាយនោះឯង ។

សេចក្តីផ្សេងគ្នារវាងអភិជ្ឈា ព្យាបាទ ដែលជាមនោទុច្ចរិត និងអភិជ្ឈា ព្យាបាទៈ ដែលជាគន្ថៈនោះ មានដូច្នេះ គឺ អភិជ្ឈាជាមនោទុច្ចរិត ជាលោភៈយ៉ាងគ្រោតគ្រាត ។ល។ ចាត់ជាអភិជ្ឈាកាយគន្ថៈទាំងអស់, ព្យាបាទ ដែលជា មនោទុច្ចរិត ជាទោសៈយ៉ាងគ្រោតគ្រាត ។ល។ ចាត់ជាព្យាបាទកាយគន្ថៈទាំងអស់ ។

៨- សំ. ពាក្យថា ឧបាទាន ចែកជាប៉ុន្មានបទ ? អ្វីខ្លះ ?

ចូរសម្តែងវចនត្ថៈមកផង

ចំ. ពាក្យថា ឧបាទាន ចែកជា ២ បទ គឺ **ឧប + អាទាន**; ឧប សំដៅដល់ មាំ, អាទាន សំដៅដល់ ប្រកាន់, កាលរួមូលគ្នាហើយ សំដៅដល់ ការប្រកាន់មាំ

ក្នុងអារម្មណ៍ មានវចនត្ថៈ សម្ដែងថា ៖

ឧបាទីយន្តីតិ = ឧបាទានានិ ធម៌ពួកណា រមែង ប្រកាន់អារម្មណ៍ ដូច្នោះ ធម៌ពួកនោះ ទើបឈ្មោះថា ឧបាទាន ។

៩- សំ. តាមធម្មតា មនុស្សយើងទាំងឡាយ មិនធ្លាប់ត្រេកអរ ក្នុងការបំពេញទាន សីល ភាវនា ជាចំណែកច្រើន ដែលជាយ៉ាងនេះ ព្រោះមានអ្វីជាឧបស័គ្គ និងធម៌ដែលជាឧបស័គ្គក្នុងការធ្វើនូវសេចក្ដីល្អនោះមានប៉ុន្មាន ? អ្វីខ្លះ ? ចូរលើកឧទាហរណ៍ មកផង ។

ចំ. តាមធម្មតា មនុស្សយើងទាំងឡាយ មិនធ្លាប់ត្រេកអរក្នុងការបំពេញទាន សីល ភាវនា ជាចំណែកច្រើន ដែលជាយ៉ាងនេះ ក៏ព្រោះមាននីវរណៈជាឧបស័គ្គ ដែលបានដល់ ។ល។ ក៏ធ្វើឱ្យឈានដែលបានហើយនោះសាបសូន្យអស់ទៅ មិនអាចចូលឈានបាន ។ ធម៌ដែលជាឧបស័គ្គ

ក្នុងការធ្វើនូវសេចក្តីល្អនោះមាន ៦ គឺ ១.កាមច្ឆន្ទនីវរណៈ ។ល ។ ៦.អវិជ្ជានីវរណៈ ឧទាហរណ៍ ដូចជាអ្នកដែលមិនមាន សេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។ល ។ សម្តែងឱ្យឃើញថា កុសលធម៌ដែលគួរកើត ក៏មិនមានឱកាសកើត ព្រោះលោភៈជាដើមនោះឯង ជាគ្រឿងទប់ឃាំងកុសលទុក ដូច្នោះ លោភៈជាដើមនេះ ទើបបានឈ្មោះថា នីវរណៈ ។

១០- សំ. កិលេសដែលមិនមែនជាអនុស័យនោះ មានប៉ុន្មាន ប្រភេទ ? អ្វីខ្លះ ? និងកិលេសដែលជាអនុស័យ ជាកិលេសប្រភេទណា ? ចូរលើកវចនត្ថ មកសម្តែងផង ។

ចំ. កិលេសដែលមិនមែនជាអនុស័យនោះមាន ២ គឺ បរិយុដ្ឋានកិលេស និងវិតិក្កមកិលេស និងកិលេសដែលជា អនុស័យនោះ ជាកិលេសប្រភេទស្ងប់ស្ងៀមនៅក្នុងខន្ធសន្តាន របស់សត្វទាំងឡាយ ដែលមិនកើតឡើងកាន់វិថីក្នុងជវនៈ ។

មានវចនត្ថៈ សម្តែងថា ៖

សន្តានេ អនុ អនុ សេន្តីតិ = អនុសយា ធម៌ពួកណា រមែងដេកត្រាំជាប់ក្នុងសន្តាន (ការកើតបន្តគ្នារបស់រូបនាម) នៃសត្វ ដូច្នោះ ធម៌ពួកនោះ ឈ្មោះថា អនុស័យ ។

អនុរូបំ ការណំ លភិត្វា សេន្តីតិ ឧប្បជ្ជន្តីតិ = អនុសយា ធម៌ពួកណា កាលបានហេតុដ៏សមគួរហើយ រមែង កើតឡើងបាន ដូច្នោះ ធម៌ពួកនោះ ឈ្មោះថា អនុស័យ ។

១១- សំ. ចូរលើកឧបមាប្រៀបធៀបរវាងកិលេសទាំង ៣ និងសម្តែងកុសលដែលអាចលះកិលេសទាំង ៣នោះដោយចំពោះ ៗ

ចំ. កិលេសទាំង ៣ ប្រភេទនេះ មានឧបមាដូចឈើគូសភ្លើង, អនុស័យកិលេស ប្រៀបដូចភ្លើងដែលនៅ ត្រង់ក្បាលនៃឈើគូស អារម្មណ៍ផ្សេង ៗដែលមកប៉ះខ្ទប់ទ្វារ ទាំង ៦ ប្រៀបដូចជាដងឈើ កាលភ្លើងប្រាកដឡើង ភ្លើង នេះ

ប្រៀបដូចជាបរិយុដ្ឋានកិលេស, និងកាលភ្លើងនេះ ឆេះនូវវត្ថុដទៃណាមួយហើយ ភ្លើងដែលឆេះវត្ថុនោះ ប្រៀបដូចជាវិតិក្កមកិលេស ដូច្នេះ និងកុសលដែលអាចលះកិលេសទាំង ៣ នោះ ដោយចំពោះ ៗ នោះ គឺ

សីលកុសល អាចលះវិតិក្កមកិលេស

សមាធិកុសល អាចលះបរិយុដ្ឋានកិលេស,

បញ្ញាក្នុងមគ្គ អាចលះអនុស័យនោះ

១២- សំ. ហេតុអ្វីបានជាសេក្តីពេញចិត្ត សេចក្តីក្រោធ សេចក្តីប្រកាន់ខ្លួន ជាដើមទាំងនេះ ឈ្មោះថា សញ្ញោជនកិលេសបាន ? ចូរអធិប្បាយ និងលើកវចនត្ថឡើងសម្តែងផង

ចំ. បានជាសេក្តីពេញចិត្ត សេចក្តីក្រោធ សេចក្តីប្រកាន់ខ្លួនជាដើមទាំងនេះ ឈ្មោះថា សញ្ញោជនកិលេសបាន ព្រោះសេក្តីពេញចិត្ត សេចក្តីក្រោធ សេចក្តីប្រកាន់ខ្លួនជាដើមទាំងនេះ រមែងចងសត្វទាំងឡាយទុក មិនឱ្យផុតចាកវដ្តទុក្ខ ។

អធិប្បាយថា តាមធម្មតា ក្នុងសន្តានរបស់បុថុជ្ជនទាំងឡាយនោះ រមែងមានធម្មជាតិ មួយប្រភេទដែលប្រៀបដូចជាខ្សែពួរ ១០ ខ្សែ ដែលធ្វើការចងរឹតសត្វទាំងឡាយទុក មិនឱ្យផុតចាកវដ្តទុក្ខ ។ ខ្សែទាំង១០នេះ បើថា ខ្សែណាមួយ មានការរឹតបន្តឹងឡើងហើយ ខ្សែសញ្ញោជននោះ ក៏នឹងនាំ សត្វឱ្យទៅកើតភូមិដែលជាប់ដោយសញ្ញោជននោះ ៗ
ដោយអាស្រ័យកម្មដែលសត្វនោះបានធ្វើហើយ ។

មានវចនត្ថៈថា សំយោជេន្តិ ពន្ធន្តីតិ = សញ្ញោជនោ ធម៌ពួកណា រមែងចងសត្វទាំងឡាយទុក ដូច្នោះ ធម៌ពួកនោះ ឈ្មោះថា សញ្ញោជនៈ ។

១៣- សំ. ចូរចែកសញ្ញោជនៈ ១០ ដោយឱរម្ភាគិយសញ្ញោជន និងឧទ្ធម្ភាគិយសញ្ញោជន តាមសុត្តន្តន័យ និងអភិធម្មន័យ ព្រមទាំងបរិយាយរឿងមកផង ។

ច. ចែកសញ្ញោជនៈ ១០ តាមសុត្តន្តន័យ ដោយ
ឱរម្ភាគិយសញ្ញោជនៈ និងឧទ្ធម្ភាគិយសញ្ញោជនៈ មានដូច្នេះ

១-ឱរម្ភាគិយសញ្ញោជនៈ មាន ៥ ។ល ។

២-ឧទ្ធម្ភាគិយសញ្ញោជនៈ មាន ៥ ។ល ។

ចែកសញ្ញោជនៈ ១០ តាមអភិធម្មន័យ ដោយឱរម្ភាគិយសញ្ញោជនៈ និងឧទ្ធម្ភាគិយសញ្ញោជនៈ មានដូច្នេះ

១-ឱរម្ភាគិយសញ្ញោជនៈ មាន ៧ ។ល ។

២-ឧទ្ធម្ភាគិយសញ្ញោជនៈ មាន ៣ ។ល ។

បរិយាយរឿងឱរម្ភាគិយសញ្ញោជនៈ និងឧទ្ធម្ភាគិយសញ្ញោជន ដូច្នេះថា ធម្មតាបុប្ផុជ្ជនទាំងឡាយ ដែលមិនបានឈាននោះ កាមរាគសញ្ញោជនៈ តឹងជាប្រចាំហើយ នឹងបើអ្នកនោះធ្វើទុច្ចរិត ។

ម្យ៉ាងទៀត សញ្ញោជនៈ ១០ ដែលចែកចេញជាឱរម្ភាគិយសញ្ញោជនៈ និងឧទ្ធម្ភាគិយសញ្ញោជនៈនោះ ក្នុងបរមត្ថទីបនីដីកា សញ្ញោជនៈ ដែលត្រូវប្រហារដោយមគ្គខាងក្រោម ៣ នោះ ឈ្មោះថា ឱរម្ភាគិយសញ្ញោជនៈ, សញ្ញោជនៈ ដែលត្រូវប្រហារដោយអរហត្តមគ្គនោះ

ឈ្មោះថា ឧទ្ធម្ភាគិយសញ្ញោជនៈ ។

១៤- សំ. តាមធម្មតា អ្នកដេកដេកលក់ឈឹងនោះ ចិត្តរបស់អ្នកនោះ រមែងផូរផង់មិនមានសៅហ្មងក្តៅក្រហាយយ៉ាងណាទេ កាយវាចា ដែលប្រព្រឹត្តទៅគួរស្អប់ គួរខ្លាច គួរសង្វេគ មិនមាន, តែកាលអ្នកនោះភ្ញាក់ឡើងហើយ ចិត្តក៏ប្រែជាសៅហ្មងខ្លះ ក្តៅក្រហាយ កាយវាចា ក៏មានកិរិយាអាការ ដែលគួរស្អប់ គួរខ្លាច គួរសង្វេគ កើតឡើងទៅផង, ដែលជាយ៉ាងនេះ ព្រោះអំណាចអ្វី ? មានប៉ុន្មាន ? បើរាប់ឱ្យពិស្តារមានប៉ុន្មាន ? រាប់ដោយវិធីយ៉ាងណា ?

ចំ. ដែលជាដូច្នេះ ក៏ដោយអំណាចកិលេស មាន ១០ គឺ ១.លោភកិលេស ២.ទោសកិលេស ៣.មោហកិលេស ៤.មានកិលេស ៥.ទិដ្ឋិកិលេស ៦.វិចិកិច្ឆាកិលេស ៧.ថីនកិលេស ៨.ឧទ្ធច្ចកិលេស ៩.អហិរិកកិលេស ១០.អនោត្តប្បកិលេស ។

**វិធីរាប់កិលេសពិស្តារមាន ១.៥០០ គឺ**

អារម្មណ៍ ដែលជាហេតុឱ្យកិលេស ១០ កើត មាន ១៥០ គឺ នាមតេបញ្ញាស បានដល់ នាមធម៌ ៥៣ (ចិត្ត១ ចេតសិក៥២), និប្ផន្នរូប១៨, និងលក្ខណរូប៤ រួម ៧៥ ។ អារម្មណ៍ ៧៥ នេះ កើតក្នុងសន្តាន២ គឺ អជ្ឈត្តសន្តាន និង ពហិទ្ធសន្តាន ទើបរួមបានជាអារម្មណ៍ ១៥០, ហើយគុណ នឹងកិលេស ១០ ត្រូវជាកិលេស ១.៥០០ ដូច្នេះឯង ។

១៥- សំ. ចូរសម្តែងអកុសលធម៌ដូចតទៅនេះ

ក. ធម៌ដែលជាអាសវៈបាន តែជាគន្ថៈមិនបាន

ខ. ធម៌ដែលជាគន្ថៈបាន តែជាអាសវៈមិនបាន

គ. ធម៌ដែលជាអាសវៈ និងជាគន្ថៈបានទាំងពីរ

ឃ. ធម៌ដែលជាអាសវៈ និងជាគន្ថៈមិនបានទាំងពីរ

ង. ធម៌ដែលជានីវរណៈបាន តែជាសញ្ញោជនៈមិនបាន

ច. ធម៌ដែលជាសញ្ញោជនៈបាន តែជានីវរណៈមិនបាន

ឆ. ធម៌ដែលជានីវរណៈ និងសញ្ញោជនៈបានទាំងពីរ

ជ. ធម៌ដែលជានីវរណៈ និងសញ្ញោជនៈមិនបានទាំងពីរ

ឈ. ធម៌ដែលជាអនុស័យបាន តែជាកិលេសមិនបាន

ញ. ធម៌ដែលជាកិលេសបាន តែជាអនុស័យមិនបាន

ដ. ធម៌ដែលជាអនុស័យ និងកិលេសបានទាំងពីរ

ឋ. ធម៌ដែលជាអនុស័យ និងកិលេសមិនបានទាំងពីរ

និងអកុសលធម៌ដែលជាអាសវៈ ឱឃៈ យោគៈ គន្ថៈ ឧបាទាន នីវរណៈ អនុស័យ សញ្ញោជនៈ កិលេស ទាំង ៩នេះ បានដល់អ្វី ? អកុសលធម៌ដែលមិនបានទាំង ៩នេះ បានដល់អ្វី ?

ចំ.ក. ធម៌ដែលជាអាសវៈបាន តែជាគន្ថៈមិនបាន បាន ដល់ មោហចេតសិក

ខ. ធម៌ដែលជាគន្ថៈបាន តែជាអាសវៈមិនបាន បានដល់ ទោសចេតសិក

គ. ធម៌ដែលជាអាសវៈ និងជាគន្ថៈបានទាំងពីរ បានដល់ លោភចេតសិក ទិដ្ឋិចេតសិក

ឃ.ធម៌ដែលជាអាសវៈ និងជាគន្ថៈមិនបានទាំង

ពីរ បានដល់ អកុសលចិត្ត១២ ចេតសិក២៣ (វៀរអង្គ ធម៌៤ ខាងលើ)

ង. ធម៌ដែលជានីវរណៈបាន តែជាសញ្ញោជនៈមិនបាន បានដល់ ថីនៈ មិទ្ធៈ កុក្កុច្ចៈ

ច. ធម៌ដែលជាសញ្ញោជនៈបាន តែជានីវរណៈមិនបាន បានដល់ មានះ ទិដ្ឋិ ឥស្សា មច្ឆរិយៈ

ឆ. ធម៌ដែលជានីវរណៈ និងសញ្ញោជនៈបានទាំងពីរ បានដល់ លោភៈ ទោសៈ មោហៈ ឧទ្ធច្ចៈ វិចិកិច្ឆា

ជ. ធម៌ដែលជានីវរណៈ និងសញ្ញោជនៈមិនបានទាំងពីរ បានដល់ អកុសលចិត្ត១២ ចេតសិក១៥ (វៀរអង្គធម៌១២)

ឈ. ធម៌ដែលជាអនុស័យបាន តែជាកិលេសមិនបាន មិនមាន

ញ. ធម៌ដែលជាកិលេសបាន តែជាអនុស័យមិនបាន បានដល់ ថីនៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ

ជ. ធម៌ដែលជាអនុស័យ និងកិលេសបានទាំងពីរ បានដល់ លោភៈ ទោសៈ មោហៈ មានះ ទិដ្ឋិ វិចិកិច្ឆា

ឋ. ធម៌ដែលជាអនុស័យ និងកិលេសមិនបានទាំងពីរ បានដល់ អកុសលចិត្ត១២ ចេតសិក១៧ (វៀរ អដ្ឋធម៌ ១០)

និងអកុសលធម៌ដែលជាអាសវៈ ឱឃៈ យោគៈ គន្ថៈ ឧបាទាន នីវរណៈ អនុស័យ សញ្ញោជនៈ កិលេស ទាំង ៩នេះ បានដល់ លោភចេតសិក អកុសលធម៌ដែល មិនបានទាំង ៩នេះ បានដល់ អកុសលចិត្ត១២ អញ្ញសមានាចេតសិក ដែលប្រកបក្នុងអកុសលចិត្ត

**ចប់ សំនួរ-ចម្លើយក្នុងអកុសលសង្គហៈ**

# ២. មិស្សកសង្គហៈ

*មិស្សកសង្គហៈ* បានដល់ ការសង្គ្រោះធម៌ជាកុសល អកុសល និងអព្យាកតៈ លាយចូលជាពួកតែមួយរួមគ្នា ហៅថា មិស្សកសង្គហៈ ។

**មិស្សកសង្គហៈ មានធម៌ ៧ ពួក**

**១, ហេតុ ៦** គឺ លោភៈ១ ទោសៈ១ មោហៈ១ អលោភៈ១ អទោសៈ១ អមោហៈ១ ។

**២, អង្គឈាន ៧** គឺ វិតក្កៈ១ វិចារៈ១ បីតិ១ ឯកគ្គតា១ សោមនស្ស១ ទោមនស្ស១ ឧបេក្ខា១ ។

**៣, អង្គមគ្គ ១២** គឺ សម្មាទិដ្ឋិ១ សម្មាសង្កប្បៈ១ សម្មាវាចា១ សម្មាកម្មន្តៈ១ សម្មាអាជីវៈ១ សម្មាវាយាមៈ១ សម្មាសតិ១ សម្មាសមាធិ១ មិច្ឆាទិដ្ឋិ១ មិច្ឆាសង្កប្បៈ១ មិច្ឆាវាយាមៈ១ មិច្ឆាសមាធិ១ ។

៤, **ឥន្ទ្រិយ ២២** គឺ ចក្ខុន្ទ្រិយ១ សោតិន្ទ្រិយ១ ឃានិន្ទ្រិយ១ ជិវ្ហិន្ទ្រិយ១ កាយិន្ទ្រិយ១ ឥត្ថិន្ទ្រិយ១ បុរិសិន្ទ្រិយ១ ជីវិតិន្ទ្រិយ១ មនិន្ទ្រិយ១ សុខិន្ទ្រិយ១ ទុក្ខិន្ទ្រិយ១ សោមនស្សិន្ទ្រិយ១ ទោមនស្សិន្ទ្រិយ១ ឧបេក្ខិន្ទ្រិយ១ សទ្ធិន្ទ្រិយ១ វីរិយិន្ទ្រិយ១ សតិន្ទ្រិយ១ សមាធិន្ទ្រិយ១ បញ្ញិន្ទ្រិយ១ អនញ្ញតញ្ញស្សាមីតិន្ទ្រិយ ១ អញ្ញិន្ទ្រិយ១ និងអញ្ញាតាវិន្ទ្រិយ១ ។

៥, **ពលៈ ៩** គឺ សទ្ធាពលៈ១ វីរិយពលៈ១ សតិពលៈ១ សមាធិពលៈ១ បញ្ញាពលៈ១ ហិរិពលៈ១ ឱត្តប្បពលៈ១ អហិរិកពលៈ១ អនោត្តប្បពលៈ១ ។

៦, **អធិបតី ៤** គឺ ឆន្ទាធិបតី ១ វីរិយាធិបតី ១ ចិត្តាធិបតី ១ វិមំសាធិបតី ១ ។

៧, **អាហារ ៤** គឺ កពឡិង្ការាហារ ១ ផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១ ។

ក៏មិស្សកសង្គហៈ ៧ នេះ ក្នុងឥន្ទ្រិយទាំងឡាយ

សោតាបត្តិមគ្គញ្ញាណ លោកហៅថា អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ អរហត្តផលញាណ លោកហៅថា អញ្ញាតាវិន្ទ្រិយ ចំណែកញាណ ៦ នៅចន្លោះកណ្តាល (គឺ សោតាបត្តិផល ដល់អរហត្តមគ្គញាណ) លោកហៅថា អញ្ញិន្ទ្រិយ ។

ចំណែកជីវិតិន្ទ្រិយ មាន ២ យ៉ាង ដោយអំណាចនៃរូប និងអរូប ។ អង្គឈានមិនមាននៅក្នុងបញ្ចវិញ្ញាណ, ពលៈមិនមាននៅក្នុងពួកអវិរិយៈ, អង្គមគ្គ មិនមាននៅក្នុងពួកអហេតុកៈ ។ មួយទៀត ឯកគ្គតានៅក្នុងចិត្តដែលសម្បយុត្តដោយវិចិកិច្ឆា មិនប្រព្រឹត្តទៅដល់ភាពជាមគ្គ ឥន្ទ្រិយ ពលៈ ចំពោះក្នុងទ្វិហេតុក ជវន និងតិហេតុកជវន បានត្រឹមតែអធិបតីម្យ៉ាង តាមគួរដល់ការកើតដូច្នេះឯង ។

## សង្គហគាថា

៤ ឆ ហេតូ បញ្ច ឈានង្គា មគ្គង្គា នវ វត្ថុតោ
សោឡសិន្ទ្រិយធម្មា ច ពលធម្មា នវេរិតា ។

៥ ចត្តារោធិបតី វុត្តា តថាហារាតិ សត្តធា
កុសលាទិសមាកិណ្ណោ វុត្តោ មិស្សកសង្គហោ ។

*មិស្សកសង្គហៈ ដែលលាយដោយកុសលជាដើម លោកពោលទុក ៧ យ៉ាង ដោយសភាវៈ គឺ ហេតុលោកពោលទុក ៦. អង្គឈានពោលទុក ៥. អង្គមគ្គ ពោលទុក ៩. ឥន្ទ្រិយ ពោលទុក ១៦. ពលៈ ពោលទុក ៩. អធិបតី ពោលទុក ៤. និង អាហារពោលទុក ៤ ដូចគ្នា ។*

## អធិប្បាយ មិស្សកសង្គហៈ ៧

*ពាក្យដែលគប្បីពោលនៅក្នុងពួកហេតុ ៦ ខ្ញុំបាន ពោលទុកហើយ នៅក្នុងបរិច្ឆេទទី ៣ នោះឯង ។*

## អធិប្បាយ អង្គឈាន ៧

*ធម៌មានវិតក្កៈជាដើមនោះ ឈ្មោះថា* **ឈាន** *ព្រោះ អត្ថថា ចូលទៅសម្លឹង គឺ ចូលទៅសញ្ជឹងគិតពិចារណា*

អារម្មណ៍ និងព្រោះអត្ថថា ដុតបំផ្លាញធម៌ជាសត្រូវ តាមសមគួរ និងវិតក្កៈជាដើមទាំងនោះ ។

ឈ្មោះថា អង្គ ក៏ព្រោះជាគ្រឿងកំណត់ គឺ ជាគ្រឿងដឹងដោយជាចំណែកប្រកបរបស់ធម៌ទាំងឡាយដែលកើតឡើង ព្រោះដូច្នោះ ទើបឈ្មោះថា ឈានង្គ ប្រែថា **អង្គឈាន ។**

មួយទៀត សូម្បីមិនមានពួកធម៌ដែលកើតឡើងដែលជាធម៌ផុតចាកចំណែកប្រកប បណ្ឌិតក៏ហៅវិតក្កៈជាដើមដោយភាពជាអង្គតែមួយយ៉ាង ៗ ដូចអង្គនៃរថ និងអង្គនៃសេនាតែមួយយ៉ាង ៗ ដោយរួមចូលគ្នា ជាឈាន ។ បណ្ដាអង្គឈានទាំងនោះ ទោមនស្សជាអង្គនៃអកុសលឈានដែលនៅសល់ទុំះឯង មានវិតក្កៈជាដើម ជាអង្គឈានរបស់កុសល អកុសល និងអព្យាកតៈ ។

## អង្គឈាន ផុតបដិបក្ខធម៌

| | |
|---|---|
| ១. វិតក្កៈ | ផុតថីនមិទ្ធៈ |
| ២. វិចារៈ[១] | ផុតវិចិកិច្ឆា |
| ៣. បីតិ | ផុតព្យាបាទៈ |
| ៤. សោមនស្ស, ឧបេក្ខា | ផុតឧទ្ធច្ចៈ កុក្កុច្ចៈ ទោមនស្ស |
| ៥. ឯកគ្គតា | ផុតកាមឆន្ទៈ ។ |

## អង្គធម៌នៃអង្គឈាន

១. **វិតក្កៈ** បានដល់ វិតក្កចេតសិក នៅក្នុងកាមចិត្ត ៤៤ និងបឋមជ្ឈានចិត្ត ១១ រួមជា ៥៥ ។

២. **វិចារៈ**[១] បានដល់ វិចារចេតសិកនៅក្នុងកាមចិត្ត ៤៤ និងបឋមជ្ឈានចិត្ត១១ ទុតិយជ្ឈាន១១ រួម៦៦ ។

៣. **បីតិ** បានដល់ បីតិចេតសិក នៅក្នុងកាម

---

១. វិចារៈ មានគតិដូចបញ្ញា តែមិនមែនជាបញ្ញា ទើបអាចផុតវិចិកិច្ឆា ។

សោមនស្ស ១៨ (លោភមូលចិត្ត ៤ មហាកុសលចិត្ត ៤ មហាវិបាកចិត្ត៤ មហាកិរិយាចិត្ត៤ សោមនស្សសន្តីរណចិត្ត១ ហសិតុប្បាទចិត្ត១), បឋមជ្ឈានចិត្ត១១ ទុតិយជ្ឈានចិត្ត១១ តតិយជ្ឈានចិត្ត១១ រួមទាំងអស់ ៥១ ។

៤. **សោមនស្ស** បានដល់ សោមនស្សវេទនា នៅក្នុងសោមនស្សសហគតចិត្ត ៦២ (លោភមូលចិត្ត ៤ អហេតុកចិត្ត ២ កាមាវចរសោភណចិត្ត ១២ បឋមជ្ឈានចិត្ត ១១ ទុតិយជ្ឈានចិត្ត ១១ តតិយជ្ឈានចិត្ត ១១ ចតុត្ថជ្ឈានចិត្ត ១១) ។

៥. **ទោមនស្ស** បានដល់ ទោមនស្សវេទនា ក្នុងទោសមូលចិត្ត ២ ។

៦. **ឧបេក្ខា** បានដល់ ឧបេក្ខាវេទនា នៅក្នុងឧបេក្ខាសហគតចិត្ត ៤៧ (អកុសលចិត្ត ៦ អហេតុកចិត្ត ៦ វៀរឧបេក្ខាទ្វិបញ្ចវិញ្ញាណ ៨ កាមាវចរសោភណឧបេក្ខាចិត្ត ១២ រូបាវចរបញ្ចមជ្ឈាន ៣, អរូបាវចរឈាន

១២ និងលោកុត្តរចិត្ត ៨ ) ។

៧. **ឯកគ្គតា** បានដល់ ឯកគ្គតាចេតសិក នៅក្នុងចិត្ត ៧៩ ឬ ១១១ ( វៀរទ្វិបញ្ចវិញ្ញាណ ១០ ) ។

## អធិប្បាយ អង្គមគ្គ ១២

ឈ្មោះថា មគ្គ ព្រោះធ្វើឱ្យសត្វបែរតម្រង់ទៅសុគតិ ទុគ្គតិ និងព្រះនិព្វាន អង្គជាផ្លូវនៃមគ្គទាំងនោះ ឬអង្គនៃអដ្ឋង្គិកមគ្គ ឈ្មោះថា **មគ្គង្គ** ( អង្គនៃមគ្គ ) ។

ធម្មជាតិ ឈ្មោះថា **សម្មាទិដ្ឋិ** ព្រោះអត្ថថា ឃើញដោយប្រពៃ គឺ មិនវិបរិត ។

សម្មាទិដ្ឋិនោះ មាន ១០ យ៉ាង ដោយអំណាចនៃន័យថា "ទានដែលបុគ្គលឱ្យហើយមានផល"ជាដើម ឬសម្មាទិដ្ឋិ ៤ យ៉ាង ដោយអំណាចនៃកិច្ច មានបរិញ្ញាតព្វកិច្ចជាដើម[១] ។

---

១. អត្ថយោជនាតតិយភាគ. កិច្ច ៤ គឺ បរិញ្ញា បហានៈ សច្ឆិកិរិយា

សភាវៈ ឈ្មោះថា **សម្មាសង្កប្បៈ** ព្រោះអត្ថថា ជាគ្រឿងត្រិះរិះប្រពៃ ។

សម្មាសង្កប្បៈនោះ មាន ៣ គឺ នេក្ខម្មសង្កប្បៈ ១ អព្យាបាទសង្កប្បៈ ១ អវិហិង្សាសង្កប្បៈ ១ ។

សម្មាវាចាជាដើម ខ្ញុំបានពន្យល់ច្បាស់ទុកក្នុងកាលមុននុ៎ះឯង ។[១]

សភាវៈ ឈ្មោះថា **សម្មាវាយាមៈ** ព្រោះអត្ថថា ជាគ្រឿងព្យាយាមប្រពៃ ។

សភាវៈ ឈ្មោះថា **សម្មាសតិ** ព្រោះអត្ថថា ជាគ្រឿងរលឹកប្រពៃ ។ ម្យ៉ាងទៀត ជនទាំងឡាយ រមែងរលឹកដោយប្រពៃ ដោយធម្មជាតិនេះ ព្រោះហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា សម្មាសតិ ។

---

ភាវនា ។ **បរិច្ឆិន្ទិត្វា ជានាទំ បរិញ្ញា** ប្រែថា ដឹងការកំណត់ ។

១. ក្នុងបរិច្ឆេទទី ២ ទំព័រ ៩៧ ។

សភាវៈ ឈ្មោះថា **សម្មាសមាធិ** ព្រោះអត្ថថា ជាហេតុតាំងមាំនៃចិត្ត ដោយប្រពៃ និងដោយស្មើជានិច្ច បានដល់ឯកគ្គតា ៥ ដោយអំណាចនៃឈាន មានបឋមជ្ឈានជាដើម ។

មិច្ឆាទិដ្ឋិ១ មិច្ឆាសង្កប្បៈ១ មិច្ឆាវាយាមៈ១ មិច្ឆាសមាធិ១ ឈ្មោះថា មគ្គង្គៈ ព្រោះជាអង្គ គឺ ផ្លូវនៃទុគ្គតិ ។

* អដ្ឋង្គិកមគ្គ ៨ និងមិច្ឆាមគ្គ ៤ រួមជាមគ្គង្គៈ ១២ យ៉ាង ដោយប្រការ ដូច្នេះ ។

## អង្គធម៌មគ្គង្គៈ ១២[១]

១. **សម្មាទិដ្ឋិ** គឺ បញ្ញាចេតសិក នៅក្នុងញាណសម្បយុត្តចិត្ត ៤៧ ឬ ៧៩ ( វៀរអសោភណចិត្ត ៣០ និងសោភណញាណវិប្បយុត្តចិត្ត ១២ )

---

១. នៅក្នុងព្រះសូត្រមានមគ្គបន្ថែមទៀត គឺ មិច្ឆាវាចា មិច្ឆាកម្មន្តៈ មិច្ឆាអាជីវៈ មិច្ឆាសតិ ។

២. **សម្មាសង្កប្បៈ** គឺ វិតក្កចេតសិក នៅក្នុងកាមាវចរសោភណចិត្ត ២៤ និងបឋមជ្ឈានចិត្ត ១១

៣. **សម្មាវាចា** គឺ សម្មាវាចាចេតសិក នៅក្នុងមហាកុសលចិត្ត ៨ លោកុត្តរចិត្ត ៤០

៤. **សម្មាកម្មន្តៈ** គឺ សម្មាកម្មន្តចេតសិក នៅក្នុងមហាកុសលចិត្ត ៨ លោកុត្តរចិត្ត ៤០

៥. **សម្មាអាជីវៈ** គឺ សម្មាអាជីវចេតសិក នៅក្នុងមហាកុសលចិត្ត ៨ លោកុត្តរចិត្ត ៤០

៦. **សម្មាវាយាមៈ** គឺ វីរិយចេតសិក នៅក្នុងសោភណចិត្ត ៩១

៧. **សម្មាសតិ** គឺ សតិចេតសិក នៅក្នុងសោភណចិត្ត ៩១ នុ៎ះឯង

៨. **សម្មាសមាធិ** គឺ ឯកគ្គតាចេតសិក នៅក្នុងសោភណចិត្ត ៩១

៩. **មិច្ឆាទិដ្ឋិ** គឺ ទិដ្ឋិចេតសិក នៅក្នុងទិដ្ឋិគត

សម្បយុត្តចិត្ត ៤

**១០. មិច្ឆាសង្កប្បៈ** គឺ វិតក្កចេតសិក នៅក្នុងអកុសលចិត្ត ១២

**១១. មិច្ឆាវាយាមៈ** គឺ វីរិយចេតសិក នៅក្នុងអកុសលចិត្ត ១២

**១២. មិច្ឆាសមាធិ** គឺ ឯកគ្គតាចេតសិក នៅក្នុងអកុសលចិត្ត ១១ (វៀរឧទ្ធច្ចៈ) ។

***ក៏មគ្គង្គៈ ១២ នោះ ពោលដោយអង្គធម៌មាន ៩ គឺ***

១.បញ្ញា ២.វិតក្កៈ ៣.សម្មាវាចា ៤.សម្មាកម្មន្តៈ ៥.សម្មាអាជីវៈ ៦.វីរិយៈ ៧.សតិ ៨.ឯកគ្គតា ៩.ទិដ្ឋិ ។

ក្នុងមគ្គ ៩ នេះ ទិដ្ឋិជាអកុសលតែម្យ៉ាង, បញ្ញា វិរតិ ៣ សតិ ជាកុសល និងអព្យាកតៈ, ចំណែកវិតក្កៈ វីរិយៈ ឯកគ្គតា ជាកុសល អកុសល និងអព្យាកតៈទាំងឯង ។

## អធិប្បាយ ឥន្ទ្រិយ ២២

ធម៌ទាំងឡាយ មានចក្ខុន្ទ្រិយជាដើម ធ្វើចក្ខុវិញ្ញាណជាដើម ឱ្យប្រព្រឹត្តទៅតាមខ្លួន ក្នុងកិច្ចទាំងឡាយ មានទស្សនកិច្ចជាដើម ឈ្មោះថា **ឥន្ទ្រិយ** ព្រោះអត្ថថា ជាធំ ។

ធម៌ទាំងឡាយ ធ្វើភេទជាដើមឱ្យប្រព្រឹត្តទៅតាមខ្លួន ក្នុងសន្តាន ដែលប្រកបដោយសភាវៈនោះ ដោយច្រើនធ្វើកម្មជរូប និងសម្បយុត្តធម៌ដែលរស់នៅឱ្យប្រព្រឹត្តទៅតាមខ្លួន ក្នុងខណៈរស់នៅធ្វើសម្បយុត្តធម៌ ឱ្យប្រព្រឹត្តទៅតាមខ្លួន ក្នុងខណៈដឹងអារម្មណ៍, ធ្វើធម៌ដែលកើតរួមជាមួយធម៌ មានសេចក្តីសុខជាដើម ឱ្យប្រព្រឹត្តទៅតាមខ្លួន ក្នុងវេលាមានសេចក្តីសុខជាដើម ។ ធ្វើធម៌ដែលកើតរួមគ្នាទាំងនោះឯងដែលប្រព្រឹត្តទៅដោយអំណាចសទ្ធាជាដើម ឱ្យប្រព្រឹត្តទៅតាមខ្លួន ក្នុងខណៈមានការជឿ ធ្វើធម៌ដែលកើតរួមគ្នា ដែលប្រព្រឹត្តទៅយ៉ាងនោះ ក្នុងខណៈប្រព្រឹត្តទៅដោយអធ្យាស្រ័យ

ថា "**យើងនឹងដឹងវត្ថុ ដែលនៅមិនទាន់ដឹង**" ឱ្យប្រព្រឹត្តទៅតាមខ្លួន ។ ធម៌ដែលកើតរួមគ្នា ដែលប្រព្រឹត្តទៅ ដោយអំណាចសេចក្ដីដឹងទូទៅជាដើម ឱ្យប្រព្រឹត្តទៅតាមខ្លួន ក្នុងខណៈដឹងទូទៅនិងក្នុងភាពជាអ្នកដឹងទូទៅ ឈ្មោះថា ឥន្ទ្រិយ ព្រោះអត្ថថា ជាធំ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលពាក្យជាដើមថា **ចក្ខុន្ទ្រិយំ** (ចក្ខុន្ទ្រិយ)ជាដើម ។

តែក្នុងអដ្ឋកថាវិភង្គ ព្រះពុទ្ធឃោសាចារ្យបានពោលអត្ថនៃឥន្ទ្រិយទុក ដោយប្រការដទៃថា "អត្ថនៃឥន្ទ្រិយ មានអត្ថថា ជាគ្រឿងសំគាល់ដល់វត្ថុ ដែលធំជាដើម" ។

ឥន្ទ្រិយ ២២ នេះ ព្រះមានព្រះភាគត្រាស់ទុកក្នុងព្រះអភិធម្ម ចំណែកក្នុងព្រះសូត្រត្រាស់ឥន្ទ្រិយ ២ ខ្លះ ៣ ខ្លះ ៥ ខ្លះ តាមអធ្យាស្រ័យរបស់វេនេយ្យសត្វ ។

ពាក្យថា ជីវិតិន្ទ្រិយ បានដល់ រូបជីវិតិន្ទ្រិយ និងអរូបជីវិតិន្ទ្រិយ ។

ឥន្ទ្រិយរបស់បុគ្គលអ្នកប្រតិបត្តិហើយ ដោយអធ្យាស្រ័យ យ៉ាងនេះថា "យើងនឹងដឹងអមតបទ ឬសច្ចធម៌ ៤ ដែលមិនធ្លាប់ដឹងក្នុងសង្សារវដ្ត មានខាងដើម និងទីបំផុត ដែលបុគ្គលដឹងមិនបាន ឈ្មោះថា អនញ្ញតញ្ញស្សាមីតិន្ទ្រិយ ។

ញាណណា រមែងដឹងទូទៅ គឺ ដឹងមិនហួសខែត្រដែនដែលបឋមមគ្គឃើញហើយ[១] និងជាឥន្ទ្រិយផង ព្រោះហេតុនោះ ញាណនោះ ទើបឈ្មោះថា អញ្ញិន្ទ្រិយ ។

ឥន្ទ្រិយរបស់ព្រះអរហន្ត ដឹងទូទៅ គឺ អ្នកចាក់ធ្លុះអរិយសច្ចៈ ៤ ហើយ នៅមានជីវិតរស់នៅ ឈ្មោះថា អញ្ញាតាវិន្ទ្រិយ ។

ក៏ការកាន់យកឥន្ទ្រិយ គឺ បញ្ញាក្នុងទីនេះ ដើម្បី

---

១. អភិធានទប្បទីបិកាសូចិ ពោលថា "បឋមមគ្គជាដើម ឃើញហើយ" ។

សេចក្ដីជាក់ច្បាស់នៃការសរុបធម៌ ។ ការកាន់យកឥន្ទ្រិយមានអនញ្ញាតញ្ញស្សាមីតិន្ទ្រិយជាដើម ដើម្បីការជាក់ច្បាស់នៃកិច្ចវិសេសរបស់អធ្យាស្រ័យ សម្រាប់បុគ្គលជាវេនេយ្យសត្វនុ៎ះឯង ។

## សម្ដែងលំដាប់ ឥន្ទ្រិយ ២២

ក៏នៅក្នុងឥន្ទ្រិយនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់អាយតនៈខាងក្នុងទុកខាងដើម ព្រោះជាទីអាស្រ័យពិសេសនៃការបញ្ញត្តិថា **សត្វ** (សត្តប្បញ្ញត្តិ) ។ ចំណែកមនិន្ទ្រិយសូម្បីគួរត្រាស់ទុកក្នុងអាយតនៈខាងក្នុងនេះដែរ ប៉ុន្តែ ក៏ត្រាស់ទុកក្នុងលំដាប់នៃជីវិតិន្ទ្រិយ ដើម្បីសម្ដែងរួមគ្នាជាមួយអរូបជីវិតិន្ទ្រិយ ។ ត្រាស់ភាវៈ ២ ទុកលំដាប់នៃអាយតនៈខាងក្នុងនោះ ដើម្បីសម្ដែងថា បញ្ញត្តិនោះ រមែងមានការបែងចែកថា **"ជាស្រី ជាប្រុស"** ដោយអំណាចនៃភាវៈទាំងនេះ ។ ត្រាស់ជីវិតិន្ទ្រិយទុកក្នុងលំដាប់ភាវរូបនោះ ដើម្បីសម្ដែងថា "ឧបាទិន្នធម៌ទាំងនោះ រមែងតាំងនៅបានដោយ

អំណាចជីវិតិន្ទ្រិយនេះ” ។ ត្រាស់វេទនា ៥ ក្នុងលំដាប់នៃជីវិតិន្ទ្រិយនោះ ដើម្បីសម្តែងថា “កងធម៌ដែលសំគាល់ថាជាសត្វ កាលប្រព្រឹត្តទៅដោយអំណាចការបន្ត រមែងសៅហ្មងដោយវេទនាទាំងនេះ” ។

ចំណែកឥន្ទ្រិយ ៥ មានសទ្ធាជាដើម ត្រាស់ទុកក្នុងលំដាប់នៃវេទនា ៥ នោះ ដើម្បីសម្តែងភោទាន(ភាពផូរផង់) និងសម្ភារៈរបស់ពួកសត្វ ដែលប្រាថ្នាសេចក្តីបរិសុទ្ធិចាកវេទនាទាំងនោះ ។ និងត្រាស់ឥន្ទ្រិយ ៣ ទុកក្នុងទីបំផុត ដើម្បីសម្តែងថា “ក៏សត្វទាំងឡាយ អ្នកមានភោទាននិងសម្ភារៈដែលខ្ជួនសន្សំទុកហើយ រមែងបរិសុទ្ធហ្មត់ចត់ដោយឥន្ទ្រិយទាំង ៣ នេះ ព្រោះដូច្នោះ សត្វទាំងនោះ ទើបជាអ្នកបរិសុទ្ធហើយ និងសម្រេចកិច្ចហើយ ការសម្រេចនៃសេចក្តីមានត្រឹមតែប៉ុណ្ណោះឯង ។

## អង្គធម៌ ឥន្ទ្រិយ ២២

១-៥ ចក្ខុន្ទ្រិយជាដើម បានដល់ ចក្ខុប្រសាទជាដើម

៦-៧ ឥត្ថិន្ទ្រិយ-បុរិសិន្ទ្រិយ បានដល់ ភាវរូបទាំង ២

៨- ជីវិតិន្ទ្រិយ បានដល់ ជីវិតរូប ជីវិតិន្ទ្រិយចេតសិក

៩- មនិន្ទ្រិយ បានដល់ ចិត្តទាំងអស់

១០- សុខិន្ទ្រិយ បានដល់ សុខនៅក្នុងសុខសហគតកាយវិញ្ញាណ ១

១១- ទុក្ខិន្ទ្រិយ បានដល់ ទុក្ខនៅក្នុងទុក្ខសហគតកាយវិញ្ញាណ១

១២- សោមនស្សិន្ទ្រិយ បានដល់ សោមនស្ស នៅក្នុង សោមនស្សសហគតចិត្ត ៦២

១៣- ទោមនស្សិន្ទ្រិយ បានដល់ ទោមនស្សនៅក្នុងទោមនស្ស សហគតចិត្ត ២

១៤- ឧបេក្ខិន្ទ្រិយ បានដល់ ឧបេក្ខានៅក្នុងឧបេក្ខាសហគតចិត្ត ៥៥

១៥- សទ្ធិន្ទ្រិយ បានដល់ សទ្ធានៅក្នុងសោភណចិត្ត៩១

១៦- វីរិយិន្ទ្រិយ បានដល់ វីរិយៈនៅក្នុងវីរិយសម្បយុត្តចិត្ត ១០៥

១៧- សតិន្ទ្រិយ បានដល់ សតិនៅក្នុងសោភណចិត្ត ៩១

១៨- សមាធិន្ទ្រិយ បានដល់ ឯកគ្គតានៅក្នុងចិត្ត ៧២
(វៀរអវីរិយចិត្ត ១៦ និងវិចិកិច្ឆាសម្បយុត្តចិត្ត ១)

១៩-បញ្ញិន្ទ្រិយ បានដល់ បញ្ញានៅក្នុងញាណសម្បយុត្តចិត្ត
៤៧ ឬ ៧៩

២០-អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ បានដល់ បញ្ញានៅក្នុងសោតាបត្តិមគ្គចិត្ត ១

២១-អញ្ញិន្ទ្រិយ បានដល់ បញ្ញានៅក្នុងមគ្គខាងលើ ៣ ផលខាងក្រោម ៣

២២-អញ្ញាតាវិន្ទ្រិយ បានដល់ បញ្ញានៅក្នុងអរហត្តផលចិត្ត១ ។

**ឥន្ទ្រិយ ២២ នេះ មានសភាវៈ ១៦ គឺ**

ប្រសាទរូប ៥ ភាវរូប ២ និងជីវិតរូប ១ រួមជា ៨ នេះ ជារូបធម៌, និងអរូបធម៌ ៨ គឺ វេទនា ១ សទ្ធា ១ វីរិយៈ ១ សតិ ១ ឯកគ្គតា ១ បញ្ញា ១ អរូបជីវិតិ

ន្ទ្រិយ ១ និងចិត្ត ១ ។

ឥន្ទ្រិយ ២២ នេះ ជាលោកិយតែម្យ៉ាង មាន ១០ ឥន្ទ្រិយ គឺ រូបឥន្ទ្រិយ៥ មានចក្ខុន្ទ្រិយជាដើម ឥត្ថិន្ទ្រិយ១ បុរិសិន្ទ្រិយ១ សុខិន្ទ្រិយ១ ទុក្ខិន្ទ្រិយ១ ទោមនស្សិន្ទ្រិយ១ ។

ដែលជាលោកុត្តរតែម្យ៉ាងមាន ៣ បានដល់ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយជាដើម ។

ដែលជាលោកិយផង និងជាលោកុត្តរៈផង បានដល់ ឥន្ទ្រិយ ៩ ដែលនៅសល់ គឺ ជីវិតិន្ទ្រិយ១ មនិន្ទ្រិយ១ សោមនស្សិន្ទ្រិយ១ ឧបេក្ខិន្ទ្រិយ១ សទ្ធិន្ទ្រិយ១ វីរិយិន្ទ្រិយ១ សតិន្ទ្រិយ១ សមាធិន្ទ្រិយ១ និងបញ្ញិន្ទ្រិយ១ ។

## អធិប្បាយ ពលៈ ៩

ធម៌ ៧ គឺ សទ្ធា ១ វីរិយៈ ១ សតិ ១ សមាធិ ១ បញ្ញា ១ ហិរិ ១ ឱត្តប្បៈ ១ ឈ្មោះថា ពលៈ ព្រោះ អត្ថថា មិនញាប់ញ័រចំពោះធម៌ដែលជាសត្រូវ ពោលគឺ ការ

មិនមានសទ្ធាការខ្ជិលច្រអូស ការប្រមាទ ការវេវវង់ ការមិនដឹង ការមិនខ្មាស និងការមិនខ្លាចបាប និងព្រោះជាធម៌តាំងមាំក្នុងសម្បយុត្តធម៌ទាំងឡាយ ។ ប៉ុន្តែ អហិរិកៈ និងអនោត្តប្បៈទាំងពីរនេះ ឈ្មោះថា ពលៈ ព្រោះជាធម៌ តាំងមាំក្នុងសម្បយុត្តធម៌តែម្យ៉ាង ។

**អង្គធម៌ ពលៈ ៩**

**១-សទ្ធាពលៈ** បានដល់ សទ្ធាចេតសិកនៅក្នុងសោភណចិត្ត ៩១ ។

**២-វីរិយពលៈ** បានដល់ វីរិយចេតសិកនៅក្នុងវីរិយសម្បយុត្តចិត្ត ១០៥ (វៀរអវីរិយចិត្ត ១៦) ។

**៣-សតិពលៈ** បានដល់ សតិចេតសិកនៅក្នុងសោភណចិត្ត ៩១ ។

**៤-សមាធិពលៈ** បានដល់ ឯកគ្គតាចេតសិកនៅក្នុងចិត្ត ១០៤ (វៀរអវីរិយ ចិត្ត ១៦ និងវិចិកិច្ឆាសម្បយុត្តចិត្ត ១) ។

**៥-បញ្ញាពលៈ** បានដល់ បញ្ញាចេតសិកនៅក្នុងញាណសម្បយុត្តចិត្ត ៧៩ (វៀរអសោភណចិត្ត ៣០ និងសោភណចិត្តដែលជាញាណវិប្បយុត្ត ១២) ។

**៦-ហិរិពលៈ** បានដល់ ហិរិចេតសិកនៅក្នុងសោភណចិត្ត ៩១ ។

**៧-ឱត្តប្បពលៈ** បានដល់ ឱត្តប្បចេតសិកនៅក្នុងសោភណចិត្ត ៩១ ។

**៨-អហិរិកពលៈ** បានដល់ អហិរិកចេតសិកនៅក្នុងអកុសលចិត្ត ១២ ។

**៩-អនោត្តប្បពលៈ** បានដល់ អនោត្តប្បចេតសិកនៅក្នុងអកុសលចិត្ត ១២ ។

## អធិប្បាយ អធិបតិ ៤

ធម៌ដែលជាធំជាងសម្បយុត្តធម៌ ដែលប្រព្រឹត្តទៅ

ព្រមជាមួយខ្លួន ឈ្មោះថា អធិបតី ។ ពិតមែន ធម៌ ៤ មាន ឆន្ទៈជាដើម ក្នុងចិត្តដែលកើតឡើង មាន ឧបនិស្សយប្បច្ច័យ ប្រជុំតាក់តែងពីខាងដើម មានជាដើមថា **"ដែលឈ្មោះថា អ្វី ៗ នឹងសម្រេចដល់មនុស្សអ្នកមានឆន្ទៈ"** ដូច្នេះ, ជាធុរៈ ជាធម៌ញ៉ាំងសម្បយុត្តធម៌ ឱ្យប្រព្រឹត្តទៅបាន សម្រេចដោយខ្លួនឯង, ក៏សម្បយុត្តធម៌ទាំងនោះ រមែង ប្រព្រឹត្តទៅបាន ដោយអំណាចនៃឆន្ទៈជាដើមទាំងនោះ ព្រោះ ហេតុនោះ ធម៌មានឆន្ទៈជាដើមនោះ ទើបប្រព្រឹត្តទៅដោយ ភាពជាធំជាងធម៌ដែលទាក់ទងជាមួយខ្លួន ។

អធិបតី ៤ មានឆន្ទៈជាដើមនេះ មិនជាអធិបតីព្រម គ្នាទេ គឺ ត្រឹមតែជាអធិបតីបានម្តងមួយ ៗ ប៉ុណ្ណោះ ។

អធិបតី ( អ្នកជាធំ ) និងឥន្ទ្រិយ ( ភាពជាធំ ) មាន សេចក្តីផ្សេងគ្នា គឺ អធិបតីនោះ ជាធំដោយអំណាចហាមភាព ជាអធិបតីធម៌ដទៃទៀត មិនឱ្យជាអធិបតីបាន, បានត្រឹមតែជា

ធម៌ញុំាងចក្ខុវិញ្ញាណជាដើម ឱ្យប្រព្រឹត្តទៅតាមកិច្ចរបស់ខ្លួន មានការឃើញជាដើមតែម្យ៉ាង ទើបឈ្មោះថា **អធិបតី** ។

ចំណែកឥន្ទ្រិយវិញ អាចមានឥន្ទ្រិយដទៃទៀតដែរ (មិនហាមឃាត់ ទើបត្រាស់ថា) ទើបឈ្មោះថា ឥន្ទ្រិយ ។

## អង្គធម៌អធិបតី ៤

**១-ឆន្ទាធិបតិ** បានដល់ ឆន្ទចេតសិកនៅក្នុងសាធិបតិជវនចិត្ត ៥២ គឺ

-ទ្វិហេតុកជវនចិត្ត ១៨ (លោភមូលចិត្ត ៨ ទោសមូលចិត្ត ២ មហាកុសលញាណវិប្បយុត្តចិត្ត ៤ មហាកិរិយាញាណវិប្បយុត្តចិត្ត ៤)

-តិហេតុកជវនចិត្ត ៣៤ (មហាកុសលញាណសម្បយុត្តចិត្ត ៤ មហាកិរិយាញាណសម្បយុត្តចិត្ត ៤ មហគ្គតជវនចិត្ត ១៨ និងលោកុត្តរចិត្ត ៨) ។

**២-វិរិយាធិបតិ** បានដល់ វិរិយចេតសិក នៅក្នុង

សាធិបតិជវនចិត្ត ៥២ នុ៎ះឯង ។

**៣-ចិត្តាធិបតិ** បានដល់ សាធិបតិជវនចិត្ត ៥២ ដូចគ្នា ។

**៤-វិមំសាធិបតិ** បានដល់ បញ្ញាចេតសិក ក្នុងតិហេតុកជវនចិត្ត ៣៤ ។

## អធិប្បាយ អាហារ ៤

ធម៌ពួកណា រមែងនាំមកនូវរូបមានឱជា ជាគម្រប់ ៨ ជាដើម ព្រោះហេតុនោះ ធម៌ទាំងនោះ ទើបឈ្មោះថា **អាហារ** ។

ពិតមែន កពឡិង្ការាហារ រមែងនាំមកនូវរូប មានឱជា ជាគម្រប់ ៨, ផស្សាហារ រមែងនាំមកនូវវេទនា ៣, កម្មដែលជាកុសល និងអកុសល ពោលគឺ មនោសញ្ចេតនាហារ រមែងនាំមកនូវបដិសន្ធិក្នុងភពទាំង ៣, បដិសន្ធិវិញ្ញាណ ពោលគឺ វិញ្ញាណាហារ រមែងនាំមកនូវនាម និងរូបដែល

កើតរួមគ្នា ។

សូម្បីពួកធម៌ដទៃទៀត មានវេទនាជាដើម នាំមកនូវបច្ចុប្បន្ន(ផល)របស់ខ្លួន ៗ ក៏ពិតមែនហើយ ប៉ុន្តែ ធម៌ ៤ នេះប៉ុណ្ណោះ ដែលត្រាស់ហៅថា អាហារ ព្រោះការបន្តខាងក្នុងជាបច្ច័យពិសេស ។

ពិតមែន កពឡិង្ការាហារ ជាបច្ច័យពិសេសដល់រូបកាយរបស់សត្វ អ្នកបរិភោគអាហារ ព្រោះរូបកាយនោះសូម្បីបច្ច័យទាំងឡាយ មានកម្មជាដើម នាំឱ្យកើតហើយ ក៏ប្រព្រឹត្តទៅបាន ១០ ឆ្នាំជាដើម ដោយកម្លាំងជួយឧបត្ថម្ភនៃកពឡិង្ការាហារនុ៎ះឯង ។ ពិតមែន អាចារ្យទាំងឡាយ ពោលថា កពឡិង្ការាហារនេះ ដូចមេនំ (អ្នកបំបៅដោះ) បីពរក្មេងតូច ឬដូចសសរជួយទល់ផ្ទះទុក ។

សូម្បីផស្សៈកាលប៉ះខ្ទប់អារម្មណ៍ ដែលជាទីតាំងនៃវេទនា មានសុខជាដើមនុ៎ះឯង ក៏ដើម្បីការតាំងនៅនៃសត្វទាំង

ឡាយ ដោយការប្រព្រឹត្តទៅនៃសុខវេទនាជាដើម ។ មនោសញ្ចេតនាហារ ប្រមូលមកដោយអំណាចនៃកម្មដែលជាកុសល និងអកុសលទាំងឯង រមែងមានដើម្បីការតាំងនៅនៃសត្វទាំងឡាយ ព្រោះញុំាងមូលនៃភពឱ្យសម្រេច ។ វិញ្ញាណដឹងច្បាស់អារម្មណ៍ទាំងឯង រមែងជាបច្ច័យដល់ការតាំងនៅរបស់សត្វទាំងឡាយ ដោយការប្រព្រឹត្តទៅនៃនាម និងរូប, ធម៌ ៤ នេះឯង ព្រះមានព្រះភាគត្រាស់ ហៅថា អាហារ ព្រោះជាបច្ច័យវិសេសដល់ការប្រព្រឹត្តទៅខាងក្នុងសន្តាន ដោយប្រការដូច្នេះ ។

## អង្គធម៌អាហារ ៤

១-កពឡិង្ការាហារ បានដល់ ឱជានៅក្នុងអាហារផ្សេង ៗ ។

២-ផស្សាហារ បានដល់ ផស្សចេតសិកនៅក្នុងចិត្តទាំងអស់ ។

៣-មនោសញ្ចេតនាហារ បានដល់ ចេតនាចេតសិកនៅក្នុងចិត្តទាំងអស់ ។

៤-វិញ្ញាណាហារ បានដល់ ចិត្តទាំងអស់ ។

## ធម៌ដែលមិនមែនជាអង្គឈាន

ពាក្យថា "អង្គឈាន មិនមានទៅក្នុងបញ្ចវិញ្ញាណ, ពលៈ មិនមានទៅក្នុងពួកអវីរិយៈ, អង្គមគ្គ មិនមានទៅក្នុងពួកអហេតុកៈ"ជាដើម ។

<u>ក្នុងអភិធម្មត្ថវិភាវិនី</u> បរិយាយពង្រីកសេចក្តីទុកថា ៖

"ឧបេក្ខា សុខ និងទុក្ខ, សូម្បីមានទៅក្នុងបញ្ចវិញ្ញាណទាំងនោះ ព្រះមានព្រះភាគទ្រង់មិនលើកឡើង ជាអង្គឈានទេ ព្រោះមិនមានអាការ គឺ ចូលទៅសម្លឹង ព្រោះបញ្ចវិញ្ញាណ ជាធម៌ត្រឹមតែធ្លាក់ទៅក្នុងអារម្មណ៍ ដោយវៀរចាកវិតក្កៈ, ដែលពិតនោះ ព្រះមានព្រះភាគត្រាស់ថា អង្គឈានមានវិតក្កៈកើតខាងក្រោយ ។ **សមាធិ** (ឯកគ្គតា) **សូម្បីមានទៅក្នុងអវីរិយចិត្ត ១៦ នោះ ក៏មិនដល់ភាពជាពលៈ** ព្រោះមិនមានសេចក្តីព្យាយាម ក្នុងចិត្ត ១៦ ដោយអំណាចនៃ

ទ្វិបញ្ចវិញ្ញាណ ១០ មនោធាតុ ៣ និងសន្តីរណចិត្ត ៣ ព្រោះត្រាស់ថា ពលៈ មានសេចក្តីព្យាយាមកើតខាងក្រោយ ។

ម្យ៉ាងទៀត ក្នុងពួកអហេតុកចិត្ត ១៨ រមែងមិនមាន មគ្គង្គៈ ព្រោះវៀរចាកហេតុ ។ ពិតមែន ព្រះមានព្រះភាគ ត្រាស់ថា "អង្គមគ្គ មានហេតុកើតខាងក្រោយ" ដូច្នេះ ។ ឯកគ្គតា ក្នុងចិត្តដែលសម្បយុត្តដោយវិចិកិច្ឆា ត្រឹមតែជាការ ឈប់នៃចិត្ត ព្រោះវៀរចាកអធិមោក្ខៈ មិនហៅថា មិច្ឆា សមាធិ សមាធិន្ទ្រិយ និងសមាធិពលៈ ។ លោកអាចារ្យ សម្តែងការមិនមានអធិបតីនៅក្នុងពួកចិត្តដែលមានហេតុតែ មួយ ដោយសព្ទថា ទ្វិហេតុកៈ និងតិហេតុកៈ ការកំណត់ថា ក្នុងទ្វិហេតុកៈ និងតិហេតុកៈនេះ លោកពោលទុកដើម្បីសម្តែង ថា **អធិបតី** មិនមានការកើតក្នុងពួកចិត្តដែលជាលោកិយ វិបាក ។ លោកអាចារ្យសំដៅយកអធិបតី គឺ វីមំសា មិន កើតក្នុងពួកទ្វិហេតុកជវនចិត្ត ទើបពោលថា "តាមសមគួរ ដល់ការកើត" ។

បណ្ឌិត រមែងបានអធិបតីធម៌ត្រឹមតែម្យ៉ាងប៉ុណ្ណោះ ព្រោះកាលមាន ២-៣ យ៉ាង ក៏មិនជាអធិបតី គឺ ជាអធិបតីបានត្រឹមតែមួយយ៉ាង ក៏ព្រោះហេតុនេះឯង ទើបព្រះមានព្រះភាគ មិនត្រាស់ដោយន័យជាដើមថា "អធិបតីជាបច្ច័យដល់ធម៌ ដែលសម្បយុត្តដោយអធិបតី ដោយអំណាចអធិបតី ដូចក្នុងនិទ្ទេសនៃហេតុប្បច្ច័យ ដូច្នោះ" ត្រាស់អធិបតិប្បច្ច័យឡើង ដោយអំណាចអធិបតីនីមួយ ៗតែម្យ៉ាង ដោយន័យជាដើមថា ឆន្ទាធិបតី ជាបច្ច័យដល់ធម៌ ដែលសម្បយុត្ត ដោយឆន្ទៈ ដូច្នេះ ។

## មិស្សកៈ មានសភាវៈ ៥៣

ពោលដោយសភាវៈ ហេតុធម៌ មាន ៦, ឈានធម៌មាន ៥ ព្រោះរួមសោមនស្ស ទោមនស្ស ឧបេក្ខា ចូលក្នុងឋានតែមួយ ដោយអំណាចនៃវេទនា, អង្គមគ្គមាន ៩ ព្រោះរួមមិច្ឆាសង្កប្បៈ មិច្ឆាវាយាមៈ មិច្ឆាសមាធិ ចូលក្នុងឋានជា

មួយ នឹងសម្មាសង្កប្បៈ សម្មាវាយាមៈ ចិត្តេកគ្គតា ដោយជាសភាគៈ, ឥន្ទ្រិយធម៌មាន ១៦ ព្រោះវេទនា ៥ ចូលក្នុងឋានតែមួយជាមួយគ្នា និងព្រោះរួមឥន្ទ្រិយជាលោកុត្តរ ៣ ចូលជាមួយនឹងបញ្ញិន្ទ្រិយ ទុកក្នុងឋានតែមួយរួមគ្នា និងព្រោះកាន់យករូបជីវិតិន្ទ្រិយ និងអរូបជីវិតិន្ទ្រិយទុក (ក្នុងរូបនិងអរូប) មួយផ្នែក ៗ ចំណែកពលៈ ព្រះមានព្រះភាគត្រាស់ទុក ៩ ដោយន័យដែលពោលហើយ, អធិបតីត្រាស់ទុក ៤ និងអាហារត្រាស់ទុក ៤ ដូចគ្នា ។

មិស្សកសង្គហៈ មាន ៧ ឋាន ដោយប្រការដូច្នេះ ។

ក៏បណ្ដាសភាវៈ មានហេតុជាដើម លោកដីកាចារ្យពោលគាថា សង្ខេបសង្គ្រោះធម៌ទុកក្នុងឋាន ដូច្នេះ គឺ ៖

- **បញ្ញា** សង្គ្រោះបាន ៥ ឋាន
- **វាយាមៈ** និង **ឯកគ្គតា** សង្គ្រោះបាន ៤ ឋាន,
- **ចិត្ត** និង **សតិ** សង្គ្រោះបាន ៣ ឋាន,

- **សង្កប្បៈ វេទនា សទ្ធា** សង្គ្រោះទុក ២ ឋាន,
- **ធម៌នៅសល់ ២៨** សង្គ្រោះឋានបាន ១ ឋាន ។

**សង្គ្រោះធម៌ចូលក្នុងឋាន ៧ គឺ**

-បញ្ញា សង្គ្រោះបាន ៥ ឋាន គឺ ហេតុ ១ អង្គមគ្គ ១ ឥន្ទ្រិយ ១ ពលៈ ១ អធិបតី ១

-វាយាមៈ គឺ វិរិយៈ សង្គ្រោះបាន ៤ ឋាន គឺ អង្គមគ្គ១ ឥន្ទ្រិយ១ ពលៈ១ អធិបតី១

-ឯកគ្គតា សង្គ្រោះបាន ៤ ឋាន គឺ ឈាន១ មគ្គ១ ឥន្ទ្រិយ ១ ពលៈ ១

-ចិត្ត សង្គ្រោះបាន ៣ឋាន គឺ ឥន្ទ្រិយ១ អធិបតី១ អាហារ១

-សតិ សង្គ្រោះបាន ៣ ឋាន គឺ មគ្គ១ ឥន្ទ្រិយ១ ពលៈ១

-សង្កប្បៈ គឺ វិតក្កៈ សង្គ្រោះបាន ២ឋាន គឺ ឈាន១ មគ្គ១

-វេទនា សង្គ្រោះបាន ២ ឋាន គឺ ឈាន ១ ឥន្ទ្រិយ ១

-សទ្ធា សង្គ្រោះបាន ២ ឋាន គឺ ឥន្ទ្រិយ ១ ពលៈ ១

## ធម៌តាំងនៅក្នុងឋានមួយដែលជាពួករបស់ខ្លួនមាន ២៨

១-ហេតុ ៥ (វៀរអមោហៈ)

២-អង្គឈាន ២ គឺ វិចារៈ បីតិ

៣-អង្គមគ្គ ៤ គឺ វិរតិ ៣ ទិដ្ឋិ ១

៤-ឥន្ទ្រិយ ៩ គឺ ប្រសាទ៥ ភាវៈ២ ជីវិត២

៥-ពលៈ ៤ គឺ ហិរិ ឱត្តប្បៈ អហិរិកៈ អនោត្តប្បៈ

៦-អធិបតិ ១ គឺ ឆន្ទៈ

៧-អាហារ ៣ គឺ កពឡិង្ការាហារ ផស្សៈ ចេតនា ។

ធម៌ទាំងនេះ ដែលឈ្មោះថា តាំងនៅក្នុងឋានតែមួយ គឺ តាំងនៅក្នុងឋានរបស់ខ្លួននោះឯង ។

**ចប់ មិស្សកសង្គហៈ ពួកទី ២**

## សំនួរ-ចម្លើយក្នុងមិស្សកសង្គហៈ

១- សំ. ក្នុងមិស្សកសង្គហៈនោះ មានធម៌ប៉ុន្មានពួក ? អ្វីខ្លះ ? រួមទាំងអស់មានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?

ចំ. ក្នុងមិស្សកសង្គហៈនោះ មានធម៌ ៧ ពួក គឺ

១.ហេតុ ២.អង្គឈាន ៣.អង្គមគ្គ ៤.ឥន្ទ្រិយ

៥.ពលៈ ៦.អធិបតី ៧.អាហារ ។

រួមទាំងអស់មាន ៦៣ប្រភេទ គឺ ហេតុ៦ អង្គឈាន៧ អង្គមគ្គ១២ ឥន្ទ្រិយ២២ ពលៈ៩ អធិបតី៤ អាហារ៤ ។

២- សំ. ចូរសម្តែងសេចក្តីសំដៅ និងអង្គធម៌របស់ធម៌ ដូចតទៅនេះ ហេតុ៦ អង្គឈាន៧ អង្គមគ្គ១២

ចំ. សេចក្តីសំដៅ និងអង្គធម៌របស់ធម៌នេះ មានដូច្នេះគឺ

ហេតុ មាន ៦ ។ល ។

អង្គឈាន មាន ៧ ។ល ។

អង្គមគ្គ មាន ១២ ។ល ។

៣- សំ. ចូរចែកឥន្ទ្រិយ២២ ដោយចិត្ត ចេតសិក រូប និង សេចក្តីសំដៅរបស់ឥន្ទ្រិយទាំង២២ នោះ ដោយចំពោះ ៗ

ចំ. ក្នុងឥន្ទ្រិយ២២ នោះ មានដូច្នេះ គឺ

+ ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ រួម៧ នេះ ជារូប ។

+ ជីវិតិន្ទ្រិយ ជាចេតសិក និងរូប ។

+ មនិន្ទ្រិយ ជាចិត្ត ។

+ សុខិន្ទ្រិយ ទុក្ខិន្ទ្រិយសោមនស្សិន្ទ្រិយ ទោមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយសទ្ធិន្ទ្រិយ វិរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ អនញ្ញាតញ្ញស្សាមិន្ទ្រិយ អញ្ញិន្ទ្រិយ អញ្ញាតាវិន្ទ្រិយ រួម ១៣ ជាចេតសិក ។

សេចក្តីសំដៅរបស់ឥន្ទ្រិយទាំង២២ ដោយចំពោះ ៗ គឺ

១. ចក្ខុន្ទ្រិយ សំដៅសេចក្តីថា ធម្មជាតិដែលជាអ្នកគ្រប់គ្រងក្នុងការឃើញ ។ល ។

២២. អញ្ញាតាវិន្ទ្រិយ សំដៅសេចក្តីថា ធម្មជាតិដែលជាអ្នកគ្រប់គ្រង ក្នុងការដឹងច្បាស់នូវអរិយសច្ចៈ ៤ ទាំងអស់ហើយ

៤_ សំ. ចូរចែកពលធម៌ ៩ ដោយសោភណៈ និង អសោភណៈ ព្រមទាំងសម្តែងសេចក្តីសំដៅ របស់ពលៈនោះ ៗផង និងសម្តែងអគ្គធម៌របស់អធិបតី៤ និងអាហារ៤ តាមលំដាប់

ចំ. ចែកពលធម៌ ៩ ដោយសោភណៈ និង អសោភណៈ មានដូច្នេះ គឺ

+ សទ្ធាពលៈ សតិពលៈ បញ្ញាពលៈ ហិរិពលៈ ឱត្តប្បពលៈ ទាំង៥នេះ ជាសោភណៈ

+ អហិរិពលៈ អនោត្តប្បពលៈ ទាំង២នេះ ជាអសោភណៈ

+ វិរិយពលៈ សមាធិ ទាំង២នេះ ជាសោភណៈផង ជាអសោភណៈផង សម្តែងសេចក្តីសំដៅរបស់ពលៈនោះ មានដូច្នេះ គឺ

១. សទ្ធាពល: សំដៅសេចក្តីថា ធម្មជាតិដែលមិន ញាប់ញ័រក្នុងការជឿចំពោះវត្ថុដែលគួរជឿ ។ល ។

៩. អនោត្តប្បពល: សំដៅសេចក្តីថា ធម្មជាតិដែល មិនញាប់ញ័រក្នុងការមិនភ័យតក់ស្លុត ចំពោះទុច្ចរិត ។

សម្តែងអង្គធម៌របស់អធិបតី៤ តាមលំដាប់

**១.ឆន្ទាធិបតិ** អង្គធម៌បានដល់ ឆន្ទចេតសិក

**២.វីរិយាធិបតិ** អង្គធម៌បានដល់ វីរិយចេតសិក

**៣.ចិត្តាធិបតិ** អង្គធម៌បានដល់ សាធិបតិជវនចិត្ត

**៤.វិមំសាធិបតិ** អង្គធម៌បានដល់ បញ្ញាចេតសិក

## សម្តែងអង្គធម៌របស់អាហារ ៤ តាមលំដាប់

១. កវឡីង្ការាហារ បានដល់ ឱជា នៅក្នុងអាហារផ្សេង ៗ ។

២. ផស្សាហារ បានដល់ ផស្សចេតសិក នៅក្នុងចិត្តទាំងអស់ ។

៣. មនោសញ្ចេតនាហារ បានដល់ ចេតនាចេតសិក នៅក្នុងចិត្តទាំងអស់ ។

៤. វិញ្ញាណាហារ បានដល់ ចិត្តទាំងអស់ ។

៥_ សំ. ចេតសិកណាខ្លះ ដែលប្រកបជាមួយចិត្តពួក ខ្លះ ហើយជាអង្គឈាន អង្គមគ្គ ឥន្ទ្រិយ ពលៈ មិនបាន ? ចូរសម្តែងឈ្មោះរបស់ចិត្តទាំងនោះ ព្រមទាំងលើកគោល អាងមកផង

ចំ. ចេតសិកខ្លះ ដែលប្រកបជាមួយចិត្តពួកខ្លះ ហើយតែជាអង្គឈាន អង្គមគ្គ ឥន្ទ្រិយ ពលៈ មិនបាននោះ បានដល់

ក. វេទនាចេតសិក ឯកគ្គតាចេតសិក ដែលនៅក្នុងទ្វិបញ្ចវិញ្ញាណ ១០ ជាអង្គឈានមិនបាន

ខ. ឯកគ្គតាចេតសិក ដែលនៅក្នុងអហេតុកចិត្ត១៨ ជាអង្គមគ្គមិនបាន, នៅក្នុងអវីរិយចិត្ត ១៦ ជាសមាធិន្ទ្រិយនិងសមាធិពលៈ មិនបាន, នៅក្នុងវិចិកិច្ឆាសម្បយុត្តចិត្តជា

មិច្ឆាសមាធិ សមាធិន្ទ្រិយ និងសមាធិពលៈ មិនបាន,

គ. វិតក្កចេតសិក ដែលនៅក្នុងអហេតុកចិត្ត៨ (វៀរទ្វិបញ្ចវិញ្ញាណ ១០ ជាអង្គមគ្គមិនបាន

ឃ. វិរិយចេតសិក ដែលនៅក្នុងហសិតុប្បាទចិត្ត១ មនោទ្វារាវជ្ជនចិត្ត១ ជាអង្គមគ្គមិនបាន

ដូចមានបាលីសម្ដែងថា បញ្ចវិញ្ញាណេសុ ឈានង្គានិ អហេតុកេសុ មគ្គង្គានិ ន លព្ភន្តិ តថា អវីរិយេសុ ឯកគ្គតា ឥន្ទ្រិយពលភាវំ ន គច្ឆតិ វិចិកិច្ឆាចិត្តេ បន មគ្គភាវំ បិ : ក្នុងទ្វិបញ្ចវិញ្ញាណ ១០ រមែងមិនជាអង្គឈាន ក្នុងអហេតុកចិត្ត១៨ មិនជាអង្គមគ្គ, ឯកគ្គតាចេតសិកនៅក្នុងអវិរិយចិត្ត១៦ មិនជាសមាធិន្ទ្រិយ និងសមាធិពលៈ, ឯកគ្គតាចេតសិក នៅក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត១ មិនជាមិច្ឆាសមាធិ សមាធិន្ទ្រិយ និងសមាធិពលៈទេ, ។

២១៦-សំ. គាថាដែលសម្ដែងធម៌ក្នុងមិស្សកសង្គហៈ

ទាំង៧ ពួកនោះ សម្តែងយ៉ាងណា ? មានសេចក្តីប្រែយ៉ាង ណា ?

ចំ. គាថាដែលសម្តែងធម៌ក្នុងមិស្សកសង្គហៈ ទាំង៧ ពួកនោះ ដូច្នេះ

**៤. ឆ ហេតូ បញ្ច ឈានង្គា ។ល ។**

**៥. ចត្តារោធិបតី វុត្តា ។ល ។**

មានសេចក្តីប្រែ ដូច្នេះ

១. ហេតុពោលដោយអង្គបរមត្ថហើយ មាន ៦ ។ល ។

២. អធិបតី ពោលដោយអង្គបរមត្ថហើយ មាន៤ ។ល ។

៧- សំ. ចូរសម្តែងវចនត្ថៈ របស់បទដូចតទៅនេះ

១.មិស្សកសង្គហៈ ២.ហេតុ ៣.អង្គឈាន ៤.អង្គមគ្គ ៥.ឥន្ទ្រិយ ៦.ពលៈ ៧.អធិបតី ៨.អាហារ

ចំ. មានវចនត្ថៈ ដូចតទៅនេះ

១. ពាក្យថា មិស្សកសង្គហៈ

កុសលាកុសលាព្យាកតមិស្សកានំ ហេតុឆក្កាទីនំ សង្គហោតិ = មិស្សកសង្គហោ : ពួកដែលសង្គ្រោះសភាវធម៌ ផ្សេងៗមានហេតុ៦ជាដើម ដែលជាកុសល អកុសល អព្យាកត លាយចូលគ្នា ដូច្នោះ ទើបឈ្មោះថា មិស្សកសង្គហៈ ។

២. ពាក្យថា ហេតុ

ហិនោតិ វត្តតិ ផលំ ឯតេហិ ឥតិ ហេតវោ
លទ្ធហេតូ តេ ជិវា រុឡ្ហមូលាវ បាទបា ។

ផលរមែងកើតព្រោះធម៌ទាំងនេះ ដូច្នោះ ធម៌ពួកនេះ ទើបឈ្មោះថា ហេតុ សំដៅសេចក្តីថា ធម៌ទាំងឡាយដែល បានទទួលឧបការអំពីហេតុ រមែងមានសភាពមាំទាំក្នុងអារម្មណ៍ ដូចដើមឈើ ដែលមានឫសដុះល្អបែកសាយទៅ ដូច្នោះ ។

៣. ពាក្យថា អគ្គឈាន

អាលម្ពមុបនិជ្ឈន្តិ ឥតិឈានានិ វុច្ចរេ
ឈានបេន្តិ វា បច្ចនីកេ ឥតិបិ ឈានសញ្ញិតា

ធម៌ពួកណា រមែងចូលទៅសំឡឹងអារម្មណ៍ មានកសិណជាដើម ដូច្នោះ ធម៌ពួកនោះ ទើបឈ្មោះថា ឈាន ឬធម៌ពួកណា រមែងដុតនូវធម៌ ដែលជាបដិបក្ខចំពោះគ្នា ដូច្នោះ ធម៌ពួកនោះ ទើបឈ្មោះថា ឈាន បានដល់ អង្គឈាន៧ ។

៤. ពាក្យថា អង្គមគ្គ

សុគត្យា ច ទុគ្គត្យា ច និព្វានស្ស ច បាបណា
តេសញ្ច បថភូតត្តា មគ្គង្គានីតិ វុច្ចរេ
មគ្គស្ស វា អង្គានីតិ មគ្គង្គានីតិ សម្មតា ។

អង្គធម៌ ៩ លោកពោលថា ជាអង្គមគ្គ ព្រោះជាហេតុឱ្យដល់សុគតិភូមិ ទុគ្គតិភូមិ និងព្រះនិព្វាន និងជាផ្លូវឱ្យដល់សុគតិភូមិ ទុគ្គតិភូមិ

និងព្រះនិព្វាន អង្គធម៌៩ លោកពោលថា ជាអង្គមគ្គ ព្រោះជាចំណែកមួយ ៗ របស់អង្គមគ្គ ។

៥. ពាក្យថា ឥន្ទ្រិយ

ឥន្ទន្តិ បរមិស្សរិយំ ករោន្តីតិ = ឥន្ទ្រិយានិ ធម៌ពួកណាជាអ្នកគ្រប់គ្រង គឺ រមែងធ្វើឱ្យខ្លួនជាឥស្សរដ៏ក្រៃលែង ដូច្នោះ ធម៌ពួកនោះ ទើបឈ្មោះថា ឥន្ទ្រិយ ។

៦. ពាក្យថា ពលៈ

ពលីយន្តិ ឧប្បន្នេ បដិបក្ខធម្មេ សហន្តិ មទ្ទន្តីតិ = ពលានិ ធម៌ពួកណា រមែងមានកម្លាំងសង្កត់នូវបដិបក្ខធម៌ដែលកើតឡើងហើយ និងមានសេចក្តីអត់ធន់តស៊ូទំលាយនូវបដិបក្ខធម៌នោះ ដូច្នោះ ធម៌ពួកនោះ ឈ្មោះថា ពលៈ ។

៧. ពាក្យថា អធិបតី

អធិឆាធំ បតិ = អធិបតិ ធម៌ដែលជាម្ចាស់នៃធម៌ ដែលកើតជាមួយគ្នានឹងខ្លួន ឬធម៌ ដែលជាធំជាងធម៌ ដែលកើតជាមួយគ្នានឹងខ្លួន ដូច្នោះ ធម៌ពួកនោះ ឈ្មោះថា អធិបតី ។ ន័យមួយទៀត អធិកោ បតិ = អធិបតិ ធម៌ដែលជាម្ចាស់ មានអំណាចក្រៃលែង ឬធម៌ដែលជាធំមានអំណាចក្រៃលែង ឈ្មោះថា អធិបតី ។

៨. ពាក្យថា អាហារ

អាហរន្តីតិ = អាហារា ធម៌ពួកណា រមែងនាំមកនូវធម៌ ដែលជាផលរបស់ខ្លួន ៗ ដូច្នោះ ធម៌ពួកនោះ ឈ្មោះថា អាហារ ។

៨- សំ.ពាក្យថា ឈាន មានសេចក្តីយ៉ាងណា ? និងធម៌ ដែលជាបដិបក្ខចំពោះអង្គឈាននោះ មានអ្វីខ្លះ ?

ចំ. ពាក្យថា ឈាន មានសេចក្តីថា ការចូលទៅសំឡឹងអារម្មណ៍ មានទីលកសិណជាដើម ឬដុតធម៌ដែលជា

បដិបក្ខចំពោះខ្លួន ដូច្នោះ ទើបឈ្មោះថា ឈាន និងធម៌ដែលជាបដិបក្ខចំពោះអង្គឈាននោះ គឺ

១. ថីនមិទ្ធៈ ជាបដិបក្ខចំពោះវិតក្កៈ

២. វិចិកិច្ឆា ជាបដិបក្ខចំពោះវិចារៈ

៣. ព្យាបាទៈ ជាបដិបក្ខចំពោះបីតិ

៤. កាមឆន្ទៈ ជាបដិបក្ខចំពោះឯកគ្គតា

៥. ឧទ្ធច្ចកុក្កុច្ចៈ និងទោមនស្សវេទនា ជាបដិបក្ខចំពោះសោមនស្សវេទនា និងឧបេក្ខាវេទនា

៦. បីតិ និង សោមនស្សវេទនា ជាបដិបក្ខចំពោះទោមនស្សវេទនា ។

៩- សំ. ចូរអធិប្បាយអង្គធម៌ទាំង ៩ មានបញ្ញាជាដើម ដែលបានឈ្មោះថា មគ្គ និងព្រះពុទ្ធទ្រង់សម្តែងផ្លូវដែល ចេញចាកអង្គមគ្គ ១២ មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ? ជាអង្គធម៌ អ្វីខ្លះ ?

ចំ. អង្គធម៌ ៩ មានបញ្ញាជាដើម ដែលបានឈ្មោះថា

មគ្គ ព្រោះធម្មតាសត្វទាំងឡាយ ដែលវិលវល់កើតស្លាប់ ក្នុងភូមិ ៣១ ភូមិ និងដែលចូលដល់និព្វានបាននោះ រមែងត្រូវអាស្រ័យមានហេតុ មានផ្លូវដែលជួយជ្រោមជ្រែងឱ្យដល់ធម៌ដែលជាហេតុ ជាផ្លូវឱ្យដល់ភូមិផ្សេង ៗ និងនិព្វាននោះ ក៏បានដល់ អង្គមគ្គ ១២ មានសម្មាទិដ្ឋិជាដើមនោះឯង ។

និងព្រះពុទ្ធទ្រង់សម្តែងផ្លូវដែលផ្ទុយពីអង្គមគ្គ ១២ មាន ៤ យ៉ាង គឺ មិច្ឆាវាចា មិច្ឆាកម្មន្ត មិច្ឆាអាជីវៈ មិច្ឆាសតិ មានអង្គធម៌ដូច្នេះ គឺ

មិច្ឆាវាចា បានដល់ អកុសលចិត្តុប្បាទដែលជាប់ ទាក់ទងដោយវចីទុច្ចរិត

មិច្ឆាកម្មន្ត បានដល់ អកុសលចិត្តុប្បាទដែលជាប់ ទាក់ទងដោយកាយទុច្ចរិត

មិច្ឆាអាជីវៈ បានដល់ អកុសលចិត្តុប្បាទដែលជាប់ ទាក់ទងដោយការចិញ្ចឹមជីវិតខុស

មិច្ឆាសតិ បានដល់ អកុសលចិត្តុប្បាទដែលមាន

សញ្ញាជាប្រធាន ក្នុងការរលឹកដល់វត្ថុ
ដែលមិនល្អផ្សេង ៗនោះឯង

១០- សំ. ចូរបរិយាយក្នុងពាក្យថា ឥន្ទ្រិយ ដោយសង្ខេប ព្រមទាំងចែកដោយភូមិផ្សេង ៗ

ចំ. បរិយាយក្នុងពាក្យថា ឥន្ទ្រិយ ដោយសង្ខេបដូច្នេះ

ពាក្យថា ឥន្ទ្រិយ ប្រែថា អ្នកគ្រប់គ្រង សេចក្តីថា អាចធ្វើឱ្យសភាវធម៌ ដែលកើតព្រមគ្នានឹងខ្លួននោះ ប្រព្រឹត្តទៅតាមអំណាចរបស់ខ្លួន ដូច ។ល ។ គឺធ្វើឱ្យសភាវធម៌ដែលកើតជាប់ជាមួយនឹងខ្លួននោះ ឱ្យប្រព្រឹត្តទៅតាមអំណាចរបស់ខ្លួន ។

ចែកដោយភូមិផ្សេង ៗ

១. ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ។ល ។

២. ជីវិតិន្ទ្រិយ មនិន្ទ្រិយ ។ល ។

៣. សោមនស្សិន្ទ្រិយ ជាកាមធម៌ ។ល ។

៤. អនញ្ញាតញ្ញស្សាមិន្ទ្រិយ ។ល ។

១១- សំ. ពាក្យថា ពលៈ មានន័យថា មិនញាប់ញ័រ ទាំងមានកម្លាំងអត់ធន់ញាំញីទំលាយបដិបក្ខធម៌បាន តើមិនញាប់ញ័រយ៉ាងណា ? តើមានកម្លាំងអត់ធន់ញាំញីទំលាយបដិបក្ខធម៌បានយ៉ាងណា ? ចូរអធិប្បាយ និងលើកនូវបាលីមក ពោលផង

ចំ. ពាក្យថា ពលៈ មានន័យថា មិនញាប់ញ័រ ទាំងមានកម្លាំង អត់ធន់ ញាំញី ទំលាយនូវបដិបក្ខធម៌បាននោះ អធិប្បាយថា ការមិនញាប់ញ័រ មាន ២ យ៉ាង គឺ នាយពលខ្លះ មិនញាប់ញ័រក្នុងនាទីរបស់ខ្លួន ។ល ។ ដូច្នេះជាដើម ប្រការមួយ, នាយពលខ្លះ មិនញាប់ញ័រក្នុងនាទីរបស់ខ្លួន ។ល ។ ដូច្នេះជាដើម ប្រការមួយ, ដូចមានបាលីជាសាធកៈថា អសទ្ធិយេ គោសជ្ជេ ច ។ល ។ អបុញ្ញាបិ តំ ឆាមិកា

១២- សំ. ចូរសម្តែងវចនត្ថៈ ក្នុងពាក្យថា អធិបតី

និង ធម៌ដែលជាអធិបតីបាននោះ នៅក្នុងជវនៈប្រភេទណា ? ចូរលើកបាលីជាសាធកៈសម្តែងផង

ចំ. ពាក្យថា អធិបតី មានវចនត្ថៈថា អធិដានំ បតិ = អធិបតិ ធម៌ដែលជាម្ចាស់នៃធម៌ ដែលកើតជាមួយគ្នានឹងខ្លួន ឬធម៌ ដែលជាធំជាងធម៌ដែលកើតជាមួយគ្នានឹងខ្លួន ដូច្នោះ ធម៌ពួកនោះ ឈ្មោះថា អធិបតី ។ ឬន័យមួយទៀត អធិកោ បតិ = អធិបតិ ធម៌ដែលជាម្ចាស់មានអំណាចក្រៃលែង ឬ ធម៌ដែលជាធំមានអំណាចក្រៃលែង ឈ្មោះថា អធិបតី ។

ធម៌ដែលជាអធិបតីបាននោះ ត្រូវនៅក្នុងជវនៈប្រភេទ ដែលជាទ្វិហេតុកជវន ឬតិហេតុកជវនប៉ុណ្ណោះ ដូចមានបាលី ជាសាធកៈសម្តែងថា

ទ្វិហេតុកតិហេតុកជវនេស្វេវ យថាសម្ភវំ អធិបតិ ឯកោវ លព្ភតិ ប្រែថា ក្នុងទ្វិហេតុកជវនៈ និងតិហេតុកជវនៈប៉ុណ្ណោះ ដែលមានអធិបតីតែម្យ៉ាង ក្នុងចំនួនអធិបតី៤ នោះ តាម

ដែលទើងកើតបាន ។

១៣- សំ. ចូរសម្តែងសេចក្តីផ្សេងគ្នារវាងភាពជាធំ ជាអ្នក គ្រប់គ្រងរបស់ឥន្ទ្រិយ ហើយនឹងភាពជាធំ ជាអ្នក គ្រប់គ្រង របស់អធិបតី ឱ្យបានល្អិតល្អន់

ចំ. សេចក្តីផ្សេងគ្នារវាងភាពជាធំ ជាអ្នកគ្រប់គ្រងរបស់ឥន្ទ្រិយ ហើយនឹងភាពជាធំ ជាអ្នកគ្រប់គ្រងរបស់អធិបតីនោះ មានដូច្នេះ គឺ ភាពជាធំ ជាអ្នកគ្រប់គ្រងរបស់ឥន្ទ្រិយនេះ កាលដែលកើតឡើងនោះ រមែងកើតឡើងព្រមគ្នាក្នុងគ្រាតែមួយ បានច្រើនឥន្ទ្រិយ ដោយមិនជំទាស់គ្នា, ឯអធិបតីបាន ត្រឹមតែមួយប៉ុណ្ណោះ មិនអាចរួមគ្នាបានច្រើន ដូចឥន្ទ្រិយទេ (កើតរួមមែនតែមិនធ្វើកិច្ចជាអធិបតី២. ៣.ទេ) ។

១៤- សំ. លោកពោលថា ធម៌ណាដែលនាំមកនូវផលរបស់ខ្លួន ធម៌នោះឈ្មោះថា អាហារ, តើនាំមកយ៉ាងណា ? ចូរអធិប្បាយ និងសម្តែងដល់ការនាំមករបស់អាហារទាំង៤ ព្រមទាំងលើកសាធកបាលីមកសម្តែងផង

ចំ. ពាក្យថា នាំមក ក្នុងទីនេះ មានន័យថា ធ្វើឱ្យកើតផលឡើង និងជួយជ្រោមជ្រែងឱ្យតាំងនៅបាន ឱ្យចម្រើនឡើងបាន, ដូចដែលបានពោលមកថា ការងារទាំងនោះតាំងឡើងបាន ចម្រើនឡើងបាន ដោយអាស្រ័យអ្នកចាត់ចែងការ បើខ្វះអ្នកចាត់ចែងហើយ កិច្ចការនោះ ៗ នឹងចម្រើនឡើងមិនបាន, សេចក្តីនេះយ៉ាងណា ការរស់នៅរបស់សត្វទាំងឡាយក៏ដូចគ្នា និងការនាំមករបស់អាហារទាំង៤ មានដូច្នេះ គឺ

១. កវឡីង្ការាហារ នាំមកនូវអាហារជសុទ្ធដ្ឋកកលាប ឱ្យកើតក្នុងសន្តានរបស់សត្វទាំងឡាយ

២. ផស្សាហារ នាំមកនូវវេទនា គឺ ការសោយអារម្មណ៍ ដែលជាសុខខ្លះ ជាទុក្ខខ្លះ ជាកណ្តាល ៗខ្លះ ។

៣. មនោសញ្ចេតនាហារ នាំមកនូវបដិសន្ធិវិញ្ញាណ គឺ ការកើតជាមនុស្ស ទេវតា ព្រហ្ម អបាយសត្វ និង បវត្តិវិញ្ញាណ គឺការឃើញ ការឮជាដើម ។

៤. វិញ្ញាណាហារ នាំមកនូវចេតសិក និងកម្មជរូប ។

ដូចមានសាធកបាលីមកសម្ដែងថា

ឱជដ្ឋមករូបំ ហិ　　វេទនំ បដិសន្ធិកំ

នាមរូបំ អាហរន្តិ　　តស្មាហារាតិ វុច្ចរេ ។

ធម៌ពួកណា　　រមែងនាំមកនូវអាហារជដ្ឋក
កលាប វេទនា បដិសន្ធិវិញ្ញាណ ចេតសិក និង
កម្មជរូប ដោយចំពោះរបស់ខ្លួន ៗ ដូច្នោះ ធម៌
ពួកនោះ ឈ្មោះថា អាហារ ។

៣០- សំ. ចូរសម្ដែងធម៌ដូចតទៅនេះ

ក. ធម៌ដែលជាឈានង្គៈបាន តែជាមគ្គង្គៈមិនបាន

ខ. ធម៌ដែលជាមគ្គង្គៈបាន　តែជាឈានង្គៈមិនបាន

គ. ធម៌ដែលជាឈានង្គៈ　និងមគ្គង្គៈបានទាំងពីរ

ឃ. ធម៌ដែលជាឈានង្គៈ　និងមគ្គង្គៈមិនបានទាំងពីរ

ង. ធម៌ដែលជាមគ្គង្គៈបាន　តែជាពលៈមិនបាន

ច. ធម៌ដែលជាពលៈបាន តែជាមគ្គង្គៈមិនបាន

ឆ. ធម៌ដែលជាមគ្គង្គៈ និងពលៈបានទាំងពីរ

ជ. ធម៌ដែលជាមគ្គង្គៈ និងពលៈមិនបានទាំងពីរ

ចំ. ក. ធម៌ដែលជាឈានង្គៈបាន តែជាមគ្គង្គៈមិនបាន បានដល់ វិចារៈ បីតិ និងវេទនាចេតសិក ដែលកើតនៅក្នុងចិត្ត ១១១ (វៀរទ្វិបញ្ចវិញ្ញាណ១០) វិតក្កចេតសិក ដែលកើតនៅក្នុងអហេតុកចិត្ត៨ ឯកគ្គតាចេតសិក ដែលកើតនៅ ក្នុងអហេតុកចិត្ត៨ និងវិចិកិច្ឆាសម្បយុត្តចិត្ត១

ខ. ធម៌ដែលជាមគ្គង្គៈបាន តែជាឈានង្គៈមិនបាន បានដល់ សតិ បញ្ញា វិរតិ ទិដ្ឋិ និងវីរិយចេតសិកនៅក្នុងចិត្ត ១០៣ (វៀរមនោទ្វារាវជ្ជនចិត្ត ១ ហសិតុប្បាទចិត្ត១)

គ. ធម៌ដែលជាឈានង្គៈ និងមគ្គង្គៈបានទាំងពីរ បានដល់ វិតក្កចេតសិក ដែលកើតនៅក្នុងចិត្ត៤៧ (វៀរអហេតុកចិត្ត៨) ឯកគ្គតាចេតសិកដែលកើតនៅក្នុងចិត្ត

១០២ (វៀរអហេតុកចិត្ត ១៨ និង វិចិកិច្ឆាសម្បយុត្តចិត្ត១)

ឃ. ធម៌ដែលជាឈានង្គៈ និងមគ្គង្គៈមិនបានទាំងពីរ បានដល់ ចិត្ត ៨៩ ចេតសិក៤០ (វៀរ ១២ គឺ វេទនា ឯកគ្គតា វិតក្កៈ វិចារៈ វីរិយៈ បីតិ ទិដ្ឋិ សតិ វិរតិ៣ បញ្ញា ដែលជាអង្គឈាននិងអង្គមគ្គ) និងវេទនា ឯកគ្គតាចេតសិកនៅក្នុងទ្វិបញ្ចវិញ្ញាណ១០ វីរិយចេតសិកក្នុងមនោទ្វារាវជ្ជនចិត្ត ១ និងហសិតុប្បាទចិត្ត១ រូប២៨ និព្វាន ។

ង. ធម៌ដែលជាមគ្គង្គៈបាន តែជាពលៈមិនបាន បានដល់ វិតក្កចេតសិកនៅក្នុងចិត្ត៤៧ (វៀរអហេតុកចិត្ត ៨) ទិដ្ឋិ និងវិរតិចេតសិក

ច. ធម៌ដែលជាពលៈបាន តែជាមគ្គង្គៈមិនបាន បានដល់ សទ្ធា ហិរិ ឱត្តប្បៈ អហិរិកៈ អនោត្តប្បៈ និងវីរិយៈ ឯកគ្គតាចេតសិកក្នុងមនោទ្វារាវជ្ជនចិត្ត១ ហសិតុប្បាទចិត្ត១

ឆ. ធម៌ដែលជាមគ្គង្គៈ និងពលៈបានទាំងពីរ បានដល់ បញ្ញា សតិ វីរិយចេតសិក ដែលកើតនៅក្នុងចិត្ត ១០៣ (វៀរមនោទ្វារាវជ្ជនចិត្ត១ ហសិតុប្បាទចិត្ត ១) ឯកគ្គតាចេតសិកដែលកើតនៅក្នុងចិត្ត១០២ (វៀរ អហេតុកចិត្ត១៨ និងវិចិកិច្ឆាសម្បយុត្តចិត្ត១)

ជ. ធម៌ដែលជាមគ្គង្គៈ និងពលៈមិនបានទាំងពីរ បានដល់ ចិត្ត ៨៩ ចេតសិក៣៨ (វៀរ ១៤ គឺ ឯកគ្គតា វិតក្កៈ វីរិយៈ អហិរិកៈ អនោត្តប្បៈ ទិដ្ឋិ សទ្ធា សតិ ហិរិ ឱត្តប្បៈ វិរតិ៣ បញ្ញាដែលជាអង្គ មគ្គនិងពលៈ) និងឯកគ្គតា ចេតសិកនៅក្នុងអវីរិយ ចិត្ត១៦ វិចិកិច្ឆាសម្បយុត្តចិត្ត១ រូប២៨ និព្វាន ។

**ចប់ សំនួរ-ចម្លើយក្នុងមិស្សកសង្គហៈ**

# ពួកទី ៣ ពោធិបក្ខិយសង្គហៈ

**១-សតិប្បដ្ឋាន** ៤ គឺ ១.កាយានុបស្សនា ២.វេទនានុបស្សនា ៣.ចិត្តានុបស្សនា ៤.ធម្មានុបស្សនា ។

**២-សម្មប្បធាន** ៤ គឺ

**១-បហានប្បធាន** ព្យាយាមលះបាបអកុសលធម៌ដែលកើតឡើងហើយ ។

**២-សំវរប្បធាន** ព្យាយាមញុំាងបាបអកុសលដែលមិនទាន់កើត មិនឱ្យកើតឡើងបាន ។

**៣-ភាវនាបធាន** ព្យាយាមញុំាងកុសល ដែលមិនទាន់កើត ឱ្យកើតឡើង ។

**៤-អនុរក្ខនាបធាន** ព្យាយាមរក្សាកុសលធម៌ដែលកើតឡើងហើយ ឱ្យរឹងរឹតតែចម្រើនឡើង ។

**៣-ឥទ្ធិបាទ** ៤ គឺ ១-ឆន្ទិទ្ធិបាទ ៣-ចិត្តិទ្ធិបាទ ២-វីរិយិទ្ធិបាទ
៤-វិមំសិទ្ធិបាទ ។

**៤- ឥន្ទ្រិយ** ៥ គឺ ១-សទ្ធិន្ទ្រិយ ២-វីរិយិន្ទ្រិយ ៣-សតិន្ទ្រិយ
៤-សមាធិន្ទ្រិយ ៥-បញ្ញិន្ទ្រិយ ។

**៥-ពលៈ** ៥ គឺ ១.សទ្ធាពលៈ ២.វីរិយពលៈ ៣.សតិពលៈ
៤.សមាធិពលៈ ៥.បញ្ញាពលៈ

**៦-ពោជ្ឈង្គៈ** ៧ គឺ ១.សតិសម្ពោជ្ឈង្គៈ
២.ធម្មវិចយសម្ពោជ្ឈង្គៈ ៣-វីរិយសម្ពោជ្ឈង្គៈ
៤-បីតិសម្ពោជ្ឈង្គៈ ៥-បស្សទ្ធិសម្ពោជ្ឈង្គៈ
៦-សមាធិសម្ពោជ្ឈង្គៈ ៧-ឧបេក្ខាសម្ពោជ្ឈង្គៈ ។

**៧-អដ្ឋមគ្គ** ៨ គឺ ១-សម្មាទិដ្ឋិ ២-សម្មាសង្កប្បៈ
៣-សម្មាវាចា ៤-សម្មាកម្មន្តៈ ៥-សម្មាអាជីវៈ
៦-សម្មាវាយាមៈ ៧-សម្មាសតិ ៨-សម្មាសមាធិ ។

បណ្តាធម៌ទាំង ៧ នេះ សម្មាសតិតែម្យ៉ាងប៉ុណ្ណោះ លោកហៅថា សតិប្បដ្ឋាន ៤, និងសម្មាវាយាមៈ លោកហៅ

ថា សម្មប្បធាន ៤ ដូចគ្នា ។

## សង្គហគាថា សម្ដែងសភាវធម៌

៦ ឆន្ទោ ចិត្តមុបេក្ខា ច សទ្ធាបស្សទ្ធិបីតិយោ
សម្មាទិដ្ឋិ ច សង្កប្បោ វាយាមោ វិរតិត្តយំ ។
៧ សម្មាសតិ សមាធីតិ ចុទ្ទសេតេ សភាវតោ
សត្តតឹសប្បភេទេន សត្តធា តត្ថ សង្គហោ ។

ធម៌ទាំងនេះ ដោយសភាវៈ មាន ១៤ យ៉ាង គឺ ឆន្ទៈ១ ចិត្តៈ១ ឧបេក្ខា១ សទ្ធា១ បស្សទ្ធិ១ បីតិ១ សម្មាទិដ្ឋិ១ សម្មាសង្កប្បៈ១ សម្មាវាយាមៈ១ វិរតិ ៣ សម្មាសតិ ១ សម្មាសមាធិ ១ ពោលដោយប្រភេទមាន ៣៧ ក្នុងពោធិបក្ខិយសង្គហៈនោះ មានការសង្គ្រោះចូលក្នុង ៧ ឋាន ។

## សង្គហគាថា សម្ដែងឋានពោធិបក្ខិយៈ

៨. សង្កប្បបស្សទ្ធិ ច បីត្យុបេក្ខា ឆន្ទោ ច
ចិត្តំ វិរតិត្តយញ្ច នវេកឋានា វិរិយំ នវដ្ឋ
សតី សមាធី ចតុ បញ្ច បញ្ញា សទ្ធា ទុឋានុត្ត
មសត្តតឹសធម្មាន មេសោ បវរោ វិភាគោ ។

៩. សព្វេ លោកុត្តរេ ហោន្តិ ន វា សង្កប្បបីតិយោ
លោកិយេបិ យថាយោគំ ឆព្វិសុទ្ធិប្បវត្តិយំ ។

*ធម៌ ៩ មានឋានតែមួយ គឺ សម្មាសង្កប្បៈ ១ បស្សទ្ធិ ១ បីតិ ១ ឧបេក្ខា ១ ឆន្ទៈ ១ ចិត្តៈ ១ និងវិរតិ ៣. វិរិយៈ មាន ៩ ឋាន. សតិ មាន ៨ ឋាន. សមាធិ មាន ៤ ឋាន. បញ្ញា មាន ៥ ឋាន. និង សទ្ធា មាន ២ ឋាន. នេះជាការចែកដ៏ប្រសើរ បំផុតនៃធម៌ខ្ពស់បំផុត ៣៧ ប្រការ ។*

*ក្នុងលោកុត្តរចិត្តទាំង ៨ មានពោធិបក្ខិយធម៌ទាំង*

អស់ ៣៧ ខ្វះ មិនមានសង្កប្បៈ និងបីតិខ្វះ សូម្បី ក្នុងលោកិយចិត្ត ក៏មាននៅក្នុងពេលប្រព្រឹត្តទៅនៃ វិសុទ្ធិ ៦ ប្រព្រឹត្តទៅតាមសមគួរដល់ការប្រកប ។

## អធិប្បាយ សតិប្បដ្ឋាន ៤

ធម៌ណា រមែងតាំងមាំ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា បដ្ឋាន, បដ្ឋាន គឺ សតិ ឈ្មោះថា **សតិប្បដ្ឋាន** ។

សតិប្បដ្ឋាននោះ មាន ៤ យ៉ាង ដោយអំណាចការ កាន់យកអាការថា "មិនស្អាត ជាទុក្ខ មិនទៀង ជាអនត្តា ក្នុងកាយ វេទនា ចិត្ត ធម៌ និងដោយអំណាចការលះនូវ សញ្ញាវិបល្លាសថា ស្អាត ជាសុខ ទៀង ជាអត្តា ព្រោះ ដូច្នោះ ទើបលោកពោលថា សតិប្បដ្ឋាន ៤ " ដូច្នេះ ។

## អធិប្បាយ ពាក្យថា កាយជាដើម

ឈ្មោះថា កាយ ព្រោះអត្ថថា ជាទីកើតនៃកោដ្ឋាស ដែលបណ្ឌិតគួរខ្ពើម មានកេសាជាដើម បានដល់ រាង

កាយ ។ ម្យ៉ាងទៀត កងនៃខ្យល់អស្សាសៈ និងបស្សាសៈ ក៏ឈ្មោះថា កាយ ។

ការតាមឃើញកាយនោះ គឺ ការរលឹកដល់កាយនោះ ដោយចំណាចនៃបរិកម្ម( ការធ្វើខាងដើម ) និងដោយអំណាច នៃវិបស្សនា ឈ្មោះថា **កាយានុបស្សនា** ។

ការតាមឃើញវេទនា ដែលជាទុក្ខ ព្រោះអត់ទ្រាំបាន ដោយលំបាក ( ទុក្ខ ទុក្ខ ), ដែលជាទុក្ខ ព្រោះការប្រែប្រួល ទៅ ( វិបរិណាមទុក្ខ ), ដែលជាទុក្ខ ព្រោះសង្ខារ( សង្ខារ ទុក្ខ ), ឈ្មោះថា **វេទនានុបស្សនា** ។

ការតាមឃើញចិត្ត ដែលផ្សេងពីគ្នានៃសម្បយោគនិង ភូមិ ដោយអំណាចនៃសរាគចិត្ត និងមហគ្គតចិត្តជាដើម ឈ្មោះថា **ចិត្តានុបស្សនា** ។

ការតាមឃើញធម៌ គឺ សញ្ញា និងសង្ខារ ដែលមាន លក្ខណៈផ្សេងគ្នា ឈ្មោះថា **ធម្មានុបស្សនា** ។

## អធិប្បាយ សម្មប្បធាន ៤

ធម្មជាតិ ដែលឈ្មោះថា សម្មប្បធាន ព្រោះអត្ថថា ជាគ្រឿងតាំងសេចក្តីព្យាយាមដោយប្រពៃ បានដល់ វាយាមៈ ។

ក៏សេចក្តីព្យាយាមនោះ មាន ៤ យ៉ាង ដោយការផ្សេងគ្នានៃចិត្ត ព្រោះដូច្នោះ ទើបលោកពោលថា "សម្មប្បធាន ៤"ជាដើម ។ សេចក្តីព្យាយាមដោយអំណាចនៃកិច្ច មានការប្រកបរឿយ ៗក្នុងកម្មដ្ឋាន មានមនសិការៈក្នុងអសុភៈជាដើម ឈ្មោះថា វាយាមៈ ។ សម្មប្បធាន ៤ នេះ បានដល់ វីរិយចេតសិក នៅក្នុងកុសលចិត្ត ២១ ប៉ុណ្ណោះ ។

## អធិប្បាយ ឥទ្ធិបាទ ៤

ចិត្តមានការតាំងមាំជាដើមនុ៎ះឯង រមែងសម្រេចដោយធម្មជាតិនេះ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា ឥទ្ធិ

បានដល់ ញាណក្នុងឥទ្ធិវិធៈ ។ បាទ គឺ ធម៌ជាគ្រឿងទ្រនៃឥទ្ធិ ឈ្មោះថា ឥទ្ធិបាទ ។ ឥទ្ធិបាទ គឺ ឆន្ទៈ ឈ្មោះថា ឆន្ទិទ្ធិបាទ ។

## អង្គធម៌ ឥទ្ធិបាទ

១. **ឆន្ទិទ្ធិបាទ** បានដល់ ឆន្ទចេតសិក នៅក្នុងកុសលចិត្ត ២១ ។

២. **វីរិយិទ្ធិបាទ** បានដល់ វីរិយចេតសិក នៅក្នុងកុសលចិត្ត ២១ ។

៣. **ចិត្តិទ្ធិបាទ** បានដល់ កុសលចិត្ត ២១ ។

៤. **វិមំសិទ្ធិបាទ** បានដល់ បញ្ញាចេតសិកនៅក្នុងកុសលញាណសម្បយុត្តចិត្ត ១៧ ។

* ឥន្ទ្រិយ ៥ ជាដើមអធិប្បាយរួចហើយ ក្នុងមិស្សកសង្គហៈ ។

## អធិប្បាយពោជ្ឈង្គៈ ៧

បុគ្គល អ្នកឈ្មោះថា ពោធិ ព្រោះអត្ថថា ត្រាស់ដឹង ។

ម្យ៉ាងទៀត ចាប់តាំងពីវិបស្សនា ព្រះយោគាវចរ រមែងត្រាស់ដឹង គឺ ចាក់ធ្លុះសច្ចៈ រមែងភ្ញាក់ពីដេកលក់ គឺ កិលេស រមែងរីករាយដោយសម្រេចនូវមគ្គនិងផល ព្រោះ មិនមានកិលេសកម្រើក ដោយធម៌សាមគ្គី មានសតិជាដើម យ៉ាងណា ធម៌សាមគ្គីយ៉ាងនោះ ឈ្មោះថា ពោធិ ។

ធម៌ជាអង្គ គឺ ជាការណ៍របស់បុគ្គលអ្នកត្រាស់ដឹង នោះ ឬរបស់ធម៌សាមគ្គីជាហេតុត្រាស់ដឹងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា ពោជ្ឈង្គៈ ( អង្គនៃការត្រាស់ដឹង ) ។ ពោជ្ឈង្គៈ នោះ មាន ៧ យ៉ាង ដោយអំណាចនៃធម៌ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា "សតិសម្ពោជ្ឈង្គៈ"ជាដើម ។

ពោជ្ឈង្គៈដែលល្អ គឺ សតិ ឈ្មោះថា

សតិសម្ពោជ្ឈង្គៈ ។

ម្យ៉ាងទៀត សតិសម្ពោជ្ឈង្គៈ ព្រោះអត្ថថា អង្គនៃបុគ្គលដែលត្រាស់ដឹងល្អ ឬ(អង្គ)នៃធម៌សាមគ្គី ជាហេតុត្រាស់ដឹងល្អ ។

ធម្មជាតិ ឈ្មោះថា ធម្មវិចយៈ ព្រោះអត្ថថា វិច័យ គឺ ថ្លឹងថ្លែង ពិនិត្យពិច័យធម៌ បានដល់ វិបស្សនាបញ្ញា ។ល ។

ក្នុងពាក្យថា "ឧបេក្ខា" នេះ លោកប្រាថ្នាយកតត្រមជ្ឈត្តុបេក្ខា ។

លោកអាចារ្យពោលថា "ក្នុងពោធិបក្ខិយសង្គហៈនោះ មានការស្ង្រោះ ៧ យ៉ាង" ហើយពោលពាក្យថា "សង្កប្បៈ និងបស្សទ្ធិ"ជាដើម ដើម្បីសម្តែងសង្គហៈ នោះទៀត ។ ក្នុងធម៌ទាំងឡាយ មានសម្មាសង្កប្បៈជាដើមនោះ វិរិយៈមាន ៩ ឋាន ។

វីរិយៈ មាន៩ឋាន ព្រោះមានកិច្ច៩
-សម្មប្បធាន មាន៤ឋាន
-វីរិយិទ្ធិបាទ មាន១ឋាន
-វីរិយិន្ទ្រិយ មាន១ឋាន
-វីរិយពលៈ មាន១ឋាន
-វីរិយសម្ពោជ្ឈង្គៈ មាន១ឋាន
-សម្មាវាយាមៈ មាន១ឋាន ។[១]

សតិ មាន៨ឋាន ព្រោះមានកិច្ច៨
-សតិប្បដ្ឋាន មាន៤ឋាន
-សតិន្ទ្រិយ មាន១ឋាន
-សតិពលៈ មាន១ឋាន
-សតិសម្ពោជ្ឈង្គៈ មាន១ឋាន
-សម្មាសតិ មាន១ឋាន

សមាធិ មាន៤ឋាន
-សមាធិន្ទ្រិយ មាន ១ ឋាន
-សមាធិពលៈ មាន ១ ឋាន
-សមាធិសម្ពោជ្ឈង្គៈ មាន១ឋាន
-សម្មាសមាធិ មាន ១ ឋាន

បញ្ញា មាន៥ឋាន
-វិមំសិទ្ធិបាទ មាន ១ ឋាន
-បញ្ញិន្ទ្រិយ មាន ១ ឋាន
-បញ្ញាពលៈ មាន ១ ឋាន
-ធម្មវិចយសម្ពោជ្ឈង្គៈមាន១ឋាន
-សម្មាទិដ្ឋិ មាន ១ ឋាន

---

១. មើលសង្គហគាថាទី ៨ ទំព័រ ៧១ ។

សទ្ធា មាន ២ ឋាន ព្រោះមានកិច្ច ២ យ៉ាង គឺ សទ្ធិន្ទ្រិយ មាន ១ ឋាន សទ្ធាពលៈ មាន ១ ឋាន ។

នេះជាការចែកដ៏ប្រសើរ គឺ កំពូលនៃធម៌ ៣៧ ប្រសើរខ្ពស់បំផុត គឺ វិសេសបំផុត ព្រោះជាប្រភេទនៃធម៌ជាគ្រឿងត្រាស់ដឹង ។ ធម៌ ៣៧ នេះ មានក្នុងលោកុត្តរចិត្ត ៨, ចិត្តខ្លះ មិនមានសង្កប្បៈ និងបីតិ ព្រោះសង្កប្បៈមិនកើតក្នុងចិត្តជាទុតិយជ្ឈានជាដើម និងបីតិមិនកើតក្នុងចិត្តជាចតុត្ថជ្ឈាន និងបញ្ចមជ្ឈាន ។

សូម្បីនៅក្នុងលោកិយចិត្ត ពោធិបក្ខិយធម៌ពួកខ្លះ ក៏មាន នៅក្នុងលោកិយចិត្តខ្លះ មិនមាននៅក្នុងលោកិយចិត្តខ្លះ តាមសមគួរដល់ការប្រកប គឺ តាមអំណាចដែលសមគួរដល់កិច្ចនោះៗ ក្នុងវេលាវិសុទ្ធិ ៦ មានសីលវិសុទ្ធិជាដើមប្រព្រឹត្តទៅ ។

**ចប់ ពោធិបក្ខិយសង្គហៈ ពួកទី ៣**

## សំនួរ-ចម្លើយ ក្នុងពោធិបក្ខិយសង្គហៈ

១- សំ. ចូរចែកពោធិបក្ខិយធម៌ ៣៧ ឱ្យជាពួក ៗ និងសម្តែងសេចក្តីសំដៅ ព្រមទាំងអង្គធម៌ក្នុងពោធិបក្ខិយធម៌ដូចតទៅនេះ ៖

១. កាយានុបស្សនាសតិប្បដ្ឋាន

២. ធម្មានុបស្សនាសតិប្បដ្ឋាន

៣. ឧប្បន្នានំ បាបកានំ បហាយ វាយាមោ

៤. អនុប្បន្នានំ បាបកានំ អនុប្បាទាយ វាយាមោ

៥. ឆន្ទិទ្ធិបាទ

៦. វិមំសិទ្ធិបាទ

៧. វីរិយិន្ទ្រិយ

៨. សទ្ធាពលៈ

៩. បញ្ញាពលៈ

១០. បីតិសម្ពោជ្ឈង្គ

១១. សមាធិសម្ពោជ្ឈង្គ

១២. សម្មាសង្កប្បៈ១

១៣. សម្មាសមាធិ

ចំ. ចែកពោធិបក្ខិយធម៌ ៣៧ ឱ្យជាពួក ៗ ដូច្នេះ គឺ សតិប្បដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ៤ ឥន្ទ្រិយ៥ ពលៈ

៥ ពោជ្ឈង្គ៧ អង្គមគ្គ៨ ។

សម្តែងសេចក្តីសំដៅ ព្រមទាំងអត្ថធម៌

ក្នុងពោធិបក្ខិយធម៌ ខាងក្រោម ដូចតទៅនេះ

១. កាយានុបស្សនាសតិប្បដ្ឋាន សំដៅដល់ សតិ ដែលតាំងមាំក្នុងការពិចារណារឿយ ៗនូវកាយ គឺ រូបក្ខន្ធ មានខ្យល់ដង្ហើមចូល-ចេញ ឥរិយាបថធំ ឥរិយាបថតូច អត្ថធម៌បានដល់ សតិចេតសិកដែលនៅក្នុងមហាកុសលចិត្ត ៨ ក្នុងមហាកិរិយាចិត្ត ៨ ក្នុងអប្បនាជវនៈ ២៦

២. ធម្មានុបស្សនាសតិប្បដ្ឋាន សំដៅដល់ សតិដែលតាំងមាំក្នុងការពិចារណារឿយ ៗនូវសភាវធម៌ ដែលកើតមានដោយអាការៈដែលប្រាសចាកតួខ្លួន មានសភាពរបស់លោភៈ ទោសៈ មោហៈ អត្ថធម៌បានដល់ សតិចេតសិកដែលនៅក្នុងមហាកុសលចិត្ត ៨ ក្នុងមហាកិរិយាចិត្ត ៨ ក្នុងអប្បនាជវនៈ ២៦

៣. ឧប្បន្នានំ បាបកានំ បហាយ វាយាមោ សំដៅដល់

សេចក្តីព្យាយាមដើម្បីលះបង់អកុសលធម៌ ដែលកើតឡើងហើយ អង្គធម៌បានដល់ វីរិយចេតសិកនៅក្នុងកុសលចិត្ត២១

៤. អនុប្បន្នានំ បាបកានំ អនុប្បាទាយ វាយាមោ សំដៅដល់សេចក្តីព្យាយាមដើម្បីរាំងអកុសលធម៌ ដែលមិនទាន់កើតឡើង មិនឱ្យកើតឡើង អង្គធម៌បានដល់ វីរិយចេតសិកដែលនៅក្នុងកុសលចិត្ត ២១

៥. ឆន្ទិទ្ធិបាទ សំដៅដល់ សេចក្តីពេញចិត្តយ៉ាងខ្លាំងក្លាជាបាទខាងដើមនៃការសម្រេចឈាន មគ្គ ផល អង្គធម៌បានដល់ ឆន្ទចេតសិកដែលនៅក្នុងកុសលចិត្ត ២១

៦. វិមំសិទ្ធិបាទ សំដៅដល់ បញ្ញាយ៉ាងខ្លាំងក្លាជាបាទ ខាងដើមនៃការសម្រេចឈាន មគ្គ ផល អង្គធម៌ បានដល់បញ្ញាចេតសិកដែលនៅក្នុងកុសលញាណសម្បយុត្តចិត្ត ១៧

៧. វីរិយិន្ទ្រិយ សំដៅដល់ វីរិយដែលជាអ្នកគ្រប់គ្រង ក្នុងសេចក្តីព្យាយាមចំពោះវត្ថុដែលគួរ អង្គធម៌បានដល់ វីរិយចេតសិកដែលនៅក្នុងមហាកុសលចិត្ត ៨ ក្នុងមហាកិរិយា

ចិត្ត ៨ ក្នុងអប្បនាជវនៈ ២៦

៨. សទ្ធាពលៈ សំដៅដល់ សទ្ធាជាអ្នកមិនញាប់ញ័រក្នុងសេចក្ដីជ្រះថ្លាចំពោះវត្ថុដែលគួរ អង្គធម៌បានដល់ សទ្ធាចេតសិកនៅក្នុងមហាកុសលចិត្ត៨ ក្នុងមហាកិរិយាចិត្ត ៨ ក្នុងអប្បនាជវនៈ ២៦

៩. បញ្ញាពលៈ សំដៅដល់ បញ្ញាជាអ្នកមិនញាប់ញ័រ ក្នុងការដឹងតាមសេចក្ដីពិត អង្គធម៌បានដល់ បញ្ញាចេតសិកដែលនៅក្នុងមហាកុសល ញាណសម្បយុត្តចិត្ត ៤ ក្នុងមហាកិរិយាញាណសម្បយុត្តចិត្ត៤ ក្នុងអប្បនាជវនៈ:២៦

១០. បីតិសម្ពោជ្ឈង្គ សំដៅដល់ សេចក្ដីឆ្អែតចិត្ត ជាអង្គនៃការដឹងសច្ច៤ អង្គធម៌បានដល់ បីតិចេតសិកដែលនៅក្នុងមហាកុសលសោមនស្សចិត្ត ៤ ក្នុងមហាកិរិយាសោមនស្សចិត្ត ៤ ក្នុងអប្បនាជវនៈ ៣០ ឬ រូបកុសល ៣ រូបកិរិយា៣ លោកុត្តរចិត្ត ៨

១១. សមាធិសម្ពោជ្ឈង្គ សំដៅដល់ សេចក្តីតាំងមាំ ក្នុងអារម្មណ៍ ជាអង្គនៃការដឹងសច្ចៈ៤ អង្គធម៌ បានដល់ឯកគ្គតាចេតសិក ដែលនៅក្នុងមហាកុសលចិត្ត ៨ ក្នុងមហាកិរិយាចិត្ត ៨ ក្នុងអប្បនាជវនៈ ២៦

១២. សម្មាសង្កប្បៈ សំដៅដល់ សេចក្តីត្រិះរិះប្រពៃ ជាផ្លូវឱ្យដល់មគ្គ ផល និព្វាន អង្គធម៌បានដល់ វិតក្កចេតសិកដែលនៅក្នុងមហាកុសលចិត្ត ៨ ក្នុងមហាកិរិយាចិត្ត ៨ ក្នុងបឋមជវនៈ១០ ឬ រូបកុសល១ រូបកិរិយា១ លោកុត្តរចិត្ត៨

១៣. សម្មាសមាធិ សំដៅដល់ សេចក្តីតាំងមាំ ជាផ្លូវឱ្យដល់មគ្គ ផល និព្វាន អង្គធម៌បានដល់ ឯកគ្គតាចេតសិកដែលនៅក្នុងមហាកុសលចិត្ត ៨ ក្នុងមហាកិរិយាចិត្ត ៨ ក្នុងអប្បនាជវនៈ ២៦

២- សំ. គាថាដែលសម្តែងអង្គធម៌ ក្នុងពោធិបក្ខិយសង្គហៈនោះ សម្តែងយ៉ាងណា ? ចូរប្រែផង

១- ឆន្ទោ ចិត្តមុបេក្ខា ច ។ល ។ វាយាមោ វិរតិត្តយំ ។

២- សម្មាសតិ សមាធីតិ ។ល ។ សត្តធា តត្ថ

សង្គហោ ។

ពោធិបក្ខិយធម៌ទាំងនេះ ដោយសភាវៈ មាន ១៤ គឺ

។ល ។

ការសង្គ្រោះជាពួកក្នុងពោធិបក្ខិយធម៌ទាំង៣៧ នេះ

មាន៧ ពួក ដូច្នេះ

៣- សំ. ចូរសម្តែងអង្គធម៌របស់ពោធិបក្ខិយធម៌ ដែលមានឋានដូចតទៅនេះ មានឋាន ១. ២. ៣. ៤. ៥. ៦. ៧. ៨. ៩.

ចំ. អង្គធម៌របស់ពោធិបក្ខិយធម៌ ដែលមានឋានដូចតទៅនេះ

+ ឋាន ១ មាន ៩ គឺ វិតក្កៈ បស្សទ្ធិ បីតិ តត្រមជ្ឈត្តតា ឆន្ទៈ ចិត្តៈ វិរតិចេតសិក ៣.

+ ឋាន ២ មាន ១ គឺ សទ្ធាចេតសិក

\+ ឋាន ៣ មិនមាន

\+ ឋាន ៤ មាន ១ គឺ ឯកគ្គតាចេតសិក

\+ ឋាន ៥ មាន ១ គឺ បញ្ញា

\+ ឋាន ៦-៧ មិនមាន

\+ ឋាន ៨ មាន ១ គឺ សតិចេតសិក

\+ ឋាន ៩ មាន ១ គឺ វីរិយចេតសិក

៤- សំ. ពោធិបក្ខិយធម៌នេះ កើតឡើងក្នុងលោកិយធម៌ បានឬទេ ? បើបានតើកើតក្នុងខណៈណា ? ចូរលើកសាធក បាលី និងប្រែមកសម្តែងផង

ចំ. ពោធិបក្ខិយធម៌នេះ កើតឡើងក្នុងលោកិយធម៌បាន និងកើតក្នុងខណៈដែលសម្រេចជាវិសុទ្ធិទាំង៦ (វៀរញាណទស្សនវិសុទ្ធិ) ដូចមានសាធកបាលី សម្តែងថា លោកិយេបិ យថាយោគំ ឆព្វិសុទ្ធិ បវត្តិយំ សូម្បីក្នុងលោកិយកុសល និងកិរិយាចិត្ត ក៏រមែងកើតឡើងតាមដែលប្រកបបាន ។

៥- សំ. បញ្ញាជំពូកណាឈ្មោះថា ពោធិ ក្នុងពោធិបក្ខិយសង្គហៈនេះ ? ចូរលើកហេតុផល និងសាធកមកសម្តែងផង

ចំ. បញ្ញាដែលឈ្មោះថា ពោធិ ក្នុងពោធិបក្ខិយសង្គហៈនេះ បានដល់ បញ្ញាដែលកើតនៅក្នុងមគ្គចិត្ត៤ ដូចដែលសម្តែងទុកក្នុងមហានិទ្ទេសព្រះបាលីថា ពោធិ វុច្ចតិ ចតូសុ មគ្គេសុ ញាណំ ញាណក្នុងមគ្គទាំង៤ ហៅថា ពោធិ បញ្ជាក់ហេតុផលឱ្យឃើញថា ព្រោះក្នុងទីនេះ ត្រូវការធម្មជាតិដែលអាចដឹងសច្ចៈ៤ដោយចំពោះ ដែលមានវចនត្ថៈសម្តែងថា ចត្តារិ សច្ចានិ ពុជ្ឈតីតិ = ពោធិ ធម្មជាតិណា ដឹងសច្ចៈ ៤ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា ពោធិ ។

ចំណែកបញ្ញា ដែលនៅក្នុងលោកិយចិត្ត ផលចិត្ត ដែលជាប់ដោយពោជ្ឈង្គ មិនមែនជាបញ្ញាដឹងសច្ចៈ ៤ ទេ ត្រឹមតែជាហេតុឱ្យដឹងអរិយសច្ចៈ ៤ ប៉ុណ្ណោះ ដូចមាន

វិចនត្ថៈសម្តែងថា ពុជ្ឈន្តិ ឯតេយាតិ = ពោធិ ព្រះយោគី បុគ្គលទាំងឡាយ រមែងដឹងសច្ចៈ៤ ដោយធម៌ពួកនេះ ដូច្នោះ ធម៌ពួក ដែលជាហេតុឱ្យដឹងអរិយសច្ចៈ ៤ នេះ ឈ្មោះថា ពោធិ ។

មួយទៀត ឈ្មោះថា ពោធិ ក្នុងពោជ្ឈង្គនោះ មិនមែនជាឈ្មោះរបស់បញ្ញាតែមួយទេ អង្គរបស់ពោជ្ឈង្គដទៃ ក៏ឈ្មោះថា ពោធិ ដែរ ។

៦- សំ. ពោធិបក្ខិយៈ មានន័យយ៉ាងណា ? បើបន្ថែមពាក្យថា សង្គហៈទៀត មានន័យយ៉ាងណា ? ចូរអធិប្បាយ និងលើកវិចនត្ថមកសម្តែងផង

ចំ. ពោធិបក្ខិយៈ មានន័យថា ធម៌ដែលកើតក្នុងផ្នែកនៃមគ្គញ្ញាណ ៤ ឈ្មោះថា ពោធិបក្ខិយៈ បានដល់ពោធិបក្ខិយធម៌ ៣៧ មានវិចនត្ថៈថា ពោធិយា បក្ខេភវាតិ = ពោធិបក្ខិយា ។ បើបន្ថែមពាក្យថា សង្គហៈទៀត

មានន័យថា ការសម្ដែងរួបរួមធម៌ដែលជាផ្នែកនៃមគ្គញ្ញាណ ៤ ឈ្មោះថា ពោធិបក្ខិយសង្គហៈ មានវចនត្ថៈសម្ដែងថា ពោធិយានំ សង្គហោតិ = ពោធិបក្ខិយាសង្គហោ

៧- សំ. ពាក្យថា សតិប្បដ្ឋាន មានន័យយ៉ាងណា ? មានវចនត្ថៈសម្ដែងយ៉ាងណា ? ហេតុអ្វីបានជាសតិតែមួយ អាចជាសតិប្បដ្ឋានទាំង ៤ បាន ? ចូលអធិប្បាយ និងលើកហេតុផលផង

ចំ. ពាក្យថា សតិប្បដ្ឋាន មានន័យថា សតិជាប្រធានក្នុងឱ្យសម្បយុត្តធម៌តាំងមាំក្នុងអារម្មណ៍ មានកាយជាដើម មានវចនត្ថៈសម្ដែងថា សតិ ឯវ បដ្ឋានន្តិ = សតិប្បដ្ឋានំ

និងសតិតែ១ អាចជាសតិប្បដ្ឋានទាំង ៤ បាននោះ ក៏ព្រោះថា អារម្មណ៍ដែលជាទីតាំងនៃការកំណត់ ក៏មាន ៤ លក្ខណៈដែលជានិមិត្ត ដែលប្រាកដឡើង ក៏មាន ៤ ការប្រហារវិប្បល្លាសធម៌ ក៏មាន ៤ ដោយហេតុនេះ ទើបសតិតែ១ អាចជាសតិប្បដ្ឋានទាំង ៤ បាន អធិប្បាយថា

អារម្មណ៍ដែលជាទីតាំងនៃការកំណត់ មាន៤ គឺ

១- រូបក្ខន្ធ ជាអារម្មណ៍នៃការកំណត់របស់សតិ ហៅថា កាយានុបស្សនាសតិបដ្ឋាន ។ ។ល ។

៤- សញ្ញាក្ខន្ធ និងសង្ខារក្ខន្ធ ជាអារម្មណ៍នៃការកំណត់របស់សតិ ហៅថា ធម្មានុបស្សនាសតិបដ្ឋាន លក្ខណៈដែលជានិមិត្តដែលប្រាកដឡើងមាន ៤ និងការប្រហារវិបល្លាសធម៌ ក៏មាន ៤ នោះ គឺ

១- ការកំណត់ពិចារណាក្នុងកាយរឿយ ៗ ជាហេតុឱ្យអសុភលក្ខណៈប្រាកដឡើង និងក្នុងខណៈជាមួយគ្នានោះ រមែងប្រហារសុភវិបល្លាសឱ្យអស់ទៅ ។ល ។

៤-ការកំណត់ពិចារណាក្នុងសភាវធម៌ គឺ សញ្ញា និងសង្ខាររឿយ ៗ ជាហេតុឱ្យអនត្តលក្ខណៈប្រាកដឡើង និងក្នុងខណៈជាមួយគ្នានោះ រមែងប្រហារអត្តវិបល្លាសឱ្យអស់ទៅ

៨- សំ. វីរិយៈ ប្រភេទណា ជាសម្មប្បធានបាន និងក្នុងការដែលពោលថា វីរិយៈ ដែលក្រៅពីកុសលវីរិយៈ

ហើយ ជាសម្មប្បធានមិនបាន យ៉ាងនេះ ព្រោះហេតុអ្វី ? ចូរ
រៀបរាប់ឱ្យបាន ត្រឹមតែ២យ៉ាង តាមការពេញចិត្តរបស់អ្នក

ចំ. វិរិយៈ ដែលជាសម្មប្បធានបាននោះ ត្រូវតែជា
វិរិយៈដ៏ខ្លាំងក្លា, វិរិយៈធម្មតា មិនអាចជាសម្មប្បធានបានទេ,
ពោលគឺ ការព្យាយាមដោយមិនរាថយ សូម្បីឈាមសាច់ ក្នុង
កាយរបស់យើងហួតហែងទៅ នៅសល់តែស្បែក សសៃ ឆ្អឹង
ក៏ដោយ កិច្ចណាដែលសម្រេចដោយកម្លាំងរបស់បុរស បើ
កិច្ចនោះមិនទាន់សម្រេចទេ យើងនឹងមិនបញ្ឈប់សេចក្តីព្យាយាម
នោះឡើយ ។

និងក្នុងការដែលពោលថា វិរិយៈ ដែលក្រៅពីកុសល
វិរិយៈហើយ ជាសម្មប្បធានមិនបាននោះ ព្រោះហេតុថា ព្រះ
អរហន្តទាំងឡាយ រមែងផុតចាកកិច្ចនៃការលះអកុសល និង
កិច្ចនៃការឱ្យកុសលកើតឡើងចេញហើយ ដូច្នោះ វិរិយៈក្នុង
កិរិយាជវនៈនោះ ទើបមិនហៅថា សម្មប្បធាន សម្រាប់
វិរិយៈក្នុងផលចិត្ត ក៏ដូចគ្នា គឺមិនជាប់ដោយកិច្ច ទាំង ៤

នោះ ព្រោះខ្លួនជាវិបាកស្រោប់ផងនោះឯង

## ពណ៌នាសម្មប្បធាន

១. ព្យាយាមដើម្បីលះអកុសលដែលកើតឡើងហើយ ក្នុងទីនេះ អកុសលធម៌កើតឡើងហើយ ហៅថា ឧប្បន្នបាបកៈ នោះ សំដៅដល់ អកុសលធម៌ ដែលជាប់ដោយទុច្ចរិត និង ទុរាជីវ ។ល ។ ចំណែកការលះអកុសលធម៌ ដែលជាឧប្បន្នបាបកៈរបស់វីរិយៈ ដែលនៅក្នុងមគ្គកុសលនោះ ច្បាស់លាស់ហើយ ។

២. ព្យាយាមដើម្បីមិនឱ្យអកុសលថ្មីកើត ក្នុងទីនេះ អកុសលធម៌មិនទាន់កើត ដែលហៅថា អនុប្បន្នបាបកៈ នោះ សំដៅដល់ ។ល ។ ការបដិបត្តិដូចពោលមកនេះ បានឈ្មោះ ថា អនុប្បន្នានំ បាបកានំ អនុប្បាទាយ វាយាមោ ។

៣. ព្យាយាមដើម្បីឱ្យកុសលថ្មីកើត ក្នុងទីនេះកុសល ថ្មី គឺ កុសលដែលមិនទាន់កើត ដែលហៅថា អនុប្បន្នកុសល នោះ សំដៅដល់ ។ល ។ ព្យាយាមញុំាងកុសលដែល មិនទាន់កើត ឱ្យកើតឡើងដល់ខ្លួននោះឯង បានឈ្មោះថា អនុប្បន្នានំ កុសលានំ ឧប្បាទាយ វាយាមោ ។

៤- ព្យាយាមដើម្បីឱ្យកុសលដែលកើតឡើងហើយ ឱ្យចម្រើន រុងរឿងឡើង ក្នុងទីនេះកុសលកើតឡើងហើយ ហៅថា ឧប្បន្នកុសលនោះ សំដៅដល់ ។ល ។ និងសេចក្តី ព្យាយាមធ្វើ ឱ្យកុសលដែលកើតឡើងហើយនោះ កើត ឡើងរឿយ ៗ ទើបឈ្មោះថា ឧប្បន្នានំ កុសលានំ ភិយ្យោភាវាយ វាយាមោ ។

៩- សំ. ដែលលោកមានសេចក្តីប្រាថ្នារៀនព្រះអភិធម្ម ឱ្យចប់ទាំង៩បរិច្ឆេទនោះ ចាំបាច់ត្រូវមានធម៌ជាគ្រឿងសម្រេច តាមសេចក្តីប្រាថ្នានោះ ប៉ុន្មានយ៉ាង ? អ្វីខ្លះ ? និងធម៌ទាំង

នេះ បើកើតនៅក្នុងវិបាក និងកិរិយាហើយ តើឈ្មោះថា ជាគ្រឿងសម្រេចតាមសេចក្ដីប្រាថ្នា ក្នុងវត្ថុដែលល្អនោះ បាន ឬទេ ? ព្រោះអ្វី ?

ចំ. កាលខ្ញុំមានសេចក្ដីប្រាថ្នារៀនព្រះអភិធម្ម ឱ្យចប់ ទាំង៩បរិច្ឆេទនោះ ចាំបាច់ត្រូវមានឥទ្ធិបាទធម៌ជាគ្រឿង សម្រេចតាមសេចក្ដីប្រាថ្នានោះ, ឥទ្ធិបាទនោះ មាន : ១.ឆន្ទិទ្ធិបាទ ២.វីរិយិទ្ធិបាទ ៣.ចិត្តិទ្ធិបាទ ៤.វិមំសិទ្ធិបាទ និង ធម៌ទាំងនេះ បើកើតនៅក្នុងវិបាកនិងកិរិយាហើយ មិនឈ្មោះថា ជាគ្រឿងសម្រេចតាមសេចក្ដីប្រាថ្នាក្នុងវត្ថុដែលល្អនោះទេ ព្រោះថា វិបាកធម៌ជាផលរបស់មគ្គចិត្ត ដូច្នោះ ផលចិត្តក្ដី ឆន្ទៈ វីរិយៈ បញ្ញា ដែលនៅក្នុងផលចិត្តក្ដី មិនឈ្មោះថា ឥទ្ធិបាទ, ចំណែកឯកិរិយាធម៌នោះ ជារបស់ព្រះអរហន្ត តាម ធម្មតា ព្រះអរហន្តទាំងឡាយនោះ ជាអ្នកដល់សេចក្ដីសម្រេច ដោយបរិបូណ៌ហើយ ដូច្នោះ ឆន្ទៈ វីរិយៈ កិរិយាចិត្ត និង បញ្ញា របស់ព្រះអរហន្តនោះ ក៏មិនឈ្មោះថា ឥទ្ធិបាទ ដូច

គ្នា, ។

១០- សំ. ពាក្យថា ពោជ្ឈង្គ ចែកជាប៉ុន្មានបទ ? ចូរប្រាប់ អត្ថន័យ និងអង្គធម៌ របស់បទនោះមកផង

ចំ. ពាក្យថា ពោជ្ឈង្គ ចែកជា ២ បទ ពោធិ + អង្គ; ពោធិ មានន័យថា ធម៌ដែលជាហេតុឱ្យដឹងអរិយសច្ចៈ ៤ បានដល់ អង្គធម៌របស់ពោជ្ឈង្គ ៧ រួមគ្នា មានសតិ បញ្ញា ជាដើម, អង្គ មានន័យថា ធម៌ដែលជាគ្រឿងប្រកប បានដល់ អង្គធម៌របស់ពោជ្ឈង្គដោយចំពោះ( មួយ ៗ ) ។

១១- សំ. ចូរសម្តែងសេចក្តីដែលអធិប្បាយពោជ្ឈង្គ ៧ ឱ្យបានល្អិតល្អន់

ចំ. សេចក្តីដែលអធិប្បាយពោជ្ឈង្គ ៧ ដោយល្អិតល្អន់នោះគឺ ៦-ពោជ្ឈង្គ ៧ គឺ

១. សតិសម្ពោជ្ឈង្គ សតិដែលមានសេចក្តីចម្រើន គឺ តាំងនៅបានជាប់តគ្នា ក្នុងអារម្មណ៍របស់សតិបដ្ឋាន៤ ដោយការនាកិច្ច ហើយទំលាយសេចក្តីប្រមាទ និងធ្វើ

សម្ពោធិញ្ញាណ គឺ មគ្គទាំង៤ កើតឡើង ឈ្មោះថា សតិសម្ពោជ្ឈង្គ ។ ។ល ។

៧. ឧបេក្ខាសម្ពោជ្ឈង្គ តត្រមជ្ឈត្តតាចេតសិក ដែលមានសេចក្តីចម្រើន គឺធ្វើឱ្យសទ្ធានិងបញ្ញា វិរិយៈនិងសមាធិ មានសភាពស្មើ មិនលើសមិនខ្វះពីគ្នា ហើយទំលាយសេចក្តីកាមឆន្ទៈ វិចិកិច្ឆា ឧទ្ធច្ចៈ កុក្កុច្ចៈ ថីនមិទ្ធៈ និងធ្វើឱ្យពោធិញ្ញាណ គឺ មគ្គទាំង៤ កើតឡើង ឈ្មោះថា ឧបេក្ខាសម្ពោជ្ឈង្គ ។

១២- សំ. ចូរសម្តែងសេចក្តីផ្សេងគ្នារវាងពាក្យថា មគ្គ និងអង្គមគ្គ ព្រមទាំងលើកវចនត្ថៈមកសម្តែងផង

ចំ. សេចក្តីផ្សេងគ្នារវាង ពាក្យថា មគ្គ និងអង្គមគ្គ មានសេចក្តីដូច្នេះ គឺ ពាក្យថា មគ្គ ជាឈ្មោះរបស់ធម៌រួមគ្នា ដូចវចនត្ថៈសម្តែងថា កិលេសេ មារេន្តា និព្វានំ គច្ឆន្តិ ឯតេនាតិ = មគ្គោ ព្រះយោគីបុគ្គលទាំងឡាយ សម្លាប់កិលេស និងរមែងចូលដល់និព្វានដោយធម៌នោះ ហេតុនោះ

ធម៌ទាំងនោះ ឈ្មោះថា មគ្គ ។

ពាក្យថា អដ្ឋមគ្គ ជាឈ្មោះរបស់អដ្ឋមគ្គដោយចំពោះ ៗ មានវចនត្ថៈសម្តែងថា មគ្គស្ស អង្គោ = មគ្គង្គោ ធម៌ដែល ជាគ្រឿងប្រកបរបស់មគ្គជាហេតុនៃការសម្លាប់កិលេស និងចូលដល់និព្វានដោយធម៌នោះ ឈ្មោះថា មគ្គអង្គ ។

១៣- ស. បញ្ញាប្រភេទណា ឈ្មោះថា សម្មាទិដ្ឋិមគ្គ និងវិតក្កៈប្រភេទណា ឈ្មោះថា សម្មាសង្កប្បមគ្គ ? ចូរអធិប្បាយ និងឧបមាក្នុងការសម្រេចកិច្ចរបស់សម្មាទិដ្ឋមគ្គផង និងចែកអដ្ឋមគ្គ ៨ ដោយសីល សមាធិ បញ្ញា ផង

ចំ. បញ្ញាដែលឈ្មោះថា សម្មាទិដ្ឋិមគ្គនោះ ជាបញ្ញាប្រភេទដែលឃើញច្បាស់ក្នុងអរិយសច្ចៈ៤ ដោយកិច្ច៤ គឺ

១. ទុក្ខេ ញាណំ ដឹងក្នុងទុក្ខសច្ចៈ ដោយបរិញ្ញាកិច្ច

២. ទុក្ខសមុទយេ ញាណំ ដឹងក្នុងហេតុឱ្យកើតទុក្ខ ដោយបហានកិច្ច

៣. ទុក្ខនិរោធេ ញាណំ ដឹងក្នុងនិព្វានជាទីរំលត់នៃទុក្ខ ដោយសច្ឆិករណកិច្ច

៤. ទុក្ខនិរោធគាមិនីបដិបទាយ ញាណំ ដឹងក្នុងផ្លូវបដិបត្តិដែលជាហេតុឱ្យដល់ព្រះនិព្វាន ដែលជាទីរំលត់នៃទុក្ខទាំងពួង ដោយភាវនាកិច្ច

ទាំងនេះទើបឈ្មោះថា បញ្ញាដែលជាសម្មាទិដ្ឋិមគ្គ ។

អធិប្បាយ ព្រមទាំងឧបមា ក្នុងការសម្រេចកិច្ចរបស់សម្មាទិដ្ឋមគ្គទាំង ៤ យ៉ាងនោះ ឧបមាដូចជាភ្លើងប្រទីប ជាធម្មតាភ្លើងដែលប្រាកដឡើងហើយ រមែងធ្វើឱ្យសម្រេចកិច្ចបានទាំង៤ យ៉ាងនោះ ព្រមគ្នាក្នុងខណៈតែមួយនោះឯង គឺ

១. ធ្វើឱ្យភ្លឺប្រាកដឡើងជះពន្លឺទៅ

២. កំចាត់ងងឹតឱ្យបាត់ទៅ

៣. ដុតប្រេងឱ្យអស់ទៅ

៤. ប្រេងក៏ស្ងួតទៅតាមលំដាប់

ក្នុងកិច្ចទាំង ៤យ៉ាងនេះ មានសេចក្តីប្រៀបប្រដូចថា ៖

១. ធ្វើឱ្យភ្លឺប្រាកដឡើងជះពន្លឺទៅ ដូចគ្នានឹងអរិយមគ្គ មានអង្គ៨ ដែលដល់នូវសេចក្តីចម្រើន នេះឯងដែលលោកហៅថា ទុក្ខនិរោធគាមិនីបដិបទាយ ញាណំ ។

២. កំចាត់ងងឹតឱ្យបាត់ទៅ ដូចគ្នានឹងការបោលសង្ខារ ធម៌បញ្ញត្តិធម៌ ដែលចូលដល់ព្រះនិព្វាន នេះឯងដែលលោកហៅថា ទុក្ខនិរោធេ ញាណំ ។

៣. ដុតប្រេងឱ្យអស់ទៅ ដូចគ្នានឹងការដឹងជុំវិញក្នុងទុក្ខទាំងពួង នេះឯងដែលលោកហៅថា ទុក្ខេ ញាណំ ។

៤. ប្រេងក៏ស្ងួតទៅតាមលំដាប់ ដូចគ្នានឹងការប្រហារសមុទយតណ្ហា នេះឯងដែលលោកហៅថា ទុក្ខសមុទយេ ញាណំ ។

បណ្តាកិច្ចទាំង ៤ នេះ ទុក្ខនិរោធគាមិនីបដិបទាយ ញាណំ ដឹងក្នុងផ្លូវបដិបត្តិដែលជាហេតុឱ្យដល់ព្រះនិព្វាន

ដែលជាទីរំលត់នៃទុក្ខទាំងពួង ដោយភាវនាកិច្ច ជាកិច្ចដែលសំខាន់ក្រៃលែង ព្រោះថា កាលអរិយមគ្គមានអង្គ៨ នេះដល់សេចក្ដីចម្រើនហើយវេលាណា វេលានោះឯង កិច្ច៣ទៀត ក៏សម្រេចទៅព្រមគ្នាក្នុងខណៈតែមួយនោះឯង ។

វិតក្កៈ ដែលបានឈ្មោះថា សម្មាសង្កប្បមគ្គនោះ ជាប្រភេទវិតក្កៈ ដែលមានសេចក្ដីត្រិះរិះប្រពៃក្នុងរឿងទាំង៣ គឺ

**១.** នេក្ខម្មសង្កប្បៈ ត្រិះរិះចេញចាកកាមគុណារម្មណ៍

**២.** អព្យាបាទសង្កប្បៈ ត្រិះរិះដែលប្រកបដោយមេត្តា

**៣.** អវិហឹសាសង្កប្បៈ ត្រិះរិះដែលប្រកបដោយករុណា

ទាំងនេះឯង ដែលបានឈ្មោះថា វិតក្កៈ ដែលជាសម្មាសង្កប្បមគ្គនោះ

ចែកអង្គមគ្គ ៨ ដោយសីល សមាធិ បញ្ញានោះ ដូច្នេះ

+ សម្មាវាចា
+ សម្មាកម្មន្តៈ
+ សម្មាអាជីវៈ

} អង្គធម៌ទាំង ៣ នេះ សង្គ្រោះចូលក្នុងសីលខន្ធ

+ សម្មាវាយាមៈ
+ សម្មាសតិ
+ សម្មាសមាធិ

} អង្គធម៌ទាំង ៣ នេះ សង្គ្រោះចូលក្នុងសមាធិខន្ធ

+ សម្មាទិដ្ឋិ
+ សម្មាសង្កប្បៈ

} អង្គធម៌ទាំង ៣ នេះ សង្គ្រោះចូលក្នុងបញ្ញាខន្ធ

១៤- សំ. ចូរសម្តែងធម៌ដូចតទៅនេះ

ក. ធម៌ដែលជាឥទ្ធិបាទបាន តែជាឥន្ទ្រិយមិនបាន

ខ. ធម៌ដែលជាឥន្ទ្រិយបាន តែជាឥទ្ធិបាទមិនបាន

គ. ធម៌ដែលជាឥទ្ធិបាទ និងឥន្ទ្រិយបានទាំងពីរ

ឃ. ធម៌ដែលជាឥទ្ធិបាទ និងឥន្ទ្រិយមិនបានទាំងពីរ

ង. ធម៌ដែលជាពោជ្ឈង្គបាន តែជាមគ្គមិនបាន

ច. ធម៌ដែលជាមគ្គបាន តែជាពោជ្ឈង្គមិនបាន

ឆ. ធម៌ដែលជាពោជ្ឈង្គ និងមគ្គបានទាំងពីរ

ជ. ធម៌ដែលជាពោជ្ឈង្គ និងមគ្គមិនបានទាំងពីរ

ចំ. ក. ធម៌ដែលជាឥទ្ធិបាទបាន តែជាឥន្ទ្រិយមិនបាន

បានដល់ ឆន្ទចេតសិក ដែលកើតនៅក្នុងកុសលចិត្ត២១ និងកុសលចិត្ត២១

ខ. ធម៌ដែលជាឥន្ទ្រិយបាន តែជាឥទ្ធិបាទមិនបាន បានដល់ សទ្ធា សតិ ឯកគ្គតាចេតសិក ដែលកើតនៅក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវនៈ ២៦ និងវិរិយចេតសិក ដែលកើតនៅក្នុងមហាកិរិយាចិត្ត ៨ មហគ្គតកិរិយាចិត្ត ៩ លោកុត្តរវិបាកចិត្ត, បញ្ញាចេតសិកដែលកើតនៅក្នុងមហាកិរិយាញាណសម្បយុត្តចិត្ត ៤ មហគ្គតកិរិយាចិត្ត ៩ លោកុត្តរវិបាកចិត្ត ។

គ. ធម៌ដែលជាឥទ្ធិបាទ និងឥន្ទ្រិយបានទាំងពីរ បានដល់ វិរិយចេតសិកដែលកើតនៅក្នុងកុសលចិត្ត២១ បញ្ញាចេតសិកដែលកើតនៅក្នុងកុសលញាណសម្បយុត្តចិត្ត១៧ ។

ឃ. ធម៌ដែលជាឥទ្ធិបាទ និងឥន្ទ្រិយមិនបានទាំងពីរ បានដល់ ចិត្ត ៦៨ ចេតសិកដែលប្រកប ៥២ (វៀរ កុសល ចិត្ត២១) និងចេតសិក៣២ ដែលកើតនៅក្នុង

កុសលចិត្ត២១ រូប២៨ និព្វាន (វៀរសទ្ធា វិរិយៈ សតិ ឯកគ្គតា បញ្ញាដែលកើតនៅក្នុងមហាកុសលចិត្ត៨ មហាកិរិយាចិត្ត៨ អប្បនាជវនៈ ២៦ ឆន្ទចេតសិក ដែលកើតនៅក្នុងកុសលចិត្ត២១) ។

ង. ធម៌ដែលជាពោជ្ឈង្គបាន តែជាមគ្គមិនបាន បានដល់ បីតិចេតសិក ដែលកើតក្នុងមហាកុសលសោមនស្ស ៤ មហាកិរិយាសោមនស្ស ៤ សប្បីតិកអប្បនាជវនៈ ៣៣ (ឬ រូបកុសល៣ រូបកិរិយា ៣ លោកុត្តរ ៨ សង្ខេប) និងកាយបស្សទ្ធិ ចិត្តបស្សទ្ធិ តត្រមជ្ឈត្តតាចេតសិក ដែលកើតនៅក្នុងមហាកុសលចិត្ត៨ មហាកិរិយាចិត្ត៨ អប្បនាជវនៈ២៦ ។

ច. ធម៌ដែលជាមគ្គបាន តែជាពោជ្ឈង្គមិនបាន បានដល់ វិតក្កចេតសិក ដែលកើតនៅក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត៨ បឋមឈានជវនៈ១០ វិរតិចេតសិក ដែលកើតនៅក្នុងមហាកុសលចិត្ត៨ លោកុត្តរ

ចិត្ត៨ ។

ឆ. ធម៌ដែលជាពោជ្ឈង្គ និងមគ្គបានទាំងពីរ បានដល់ វីរិយៈ សតិ ឯកគ្គតាចេតសិក ដែលកើតនៅក្នុងមហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អប្បនាជវនៈ ២៦ និង បញ្ញា ចេតសិកដែលកើតនៅក្នុងមហាកុសលញាណសម្បយុត្តចិត្ត ៤ មហាកិរិយាញាណសម្បយុត្តចិត្ត ៤ អប្បនាជវនៈ ២៦

ជ. ធម៌ដែលជាពោជ្ឈង្គ និងមគ្គមិនបានទាំងពីរ បានដល់ ចិត្ត៨៩ ចេតសិក ៤៩ រូប២៨ និព្វាន (វៀរ វិរតិ បញ្ញា វីរិយៈ បីតិ បស្សទ្ធិ ឯកគ្គតា តត្រមជ្ឈត្តតា វិតក្កៈ នៅក្នុងមហាកុសលចិត្ត មហាកិរិយាចិត្ត អប្បនាជវនៈ) ។

ចប់ សំនួរ-ចម្លើយក្នុងពោធិបក្ខិយសង្គហៈ

# ពួកទី ៤ សព្វសង្គហៈ

ការសង្គ្រោះបរមត្ថធម៌ទាំងពួង ហៅថា សព្វសង្គហៈ ។

ក្នុងសព្វសង្គហៈនេះ ព្រះអនុរុទ្ធាចារ្យសម្តែងធម៌ទុក ៥ ពួក គឺ ខន្ធ ៥ ឧបាទានខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ និងអរិយសច្ចៈ ៤ ។

**១- ខន្ធ ៥** គឺ ១.រូបក្ខន្ធ ២.វេទនាខន្ធ ៣.សញ្ញាខន្ធ ៤.សង្ខារក្ខន្ធ ៥.វិញ្ញាណក្ខន្ធ ។

**២-ឧបាទានក្ខន្ធ ៥** គឺ ១.រូបូបាទានក្ខន្ធ ២.វេទនូបាទានក្ខន្ធ ៣.សញ្ញូបាទានក្ខន្ធ ៤.សង្ខារូបាទានក្ខន្ធ ៥.វិញ្ញាណូបាទានក្ខន្ធ ។

**៣-អាយតនៈ ១២** គឺ

១.ចក្ខាយតនៈ ២.សោតាយតនៈ ៣.ឃានាយតនៈ ៤.ជិវ្ហាយតនៈ ៥.កាយាយតនៈ ៦.មនាយតនៈ

៧.រូបាយតនៈ ៨.សទ្ទាយតនៈ ៩.គន្ធាយតនៈ
១០.រសាយតនៈ ១១.ផោដ្ឋព្វាយតនៈ ១២.ធម្មាយតនៈ ។

៤- ធាតុ ១៨ គឺ

| | | |
|---|---|---|
| ១.ចក្ខុធាតុ | ៧.រូបធាតុ | ១៣.ចក្ខុវិញ្ញាណធាតុ |
| ២.សោតធាតុ | ៨.សទ្ទធាតុ | ១៤.សោតវិញ្ញាណធាតុ |
| ៣.ឃានធាតុ | ៩.គន្ធធាតុ | ១៥.ឃានវិញ្ញាណធាតុ |
| ៤.ជិវ្ហាធាតុ | ១០.រសធាតុ | ១៦.ជិវ្ហាវិញ្ញាណធាតុ |
| ៥.កាយធាតុ | ១១.ផោដ្ឋព្វធាតុ | ១៧.កាយវិញ្ញាណធាតុ |
| ៦.មនោធាតុ | ១២.ធម្មធាតុ | ១៨.មនោវិញ្ញាណធាតុ ។ |

**៥-អរិយសច្ច : ៤** គឺ ១.ទុក្ខអរិយសច្ចៈ
២.ទុក្ខសមុទយអរិយសច្ចៈ ៣.ទុក្ខនិរោធអរិសច្ចៈ
៤.ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ ។

ធម៌ទាំង ៦៩ នេះ គឺ ចេតសិក ៥២ សុខុមរូប ១៦ និង និព្វាន ១ ហៅថា ធម្មាយតនៈ និងធម្មធាតុ ។

មនាយតនៈប៉ុណ្ណោះ រមែងបែកបានដោយអំណាចនៃ

វិញ្ញាណធាតុ ៧ យ៉ាង ។

## **សង្គហគាថា**

១០. រូបញ្ច វេទនា សញ្ញា   សេសា ចេតសិកា តថា
វិញ្ញាណមិតិ បញ្ចេតេ   បញ្ចក្ខន្ធាតិ ភាសិតា ។
១១. បញ្ចុបាទានក្ខន្ធាតិ   តថា តេភូមិកា មតា
ភេទាភាវេន និព្វានំ   ខន្ធសង្គហនិស្សដំ ។
១២. ទ្វារាលម្ពនភេទេន   ភវន្តាយតនានិ ច
ទ្វារាលម្ពនតទុប្បន្ន   បរិយាយេន ធាតុយោ ។
១៣. ទុក្ខំ តេភូមិកំ វដ្ដំ   តណ្ហា សមុទយោ ភវេ
និរោធោ នាម និព្វានំ   មគ្គោ លោកុត្តរោ មតោ ។
១៤. មគ្គយុត្តា ផលា ចេវ   ចតុសច្ចវិនិស្សដា
ឥតិ បញ្ចប្បភេទេន   បវុត្តោ សព្វសង្គហោ ។

*ធម៌ ៥ នេះ គឺ រូប វេទនា សញ្ញា ចេតសិកដែល នៅសល់ (សង្ខារ) និងវិញ្ញាណ ហៅថា ខន្ធ*

៥ ។ មួយទៀត ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ត្រាស់ហៅថា ឧបាទានក្ខន្ធ ៥ ព្រះនិព្វានផុតចាកការសង្គ្រោះចូលក្នុងខន្ធ ព្រោះមិនមានប្រភេទ (១១ មានអតីតជាដើម) ។ អាយតនៈ ១២ រមែងមានដោយប្រភេទនៃទ្វារ និងអារម្មណ៍ ធាតុ ១៨ រមែងមានដោយបរិយាយ ដែលកើតឡើងនៃទ្វារ អារម្មណ៍ និងវិញ្ញាណ ដែលជាទីអាស្រ័យទ្វារ និងអារម្មណ៍ ទាំងពីរនោះ ។ វដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ នេះ ឈ្មោះថា ទុក្ខ. តណ្ហា ឈ្មោះថា សមុទយៈ. ព្រះនិព្វាន ឈ្មោះថា និរោធ. លោកុត្តរមគ្គ លោកហៅថា មគ្គ ។ ធម៌ដែលសម្បយុត្តដោយមគ្គ និងផល ផុតចាកសច្ចៈទាំង ៤. សព្វសង្គហៈ លោកពោលទុកដោយប្រភេទ ៥ យ៉ាងដោយប្រការដូច្នេះ ។

# អធិប្បាយ ខន្ធ ៥

សភាគធម៌ គឺ ធម៌ដែលមានចំណែកស្មើគ្នានោះ ៗ ដែលផ្សេងគ្នា ដោយកាល មានអតីតកាល អនាគតកាល និងបច្ចុប្បន្នកាលជាដើម ឈ្មោះថា ខន្ធ ព្រោះអត្ថគឺ ជាគំនរក្នុងទីតែមួយជាមួយគ្នា (ដោយរុប្បនលក្ខណៈ) ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ៖

"នេះហៅថា រូបក្ខន្ធ ព្រោះប្រមូលរូបរួមនូវរូបទាំងអស់ (១១ ប្រភេទ) នោះ ក្នុងទីជាមួយគ្នា"[១] ។ ក៏ប៉ុន្តែខន្ធទាំងនោះ ព្រះមានព្រះភាគត្រាស់ទុក ៥ យ៉ាង ប៉ុណ្ណោះ ដោយការកំណត់ផ្សេងគ្នា ដូចជា**ភាជន៍ ភោជន ព្យញ្ជនៈ ភត្តការកៈ និងភុញ្ជកៈ** ព្រោះដូច្នោះ ទើបលោកអាចារ្យពោលពាក្យថា "**រូបក្ខន្ធ**"ជាដើម ។

ពិតមែន រូបតាំងនៅក្នុងឋានដូច **ភាជន៍** ព្រោះជាទី

---

១. អភិ. វិភ. ខន្ធវិភង្គ. ៨០. ២/១ ។

អាស្រ័យនៃវេទនា, វេទនាតាំងនៅក្នុងឋានដូច**ភោជន** ព្រោះជារបស់នឹងគប្បីបរិភោគ ។ សញ្ញា តាំងនៅក្នុងឋានដូចជា**ម្ហូបគ្រឿម**( សម្ល ) ព្រោះជាហេតុ បានទទួលសេចក្តីត្រេកអរពីវេទនា ។ សង្ខារតាំងនៅក្នុងឋានដូចជា**អ្នកដាំស្ល** ព្រោះតាក់តែងឱ្យត្រេកអរកាយ ។ វិញ្ញាណតាំងនៅក្នុងឋានដូច**អ្នកបរិភោគ** ព្រោះជាអ្នកចូលទៅបរិភោគនូវអារម្មណ៍ ។

## អត្ថផ្សេង ៗ គ្នារបស់ខន្ធ ៥

១-**រូប** មានវចនត្ថៈថា **រុប្បតីតិ = រូបំ** ប្រែថា ធម្មជាតិណា រមែងបែកធ្លាយ គឺ រមែងកម្រើក ( វិការៈ ) ដោយបច្ច័យទាំងឡាយ មានត្រជាក់ជាដើម ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា រូប ។

ន័យមួយទៀត ធម្មជាតិណា ដែលបច្ច័យ មានត្រជាក់ជាដើម រមែងប៉ះខ្ទប់ រមែងបៀតបៀន ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា រូប ។

២-**វេទនា** មានវចនត្ថៈថា **វេទិយតិ អារម្មណរសំ អនុភវតីតិ = វេទនា** : ធម្មជាតិណា រមែងដឹងខ្លួន គឺរមែងសោយរសនៃអារម្មណ៍ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា វេទនា ។

៣-**សញ្ញា** មានវចនត្ថៈថា **នីលាទិភេទារម្មណំ សញ្ញានាតិ សញ្ញំ កត្វា ជានាតីតិ = សញ្ញា** : ធម្មជាតិណា រមែងសំគាល់ចាំនូវអារម្មណ៍ មានអារម្មណ៍ពណ៌ខៀវជាដើម គឺថា រមែងធ្វើសេចក្តីកំណត់ដឹង ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា សញ្ញា ។

ម្យ៉ាងទៀត បុគ្គលរមែងស្គាល់អារម្មណ៍ ដោយធម្មជាតិនេះ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា សញ្ញា ។

៤-**សង្ខារ** មានវចនត្ថៈថា **សង្ខតំ អភិសង្ខរោន្តីតិ = សង្ខារា** : ធម្មជាតិពួកណា រមែងប្រជុំតាក់តែងនូវសង្ខតធម៌ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា សង្ខារ ។

៥-វិញ្ញាណ មានវចនត្ថៈថា **វិជានាតីតិ = វិញ្ញាណំ** : ធម្មជាតិណា រមែងដឹងច្បាស់ (នូវអារម្មណ៍) ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **វិញ្ញាណ** ។

## អធិប្បាយ ឧបាទានក្ខន្ធ

ខន្ធ ជាអារម្មណ៍ដល់ឧបាទាន ឈ្មោះថា **ឧបាទានក្ខន្ធ** ។ ប៉ុន្តែ ខន្ធមានរូបជាដើមនោះ ដែលព្រះមានព្រះភាគទ្រង់កាន់យកដោយជាអារម្មណ៍ដល់ឧបាទាន មាន ៥ ទុំះឯង ដូច្នោះទើបលោកអាចារ្យពោលពាក្យថា "រូបុបាទានក្ខន្ធោ"ជាដើម ។ ពិតមែន ដើម្បីសង្គ្រោះធម៌ ដែលមានចំណែកស្មើគ្នា គឺទាំងធម៌មានអាសវៈ ទាំងមិនមានអាសវៈ ព្រះមានព្រះភាគទ្រង់សម្តែងថា បញ្ចក្ខន្ធ ដោយមិនផ្សេងគ្នា តែដើម្បីទ្រង់ចង្អុលប្រាប់នូវភូមិវិបស្សនា ក៏ត្រាស់ថា ធម៌មានអាសវៈប៉ុណ្ណោះ ជាឧបាទានក្ខន្ធ ដូចជាថា ក្នុងធម៌មានរូបជាដើមមាន

អាសវៈក៏មាន មិនមានអាសវៈក៏មាន យ៉ាងណា រូបទីងជា យ៉ាងនោះ មិនមានទេ ព្រោះរូបជាកាមាវចរៈតែម្យ៉ាង ។ តែ បណ្ឌិតគប្បីឃើញថា រូបនោះ ដែលទ្រង់សម្តែងទុកក្នុង ខន្ធទាំងឡាយ ដោយអំណាចនៃធម៌ជាកង ដែលមានចំណែក ស្មើគ្នា ចំណែករូបទ្រង់សម្តែងទុកក្នុងឧបាទានក្ខន្ធ ដោយ ជាទីតាំងនៃឧបាទាន និង(ជាទីតាំង) នៃរាសី (គំនរ) ។

## អង្គធម៌ ឧបាទានក្ខន្ធ

១- រូបូបាទានក្ខន្ធ[១] បានដល់ រូប ២៨

២- វេទនូបាទានក្ខន្ធ បានដល់ វេទនាចេតសិកនៅក្នុង

---

១. ព្រះសូត្រសម្តែងរូប ១១ ពួកមានរូបអតីតជាដើម ក្នុងព្រះអភិធម្ម សម្តែង រូប ៣ ខណៈ គឺ ឧប្បាទៈ ឋិតិ ភង្គៈ ចូរពិនិត្យសេចក្តី ពិស្តារក្នុងគម្ពីរវិភង្គ ។

លោកិយចិត្ត ៨១ ។

៣- សញ្ញុបាទានក្ខន្ធ បានដល់ សញ្ញាចេតសិកនៅក្នុង លោកិយចិត្ត ៨១ ។

៤- សង្ខារុបាទានក្ខន្ធ បានដល់ ចេតសិក ៥០ នៅក្នុង លោកិយចិត្ត ៨១ ។

៥- វិញ្ញាណុបាទានក្ខន្ធ បានដល់ លោកិយចិត្ត ៨១ ។

## អធិប្បាយ អាយតនៈ ១២

ចិត្តនិងចេតសិក ដែលមានអារម្មណ៍ក្នុងទ្វារនោះ ៗ រមែងខ្វល់ខ្វាយ គឺ រមែងបន្ត បានដល់ រមែងព្យាយាម ដោយកិច្ច មានការសោយអារម្មណ៍ជាដើមនោះ ៗ ក្នុងចក្ខុនិងរូបជាដើមនេះ ព្រោះហេតុនោះ ចក្ខុនិងរូបជាដើមនោះ ទើបឈ្មោះថា អាយតនៈ ។

មួយទៀត ចក្ខុនិងរូបជាដើមនេះ រមែងផ្សព្វផ្សាយ គឺ រមែងពង្រីកធម៌ទាំងនោះ ឱ្យទូលំទូលាយទៅ ព្រោះដូច្នោះ

ចក្ខុនិងរូបជាដើមនេះ ទើបឈ្មោះថា អាយតនៈ ។

មួយទៀត ចក្ខុនិងរូបជាដើម រមែងនាំទៅនូវសង្សារទុក្ខដ៏វែងឆ្ងាយ គឺ រមែងឱ្យប្រព្រឹត្តបន្តបន្ទាប់ទៅ ព្រោះដូច្នោះ ទើបឈ្មោះថា **អាយតនៈ ។**

ម្យ៉ាងទៀត ឈ្មោះថា **អាយតនៈ** ព្រោះអត្ថថា ជាការណៈ គឺ ជាហេតុនៃចក្ខុវិញ្ញាណជាដើម ។

ន័យមួយទៀត ក្នុងផ្លូវលោក **ស្ថានទីនៅ អណ្តូងកើត ទីប្រជុំ និង កន្លែងកំណើត** គេហៅថា **អាយតនៈ** ព្រោះដូច្នោះ ចក្ខុជាដើមនោះ ឈ្មោះថា អាយតនៈ ព្រោះជាស្ថានទីនៅនៃចក្ខុវិញ្ញាណជាដើម ដែលប្រព្រឹត្តទៅក្នុងទ្វារ និងអារម្មណ៍នោះៗ ។ ឈ្មោះថា អាយតនៈ ព្រោះជាអណ្តូងកើតនៃចក្ខុវិញ្ញាណ ជាដើមនុ៎ះឯង ដែលប្រព្រឹត្តទៅយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ឈ្មោះថា អាយតនៈ ព្រោះជាទីប្រជុំនៃចក្ខុវិញ្ញាណជាដើម ដែលប្រជុំគ្នាតាមទ្វារ និង

អារម្មណ៍ ។ និង ឈ្មោះថា **អាយតនៈ** ព្រោះជាកន្លែងកើតរបស់ចក្ខុវិញ្ញាណជាដើម ដែលកើតនៅក្នុងទ្វារ និងអារម្មណ៍នុ៎ះឯង ។

អាយតនៈទាំងនោះ មាន ១២ យ៉ាង គឺ អាយតនៈខាងក្នុងដែលជាទ្វារ មាន ៦ យ៉ាង ចំណែកខាងក្រៅក៏មានអារម្មណ៍ ៦ យ៉ាង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលពាក្យថា "ចក្ខាយតនៈ"ជាដើម ។ ក្នុងពាក្យនេះមានវិគ្រោះស័ព្ទថា "ចក្ខុនោះផង ជាអាយតនៈផង ព្រោះដូច្នេះទើបឈ្មោះថា ចក្ខាយតនៈ" ។ សូម្បីក្នុងពាក្យដែលនៅសល់ ក៏មានវិគ្រោះយ៉ាងនេះឯង ។

## លំដាប់អាយតនៈ ១២

អាយតនៈទាំង ១២ នោះ ពួកអាយតនៈ ខាងក្នុង (មានចក្ខាយតនៈ)ជាក់ច្បាស់ហើយ ព្រោះមានអារម្មណ៍ ជាសនិទស្សនៈ និងសប្បដិឃៈ ព្រោះដូច្នោះ ទើបព្រះមានព្រះ

ភាគត្រាស់ចក្ខាយតនៈទុកមុន ។ ត្រាស់អាយតនៈ ខាងក្រៅនេះ ដែលមានអារម្មណ៍ជាអនិទស្សនៈ និងសប្បដិឃៈ ទុកក្នុងលំដាប់នៃចក្ខាយតនៈនោះ ។

សូម្បីក្នុងអាយតនៈដែលនៅសល់ មានសោតាយតនៈជាដើមនោះ ទ្រង់ត្រាស់ទុកក្នុងលំដាប់នៃចក្ខាយតនៈ ព្រោះទទួលអារម្មណ៍ដែលមិនទាន់មកដល់បានដោយប្រក្រតី ។ បណ្តាអាយតនៈពីរក្រៅនេះ ត្រាស់ឃានាយតនៈទុកមុន ព្រោះអាចទទួលអារម្មណ៍បានរហ័ស, ពិតមែន ក្លិនរបស់ភោជនជាដើម គ្រាន់តែដាក់ទុកនៅខាងមុខភ្លាម ក៏ប៉ះខ្ទប់ឃានៈ (ប្រមុះ)បាន ដោយការហុយភាយទៅតាមខ្យល់ ។ ត្រាស់ជិវ្ហាយតនៈ ក្នុងលំដាប់នៃឃានាយតនៈ ព្រោះប្រព្រឹត្តទៅចំពោះទីដែលប៉ះខ្ទប់ ។ តពីនោះ ត្រាស់កាយាយតនៈដែលប្រព្រឹត្តទៅទូទាំងកាយគ្រប់កន្លែង ។ បន្ទាប់ពីនោះ ក៏ត្រាស់មនាយតនៈដែលអាចទទួលអារម្មណ៍របស់អាយតនៈ បានទាំង

៥ ។ ប៉ុន្តែ ក៏ត្រាស់អាយតនៈខាងក្រៅ ដែលជាអារម្មណ៍ មានរូបាយតនៈជាដើមនោះ ដោយលំដាប់នៃអាយតនៈដែលពោលមកហើយ ។

បណ្ដាអាយតនៈទាំង ១២ នោះ អាយតនៈ ១០ ខាងដើម ជារូបតែម្យ៉ាង, ធម្មាយតនៈ ជារូប ( សុខុមរូប ១៦ )ផង ជានាម ( គឺ ចេតសិក ៥២ និងនិព្វាន )ផង, ចំណែកមនាយតនៈជានាមតែម្យ៉ាង បានដល់ ចិត្តទាំងអស់ទុំះ ឯង ។

## អធិប្បាយ ធាតុ ១៨

ធម៌ពួកណា រមែងទ្រទ្រង់ទុកនូវសភាវលក្ខណៈរបស់ខ្លួន ព្រោះហេតុនោះ ធម៌ទាំងនោះ ឈ្មោះថា ធាតុ ។ វិគ្រោះនេះ បានទាំងលោកិយធាតុ និងលោកុត្តរធាតុ, ចំណែកធាតុជាលោកិយនោះ លោកសម្ដែងទុកមកដែលមានសេចក្ដីដូចតទៅនេះ ៖

ម្យ៉ាងទៀត ដែលឈ្មោះថា **ធាតុ** ព្រោះអត្ថថា ទ្រទ្រង់ទុកនូវសង្សារទុក្ខ ច្រើនអនេកប្រការ តាមសមគួរដល់ការកើត ។

មួយទៀត ឈ្មោះថា **ធាតុ** ព្រោះអត្ថថា ដែលសត្វទ្រទ្រង់ទុក គឺ លី( ឬរែក ) ទុក ដូចរបស់ធ្ងន់ដែលអ្នកលី( ឬរែក ) ត្រូវលី( ឬរែក )របស់ធ្ងន់នោះទៅ ដូច្នោះ ។

មួយទៀត ឈ្មោះថា **ធាតុ** ព្រោះអត្ថថា ត្រឹមតែជាការទ្រទ្រង់ទុកនូវសេចក្តីទុក្ខប៉ុណ្ណោះ ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច ។

មួយទៀត ឈ្មោះថា **ធាតុ** ព្រោះអត្ថថា ជាហេតុឱ្យសត្វត្រូវសោយនូវសង្សារទុក្ខ ។

មួយទៀត ឈ្មោះថា **ធាតុ** ព្រោះអត្ថថា ជាទីតាំងនៅ គឺ តម្រង់នៅនៃទុក្ខ មានប្រការយ៉ាងនោះ ។

មួយទៀត ឈ្មោះថា **ធាតុ** ព្រោះអត្ថថា ជាចំណែក

នៃធម៌ដែលគួរដឹង ដូចធាតុនៅក្នុងអវយវៈនៃរាងកាយដែលមានរស និងលោហិតជាដើម និងដូចធាតុ ចំណែកតូច ៗនៃវត្ថុខាងក្រៅ ដែលកើតពីសិលា មានថ្មជា និងមនោសិលាជាដើម ។

សមដូចពាក្យដែលលោកអាចារ្យទាំងឡាយ ពោលទុកថា ៖

ធម្មជាតិ ដែលបណ្ឌិតហៅថា ធាតុ ព្រោះអត្ថថា ទ្រទ្រង់ទុកនូវសង្សារទុក្ខ ។ មួយទៀត ការទ្រទ្រង់សង្សារទុក្ខទុក ក៏ហៅថា ធាតុ. មួយទៀត ឈ្មោះថា ធាតុ ព្រោះអត្ថថា ដែលពួកសត្វទ្រទ្រង់ទុក មួយទៀត ព្រោះអត្ថថា ជាហេតុធ្វើឱ្យពួកសត្វ ត្រូវសោយសង្សារទុក្ខ. មា៉ងទៀត ឈ្មោះថា ធាតុ ព្រោះអត្ថថា ជាទីតាំងនៅនៃសង្សារទុក្ខ មួយទៀត ព្រោះអត្ថថា ដូចជាធាតុ ចំណែកតូច ៗ នៃសរីរៈ និងចំណែកតូច ៗ នៃវត្ថុខាងក្រៅដែលកើតពីសិលា ។

ក៏ធាតុទាំងនោះ ព្រះមានព្រះភាគទ្រង់ចែកមនាយតនៈ ជា ៧ ប្រការ ដោយអំណាចនៃវិញ្ញាណធាតុ ៧ ហើយទើបត្រាស់ទុក ១៨ យ៉ាង រួមនឹងអាយតនៈ ១១ ដែលនៅសល់ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា "ចក្ខុធាតុ"ជាដើម ។

គប្បីជ្រាបលំដាប់នៃធាតុ តាមន័យនៃអាយតនៈ ។

<u>ក្នុងសម្មោហវិនោទនី</u> លោកសម្ដែងលំដាប់នៃធាតុទុកថា ៖

ព្រះមានព្រះភាគ ត្រាស់លំដាប់នៃធាតុ ដោយការកំណត់ហេតុ និងផល ពិតមែន ចក្ខុធាតុនិងរូបធាតុ ជាហេតុ ចក្ខុវិញ្ញាណធាតុ ជាផល, គឺ ចក្ខុធាតុ គប្បីឃើញដូចផ្ទៃស្គរ, រូបធាតុ ដូចអន្ទងវាយស្គរ, ចក្ខុវិញ្ញាណ ដូចសំឡេងស្គរ; បណ្ឌិតគប្បីជ្រាបបទទាំងពួងដោយន័យនេះឯង ។

## ធាតុមានច្រើនអនេកប្រការ

ធាតុតាមន័យព្រះសូត្រ និងព្រះអភិធម្ម សូម្បីធាតុដទៃ ៗ ក៏មានច្រើនអនេកប្រការ ដូចជាអាភាធាតុ, សុភធាតុ អាកាសានញ្ចាយតនធាតុជាដើម, សញ្ញាវេទយិតនិរោធធាតុ, កាមធាតុ, ព្យាបាទធាតុ, វិហឹង្សធាតុ, សង្ខតធាតុ, អសង្ខតធាតុ, និងលោកជាអនេកធាតុជាដើម ។

សួរថា បើធាតុមានច្រើនយ៉ាងនេះ ព្រោះហេតុអ្វី ទើបត្រាស់ទុកត្រឹមតែ ១៨ ប៉ុណ្ណោះ ។

ឆ្លើយថា អាភាធាតុ ក៏គឺ រូបធាតុនោះឯង, សុភធាតុក៏ជាធម៌ជាប់ដោយរូបធាតុ ចិត្តក្នុងអាកាសានញ្ចាយតនធាតុជាដើម បានដល់ មនោវិញ្ញាណធាតុ ធាតុដែលនៅសល់ជាធម្មធាតុ ចំណែកសញ្ញាវេទយិតនិរោធធាតុ ដោយសភាវៈ រមែងមិនមាន ។ មួយទៀត កាមធាតុ បានដល់ ធាតុ ១៨ ដូចដែលបានត្រាស់ថា ខាងក្រោមតាំងពីអវចី ខាងលើកំណត់ទៅតាជាន់បរនិម្មិតវសវត្តីជាទីបំផុត ក្នុងរវាងនេះ ខន្ធ

អាយតនៈ និងធាតុ ១៨ ជាដើម យ៉ាងណា ត្រាច់អន្ទោល ទៅមកក្នុងទីនេះ រាប់បញ្ចូលក្នុងខេត្តនេះ ធម៌នេះ ហៅថា **កាមធាតុ** ។ ក៏ធម្មធាតុនោះ មួយចំណែកជាសង្ខតធាតុមួយចំណែកទៀត ជាអសង្ខតធាតុ, លោកជាអនេកធាតុ និងនានាធាតុ ក៏ជាប្រភេទរបស់ធាតុ ១៨ នុ៎ះឯង ដូច្នោះ ធាតុដែលជាសភាវៈ ព្រះអង្គទើបត្រាស់ទុក ១៨ ប៉ុណ្ណោះ[១] ។

## ទ្រង់សម្ដែងធាតុដកអត្តានុទិដ្ឋិ

ម្យ៉ាងទៀត ទ្រង់សម្ដែងធាតុ ១៨ ដើម្បីដកការយល់ខុសថា មានជីវាត្មន់ក្នុងវិញ្ញាណដែលមានការដឹងអារម្មណ៍ ទ្រង់ប្រាថ្នានឹងដកឡើងនូវសេចក្ដីសំគាល់ថា មានជីវាត្មន់ដែលដេកត្រាំជាប់នៅរឿយ ៗ អស់កាលដ៏យូរ វែងឆ្ងាយរបស់សត្វទាំងនោះ ទើបទ្រង់ត្រាស់ប្រកាសសេចក្ដីមានច្រើនយ៉ាង

---

១. សំយុ. និទា. ៣២. ១/១ ធាតុ ១៦ ខាងដើមជាកាមាវចរ ធាតុ ២ ខាងចុងប្រព្រឹត្តទៅក្នុងភូមិ ៤ ។

នៃធាតុទាំងនោះ ដោយចែកជាចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណធាតុ មនោវិញ្ញាណធាតុ និងទ្រង់ប្រកាស សេចក្ដីដែលធាតុទាំងនោះ ជារបស់មិនទៀងជាដើម ព្រោះត្រូវប្រព្រឹត្តទៅដោយបច្ច័យមានចក្ខុ និងរូបជាដើម ទើបមាន, ចំណែកធម៌ដទៃ នឹងជាធម៌ទៀតទៀនជាដើមមិនមាន ទ្រង់ប្រកាសធាតុទុក ១៨ យ៉ាង ។ មួយទៀត ហេតុដទៃដែលក្រៃលែងជាងនេះ ក៏ដោយអធ្យាស្រ័យរបស់សត្វ ដែលនឹងត្រាស់ដឹង ដោយទ្រង់សម្ដែងធម៌ដែលមិនសង្ខេប និងមិនពិស្ដារលើសពីនេះ ដោយពិតទុំះឯង ។

## អធិប្បាយ អរិយសច្ចៈ ៤

ធម្មជាតិ មានទុក្ខជាដើម ឈ្មោះថា អរិយៈ ព្រោះការធ្វើភាពជាអរិយៈ, ឈ្មោះថា សច្ចៈ ព្រោះជារបស់ពិត ព្រោះដូច្នោះ ទុក្ខជាដើមនោះ ទើបឈ្មោះថា អរិយសច្ចៈ ។

ពិតមែន សច្ចៈទាំង ៤ នេះ រមែងធ្វើឱ្យសម្រេចជា

ព្រះអរិយបុគ្គល ៨ ពួក គឺ ព្រះអរិយៈ (អ្នកតាំងនៅក្នុងមគ្គ ៤ ពួក និងអ្នកតាំងនៅក្នុងផល ៤ ពួក គឺ ព្រោះថា កាលមិនមានការត្រាស់ដឹងសច្ចៈ បុគ្គលទាំងនោះ ក៏មិនចូលដល់ភាពជាព្រះអរិយៈ និងកាលមានការត្រាស់ដឹងសច្ចៈនោះ បុគ្គលទាំងនោះ ទើបចូលដល់ភាពជាព្រះអរិយៈបានដោយពិត ៗ ក៏សេចក្តីដែលទុក្ខ ជាធម្មជាតិបៀតបៀន, សមុទយជាដែនកើត, និរោធជាធម៌រលាស់ចេញ និងមគ្គជាធម៌នាំចេញ ប៉ុណ្ណោះឡើយ; តែទុក្ខជាដើម នឹងមិនបៀតបៀនជាដើម ក៏មិនមានព្រោះហេតុនោះ ទុក្ខជាដើមនោះ ទើបឈ្មោះថា ជារបស់ពិតដោយលក្ខណៈ ពោលគឺ ការបៀតបៀនជាដើម ដែលមិនមាននៅក្នុងធម៌ដទៃ និងប្រាកដក្នុងសច្ចៈ មានទុក្ខជាដើមនោះ ព្រោះហេតុនោះ ទើបព្រះបូរាណាចារ្យពោលទុកថា ៖

**សច្ចៈ ៤ មានទុក្ខជាដើម រមែងឱ្យសម្រេចជាព្រះអរិយបុគ្គល ៤ ពួក អ្នកកំពុងកាត់នូវមន្ទិល និង**

ព្រះអរិយបុគ្គល ៤ ពួក អ្នកដាច់អស់ទោសហើយ តាមសមគួរដល់ការត្រាស់ដឹង ព្រោះការបៀតបៀនជាដើម នឹងមិនមានក្នុងពួកធម៌ដទៃក្រៅពីទុក្ខជាដើមទាំងនេះ ការដែលទុក្ខជាដើមទាំងនេះ និងមិនបៀតបៀនជាដើម ក៏មិនមាន ព្រោះហេតុនោះឯង ទុក្ខជាដើមទាំងនេះ ទើបឈ្មោះថា ជាសច្ចៈ ពិត ។

ម្យ៉ាងទៀត សច្ចៈរបស់ព្រះអរិយៈ ឈ្មោះថា អរិយសច្ចៈ ព្រោះជាសច្ចៈ ដែលលោកទាំងនោះ គប្បីត្រាស់ដឹង, ម្យ៉ាងទៀត សច្ចៈរបស់ព្រះសម្មាសម្ពុទ្ធអ្នកជាអរិយៈ ព្រោះជាសច្ចៈដែលព្រះអង្គ ទ្រង់សម្ដែងទុក ព្រោះហេតុនោះ ទើបឈ្មោះថា អរិយសច្ចៈ ។ ក៏អរិយសច្ចៈនោះ មាន ៤ ដោយអំណាចនៃផល និងហេតុដែលសៅហ្មង និងមិនសៅហ្មង[១]

---

១. ផលដែលសៅហ្មង គឺ ទុក្ខសច្ចៈ ហេតុដែលសៅហ្មង គឺ សមុទ័យ, ដែលនៅសល់ ក៏ទំនងនេះឯង ។

ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **"អរិយសច្ចៈ ៤"** ដូច្នេះ ។

## វិគ្រោះសព្ទ អរិយសច្ចៈ ៤

សច្ចៈទី ១ ឈ្មោះថា **ទុក្ខ** ព្រោះជាធម៌ដែលបណ្ឌិតស្អប់ខ្ពើម និងព្រោះជារបស់សោះសូន្យទទេ ។

សច្ចៈទី ២ ឈ្មោះថា **សមុទយ** ព្រោះជានិមិត្តនៃការកើតទុក្ខ ក្នុងពេលមានការតាំងមាំនៃបច្ច័យ មានកម្មជាដើម ដោយធ្វើវិគ្រោះថា ទុក្ខរមែងកើតអំពីតណ្ហានេះ ជាហេតុនាំឱ្យកើតនៃទុក្ខ ទើបឈ្មោះថា ទុក្ខសមុទយ ។ ការរលត់ គឺការមិនកើតឡើងនៃទុក្ខ ក្នុងព្រះនិព្វាននេះ ឬដោយព្រះនិព្វាននេះ ព្រោះហេតុនោះ ការរលត់ គឺ ការមិនកើតឡើងនៃទុក្ខនោះ ទើបឈ្មោះថា **ទុក្ខនិរោធ** ។ ធម្មជាតិ ដែលឈ្មោះថា **ទុក្ខនិរោធគាមិនីបដិបទា** ព្រោះអត្ថថា ដល់សេចក្តី រលត់ទុក្ខ និងជាហេតុដំណើរឆ្ពោះទៅកាន់សេចក្តីរលត់ទុក្ខនោះ ។

## អធិប្បាយ បកិណ្ណកធម៌

ធម៌ ៦៩ យ៉ាង គឺ ចេតសិក ៥២ សុខុមរូប ១៦ និព្វាន ១ រមែងដល់ការរាប់ថា ជាធម្មាយតនៈ ក្នុងពួកអាយតនៈ និងដល់ភាពជាធម្មធាតុក្នុងពួកធាតុ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះអង្គទ្រង់ចែកវេទនា និង សញ្ញា ទុកជាខន្ធមួយផ្នែក ។

ឆ្លើយថា ព្រោះវេទនាជាធម៌ដែលត្រេកអរក្នុងវដ្តៈ និងសញ្ញាជាធម៌ជួយឧបត្ថម្ភគាំទ្រវេទនានោះ ។

ពិតមែន វេទនា ប្រព្រឹត្តទៅដោយអំណាចសេចក្តីត្រេកអរក្នុងធម៌ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ និងប្រព្រឹត្តទៅដោយអាការនៃសេចក្តីត្រេកអរនោះ ដោយអំណាចសញ្ញាវិបល្លាស គឺ សេចក្តីសំគាល់ខុសថា ល្អស្អាត ក្នុងរបស់ដែលមិនល្អស្អាតជាដើម ព្រោះហេតុនោះ សញ្ញា ទើបជាធម៌ ជួយឧបត្ថម្ភគាំទ្រដល់វេទនានោះ ព្រោះហេតុនេះ ទើប

ព្រះមានព្រះភាគទ្រង់ចែកវេទនា និងសញ្ញានេះ (ចេញពីចេតសិកទាំងឡាយ) ព្រោះហេតុថា ជាប្រធាននៃសង្ខារ ។

ពិតណាស់ ដូចពាក្យដែលលោកអាចារ្យពោលទុកថា **ដើម្បីទ្រង់ចែកសម្តែងនូវចំណែក ដែលត្រេកអរក្នុងវដ្តធម៌ និងចំណែកដែលរង់ចាំជួយឧបត្ថម្ភ គាំទ្រធម៌ដែលត្រេកអរនោះទុកផ្សេងពីគ្នា ទើបព្រះមានព្រះភាគទ្រង់លើកខន្ធ ២ (វេទនានិងសញ្ញា) ឡើងសម្តែងទុក ។**

## សម្តែងនិរោធសច្ចៈ ផុតចាកខន្ធ

លោកអាចារ្យធ្វើទុកក្នុងចិត្តថា "ក៏ព្រះនិព្វាន ព្រះមានព្រះភាគ ទ្រង់សង្គ្រោះចូលក្នុងអាយតនៈ និងធាតុមិនមែនឬ ? ព្រោះហេតុអ្វី ទើបមិនសង្គ្រោះចូលក្នុងខន្ធផង ?" ដូច្នេះ, ទើបពោលពាក្យជាដើមថា "ព្រោះព្រះនិព្វានមិនមានប្រភេទ"

ដូច្នេះ ។ ព្រោះថា ការបញ្ញត្តិថា ខន្ធ ដោយអត្ថ គឺ ការប្រជុំគ្នានៃធម៌ ដែលមានការផ្សេងគ្នានៃកាល មានអតីតកាលជាដើម ព្រោះដូច្នោះ ព្រះនិព្វាន ទើបផុតចាកការសង្គ្រោះជាខន្ធ ព្រោះមិនមានការចែកជាប្រភេទ ។

អាយតនៈ មាន ១២ ដោយការផ្សេងគ្នានៃទ្វារ ៦ និងអារម្មណ៍ ៦ ។ ធាតុមាន១៨ ដោយបរិយាយ គឺដោយលំដាប់នៃទ្វារ ៦ អារម្មណ៍ ៦ និង វិញ្ញាណដែលអាស្រ័យទ្វារ និងអារម្មណ៍ទាំង ២ នោះកើត ក៏មាន ៦ ដូចគ្នា ។

## សម្តែងវដ្តៈនៃទុក្ខសច្ចៈជាដើម

ភូមិនៃវដ្តៈនេះ មាន ៣ ( គឺ កាមភូមិ រូបភូមិ អរូបភូមិ ) ព្រោះហេតុនោះ វដ្តៈនោះ ទើបមានភូមិ ៣ គឺប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ដែលឈ្មោះថា វដ្តៈព្រោះអត្ថថា ជាទីប្រព្រឹត្តទៅនៃកម្មនិងវិបាកនៃកម្មនោះ ។

ទុក្ខសមុទ័យ គឺ តណ្ហា ។ បទថា **តណ្ហា** បានដល់

តណ្ហា ៣ គឺ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ តណ្ហា ១០៨ គឺ តណ្ហា ៣ នុ៎ះឯង ប្រព្រឹត្តទៅក្នុងអារម្មណ៍ ៦ ។ តណ្ហា ៥៤ គឺ តណ្ហា ១៨ ប្រព្រឹត្តទៅដោយអំណាចនៃកាល ៣ មានអតីតកាលជាដើម និងតណ្ហា ១០៨ គឺ តណ្ហាដែលជាចំណែកខាងក្នុង(អជ្ឈត្តិកៈ) និងប្រព្រឹត្តទៅក្នុងចំណែកខាងក្រៅ(ពាហិរៈ) ។

សួរថា កាលបើធម៌ដទៃ មានអវិជ្ជាជាដើមដែលជាហេតុនៃទុក្ខ ក៏មានច្រើន ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ត្រឹមតែតណ្ហាប៉ុណ្ណោះថា ជាសមុទយៈ (ហេតុឱ្យកើតទុក្ខ) ។

ឆ្លើយថា ព្រោះតណ្ហាជាហេតុ និងជាប្រធាន ។

ពិតមែន តណ្ហា ជាហេតុពិសេសនៃទុក្ខ ព្រោះជាហេតុនៃកម្មដែលវិចិត្រ ព្រោះចូលដល់ភាពជាមិត្តសម្លាញ់នៃកម្ម និងព្រោះជាហេតុនៃទុក្ខដ៏ច្រើនប្រការនុ៎ះឯង ។

## សម្ដែងអរិយមគ្គ

ក្នុងពាក្យថា "មគ្គ" បណ្ឌិតគប្បីប្រកបមគ្គសព្ទដទៃទៀតថា មគ្គ ដែលលោកពោលដោយឈ្មោះថា និរោធគាមិនីបដិបទា លោកហៅថា លោកុត្តរមគ្គ ។

ក្នុងសច្ចវិភង្គ សម្ដែងសេចក្ដីឧបមាសច្ចៈទាំង ៤ ថា

**ភារោ វិយ ហិ ទុក្ខសច្ចំ ទដ្ឋព្វំ. ភារាទានមិវ សមុទយសច្ចំ. ភារនិក្ខេបនមិវ និរោធសច្ចំ. ភារនិក្ខេបនូបាយោ វិយ មគ្គសច្ចំ ។ រោគោ វិយ ច ទុក្ខសច្ចំ. រោគនិទានមិវ សមុទយសច្ចំ. រោគវូបសមោ វិយ និរោធសច្ចំ. ភេសជ្ជមិវ មគ្គសច្ចំ ។ ទុព្ភិក្ខមិវ វា ទុក្ខសច្ចំ. ទុព្វុដ្ឋិ វិយ សមុទយសច្ចំ. សុភិក្ខមិវ និរោធសច្ចំ សុវុដ្ឋិ វិយ មគ្គសច្ចំ ។**

ពិតមែន ទុក្ខសច្ចៈ បណ្ឌិតគប្បីឃើញដូចជាភារៈ, សមុទយសច្ចៈ ដូចជាការកាន់យកភារៈ, និរោធសច្ចៈ ដូចជាការដាក់ចុះនូវភារៈ, មគ្គសច្ចៈ ដូចជាឧបាយជាគ្រឿងការដាក់

ចុះនូវភារៈ ។ ម្យ៉ាងទៀត ទុក្ខសច្ចៈ គប្បីឃើញដូចជារោគ, សមុទយសច្ចៈ ដូចជាហេតុនាំឱ្យកើតរោគ, និរោធសច្ចៈ ដូចជាការស្ងប់រម្ងាប់រោគ, មគ្គសច្ចៈ ដូចជាថ្នាំព្យាបាលរោគ ។ មួយវិញទៀត ទុក្ខសច្ចៈ គប្បីឃើញដូចជាស្រុកអត់បាយ, សមុទយសច្ចៈ ដូចជាការរាំងភ្លៀង, និរោធសច្ចៈ ដូចជាស្រុកសម្បូរណ៍បាយ, មគ្គសច្ចៈ ដូចជាការធ្លាក់ភ្លៀងមកដោយល្អ ។

## សម្តែងសច្ចវិមុត្ត

ធម៌ទាំងនេះ គឺ ធម៌មានផស្សៈជាដើមដែលប្រកបដោយមគ្គ គឺ ដែលសម្បយុត្តដោយមគ្គ ដែលនៅសល់ក្រៅពីអង្គ ៨ និងផលព្រមដោយធម៌ដែលសម្បយុត្ត ផុតចាកសច្ចៈ ៤ ដោយនិប្បរិយាយ (គឺ មគ្គចិត្តុប្បាទ ២៩ ផលចិត្តុប្បាទ ៣៧) ។

តែដោយបរិយាយ (ដោយអម) ព្រោះហេតុដែល

លោកពោលថា **“មគ្គង្គំ ឈានង្គំ”** ទុក សូម្បីក្នុងនិទ្ទេសនៃអញ្ញាតាវិន្ទ្រិយ ទើបអាចធ្វើការសង្គ្រោះសម្មាទិដ្ឋិជាដើម ក្នុងផលធម៌ចុះក្នុងមគ្គសច្ចៈ និងមគ្គផល សម្បយុត្តធម៌ក្រៅពីនេះ ចុះក្នុងទុក្ខសច្ចៈ ដែលជាសង្ខារទុក្ខដូចគ្នា ព្រោះថាកាលមានការសង្គ្រោះយ៉ាងនេះ សូម្បីកាលសម្តែងសច្ចៈ ជាសព្វសង្គាហិក គឺ សង្គ្រោះធម៌ទាំងពួង ក៏ឱ្យកើតឡើងបាន ។

សួរថា ព្រោះហេតុអ្វី បានជាលោកអាចារ្យពោលធម៌មានខន្ធជាដើម ទុកច្រើនម្ល៉េះ ?

ឆ្លើយថា ព្រោះធម៌ទាំងនោះ ព្រះមានព្រះភាគ ទ្រង់សម្តែងទុកច្រើនយ៉ាងនេះ ដូចគ្នា ។

សួរថា ព្រោះហេតុអ្វី ទើបទ្រង់សម្តែងធម៌ទុកច្រើនយ៉ាងនោះ ?

ឆ្លើយថា ព្រោះទ្រង់ប្រាថ្នាអនុគ្រោះសត្វ ៣ ពួក ។

ពិតមែន សត្វមាន ៣ ពួក ដោយអំណាចសេចក្តី

ល្ងង់ខ្លៅ ក្នុងនាម ១ ក្នុងរូប ១ និងក្នុងនាមរូប ១, ដោយអំណាចឥន្ទ្រិយចាស់ក្លា ១ មិនទាន់ចាស់ក្លា ១ ទន់ ១, និងដោយអំណាចពេញចិត្តធម៌សង្ខេប ១ កណ្តាល ១ និងពិស្តារ ១ ។

បណ្តាវេនេយ្យសត្វទាំង ៣ នោះ សត្វល្ងង់ខ្លៅក្នុងនាម ក៏នឹងកាន់យក គឺ កំណត់ដឹងខន្ធបាន ព្រោះក្នុងខន្ធនោះ បែងចែកនាមទុក ៤ យ៉ាង ។ សត្វអ្នកល្ងង់ខ្លៅក្នុងរូបនឹងកាន់យក គឺ កំណត់ដឹងបានក្នុងអាយតនៈ ព្រោះបែងចែករូប ១០ និងកន្លះ (១០½) អាយតនៈទៀត ។ សត្វល្ងង់ខ្លៅក្នុងនាម និងរូបទាំងពីរ នឹងយល់នូវធាតុបាន ព្រោះបែងចែកនាម និងរូបទាំង ២ ទុកក្នុងពួកធាតុនោះ ដោយពិស្តារ ។

មួយទៀត បណ្ឌិតគប្បីប្រកបពាក្យថា សត្វអ្នកមានឥន្ទ្រិយចាស់ក្លា នឹងពេញចិត្តក្នុងធម៌សង្ខេប នឹងយល់ដឹងនូវខន្ធដូច្នេះជាដើម និងគប្បីឃើញថា ខន្ធ អាយតនៈ ធាតុទាំង

៣ នេះ នាំមកនូវឧបការៈប្រចក្សដោយអំណាចនៃទុក្ខសច្ចៈ និរោធសច្ចៈ និងហេតុនៃទុក្ខ គឺ សមុទយសច្ចៈ និងហេតុនៃនិរោធៈ គឺ មគ្គសច្ចៈ មិនមែនប្រព្រឹត្តទៅដោយប្រការដទៃទេ ព្រោះដូច្នោះ វេនេយ្យសត្វ ទើបកាន់យក គឺ ដឹងសច្ចៈ បាន ។

**ចប់ សព្វសង្គហៈពួកទី៤**

# សំនួរ-ចម្លើយក្នុងសព្វសង្គហៈ

១- សំ. ក្នុងសព្វសង្គហៈនោះ មានធម៌ប៉ុន្មានពួក ? អ្វីខ្លះ ? រួមទាំងអស់មានប៉ុន្មានប្រភេទ ? អ្វីខ្លះ ? ចូរសម្តែងអត្ថន័យ និងអង្គធម៌ក្នុងពួកដូចតទៅនេះ ខន្ធ៥ ឧបាទានខន្ធ៥ អាយតនៈ១២ ធាតុ១៨ អរិយសច្ចៈ៤ ។

ចំ. ក្នុងសព្វសង្គហៈនោះ មានធម៌ ៥ ពួក គឺ ១.ខន្ធ ២.ឧបាទានខន្ធ ៣.អាយតនៈ ៤.ធាតុ ៥.អរិយសច្ចៈ ។

សម្តែងអត្ថន័យ និងអង្គធម៌ក្នុងពួកនោះ ៗ មានដូច្នេះ

១- ខន្ធ ៥ គឺ ។ល ។

២-ឧបាទានខន្ធ ៥ គឺ ។ល ។

៣-អាយតនៈ ១២ គឺ ។ល ។

៤- ធាតុ ១៨ គឺ ។ល ។

៥-អរិយសច្ចៈ ៤ គឺ ។ល ។

២- សំ. ចូរប្រែគាថា ទាំងពីរ ដូចតទៅនេះ

១- រូបញ្ច វេទនា សញ្ញា ។ល ។ បញ្ចក្ខន្ធាតិ ភាសិតា ។
២- បញ្ចុបាទានក្ខន្ធាតិ ។ល ។ ខន្ធសង្គហនិស្សដ្ឋំ ។[១]

ចំ. ក្នុងគាថាទាំងពីរនេះ មានសេចក្ដីប្រែថា

១. អ្នកសិក្សាទាំងឡាយ គប្បីសម្ដែងធម៌ ទាំង៥ នេះ គឺ រូប វេទនា សញ្ញា និងចេតសិកដែលនៅសល់ ៥០ ( សង្ខារ ) និងវិញ្ញាណ ទាំងនេះថា ខន្ធ ៥ ។

២. អ្នកសិក្សាទាំងឡាយ គប្បីជ្រាប រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ដែលកើតនៅក្នុងភូមិទាំង ៣ ថា ឧបាទានក្ខន្ធ៥ ចំណែកព្រះនិព្វានផុតចាកខន្ធ ទាំង៥ ព្រោះមិនមានប្រភេទ( ១១ ) ដែលផ្សេងគ្នា ដូចបច្ចុប្បន្ន អតីត អនាគត ជាដើម ។

៣- សំ. ក្នុងបរមត្ថធម៌ ៤ ប្រការ ចែកជាអាយតនៈ

---

១. នៅទំព័រ ១៥៥ ។

១២ ជាធាតុ១៨ ជាដើមដូច្នេះ ព្រោះអាស្រ័យអ្វី ? ចូរអធិប្បាយព្រមទាំងលើកបាលីមកជាសាធកៈផង

ចំ. ក្នុងបរមត្ថធម៌ ៤ ប្រការ ចែកជាអាយតនៈ ១២ នោះ ព្រោះអាស្រ័យមានប្រភេទផ្សេងគ្នានៃទ្វារ៦ អារម្មណ៍៦ អធិប្បាយថា ពាក្យថា អាយនៈនេះ មានន័យថា រមែងធ្វើនូវចិត្ត និងចេតសិក គឺវិថីចិត្តឱ្យទូលំទូលាយចម្រើនឡើង ធម៌ទាំងនេះ មាន ២ យ៉ាង គឺ ទ្វារ និងអារម្មណ៍ ចាត់ជា ១២ ប្រភេទ គឺ

១. កាលរូបារម្មណ៍មកប្រាកដក្នុងចក្ខុទ្វារ ចក្ខុទ្វារវិថី រមែងកើតឡើងច្រើនវិថី ដូច្នោះ ចក្ខុទ្វារ និងរូបារម្មណ៍ ទាំងពីរនេះ ក៏ចាត់ជាចក្ខាយតនៈ និងរូបាយតនៈ ដូច្នេះជាដើម ។ល ។

៦. កាលធម្មារម្មណ៍មកប្រាកដក្នុងមនោទ្វារ មនោទ្វារវិថី រមែងកើតឡើងច្រើនវិថី ដូច្នោះ មនោទ្វារ និងធម្មារម្មណ៍ ទាំងពីរនេះ ក៏ចាត់ជាមនាយតនៈ និងធម្មាយតនៈ ។

តាំងពីចក្ខុទ្វារ និងរូបារម្មណ៍ ដរាបដល់កាយទ្វារ និង

ផោដ្ឋព្វារម្មណ៍ទាំង៥នេះ ចាត់ជាអាយតនៈដោយត្រង់, តែការចាត់មនោទ្វារ និងធម្មារម្មណ៍ ជាអាយតនៈនោះ ជាការចាត់ ដោយអម ព្រោះថា មនោទ្វារនេះ បានដល់ វិភង្គចិត្ត ១៩ ប៉ុណ្ណោះ តែសម្រាប់មនាយតនៈនោះ បានដល់ចិត្តទាំងអស់ ដូច្នោះមនោទ្វារនេះ ទើបបានត្រឹមតែមួយចំណែករបស់មនាយតនៈនេះ ជាការចាត់ដោយឯកទេសយូបចារន័យ, ចំណែកធម្មារម្មណ៍នោះ ទូលំទូលាយជាងធម្មាយតនៈ ព្រោះធម៌ដែលជាធម្មាយតនៈនេះ បានត្រឹមតែជាចំណែក មួយរបស់ធម្មារម្មណ៍ ហេតុនេះជាការចាត់ធម្មារម្មណ៍ ជាមនាយតនៈនេះ ទើបជាការចាត់ដោយបរិយាយន័យ,

ក្នុងបរមត្ថធម៌ ៤ប្រការ ចែកជាជាធាតុ មាន១៨នោះ ព្រោះអាស្រ័យទ្វារ៦ អារម្មណ៍៦ និងវិញ្ញាណ៦ ។

អធិប្បាយ ពាក្យថា ធាតុ មានន័យថា ធម្មជាតិដែលទ្រទ្រង់ទុកនូវសភាពរបស់ខ្លួន មិនមានការប្រែប្រួលធម៌

ទាំងនេះ មាន ៣ យ៉ាង គឺ

១. ទ្វារ មានសភាពទ្រទ្រង់ទុកនូវការទទួលអារម្មណ៍

២. អារម្មណ៍ មានសភាពទ្រទ្រង់ទុកនូវការប្រាកដឡើង ក្នុងទ្វារនោះ

៣. វិញ្ញាណ៦ មានសភាពទ្រទ្រង់ទុកនូវការដឹងអារម្មណ៍ មានការឃើញជាដើម ។

ចាត់ជា ១៨ ប្រភេទ គឺ

១. កាលរូបារម្មណ៍ មកប្រាកដក្នុងចក្ខុទ្វារហើយ ចក្ខុវិញ្ញាណ រមែងកើតឡើង ដូច្នោះ ចក្ខុទ្វារ រូបារម្មណ៍ និង ចក្ខុវិញ្ញាណ ទាំងបីនេះ ក៏ចាត់ជាចក្ខុធាតុ រូបធាតុ និង ចក្ខុវិញ្ញាណធាតុ ដូច្នេះជាដើម ។ ។ល ។

៦. កាលធម្មារម្មណ៍មកប្រាកដក្នុងផ្លូវមនោទ្វារហើយ មនោវិញ្ញាណរមែងកើតឡើង ដូច្នោះ មនោទ្វារ ធម្មារម្មណ៍ និង មនោវិញ្ញាណ ទាំងបីនេះ ក៏ចាត់ជាមនោធាតុ ធម្មធាតុ និង

មនោវិញ្ញាណធាតុ ។

តាំងពីចក្ខុទ្វារ រូបារម្មណ៍ និងចក្ខុវិញ្ញាណធាតុ ដរាបដល់កាយទ្វារ ផោដ្ឋព្វារម្មណ៍ និងកាយវិញ្ញាណទាំងនេះ ចាត់ជាធាតុដោយត្រង់, តែការចាត់មនោទ្វារ និងធម្មារម្មណ៍ ជាមនោធាតុ និងធម្មធាតុនោះ ជាការចាត់ដោយអម ព្រោះថាមនោទ្វារនោះ បានដល់ ភវង្គចិត្ត ១៩ ចំណែកមនោធាតុ បានដល់ ចិត្ត ៣ ប៉ុណ្ណោះ គឺ បញ្ចទ្វារាវជ្ជនចិត្ត ១ សម្បដិច្ឆន្នចិត្ត ២ នេះ ជាការចាត់ដោយបរិយាយន័យ, សម្រាប់ធម្មារម្មណ៍ដែលចាត់ជាធម្មធាតុនោះ មានន័យដូចគ្នា នឹងធម្មាយតនៈដែរ, ចំណែកមនោវិញ្ញាណចាត់ជាមនោវិញ្ញាណ ធាតុនោះ ជាការចាត់ដោយត្រង់, តែមនោវិញ្ញាណ មិនមែន ដឹងត្រឹមតែធម្មារម្មណ៍ទេ, តែពោលដោយលំដាប់របស់ទ្វារ អារម្មណ៍ ដោយចំពោះ ៗប៉ុណ្ណោះ ។

មានបាលីជាសាធកៈថា ៖

ទ្វារាលម្ពនភេទេន  ភវន្តាយតនានិ ច
ទ្វារាលម្ពនតទុប្បន្ន  បរិយាយេន ធាតុយោ ។

អាយតនៈមានចំនួន១២ ព្រោះមានប្រភេទផ្សេងគ្នានៃទ្វារ៦ និងអារម្មណ៍៦ ធាតុមានចំនួន១៨ ដោយបរិយាយនៃទ្វារ៦ អារម្មណ៍៦ និងវិញ្ញាណ៦ ដែលកើតក្នុងទ្វារនិងអារម្មណ៍នោះ ។

៤- សំ. ចូរសម្តែងគាថា ដែលពោលដល់ការរាប់អង្គធម៌ ក្នុងអរិយសច្ចៈ ៤ ព្រមទាំងពាក្យប្រែ និងធម៌ដែលជាសច្ចៈ វិមុត្តនោះ មានប៉ុន្មាន ? អ្វីខ្លះ ?

ចំ. គាថា ដែលពោលដល់ការរាប់អង្គធម៌ក្នុងអរិយសច្ចៈ ៤ មានដូច្នេះ

ទុក្ខំ តេភូមិកំ វដ្ដំ  តណ្ហា សមុទយោ ភវេ
និរោធោ នាម និព្វានំ  មគ្គោ លោកុត្តរោ មតោ ។

អ្នកសិក្សាទាំងឡាយ គប្បីជ្រាបធម៌ដែលវិលវល់ ក្នុងភូមិទាំង ៣ នេះ ឈ្មោះថា ទុក្ខសច្ចៈ, តណ្ហា ឈ្មោះថា សមុទយសច្ចៈ, ព្រះនិព្វាន ឈ្មោះថា និរោធសច្ចៈ, អដ្ឋមគ្គ៨ ដែលនៅក្នុងលោកុត្តរមគ្គ ឈ្មោះថា មគ្គសច្ចៈ ។

មគ្គយុត្តា ផលា ចេវ     ចតុសច្ចវិនិស្សដា
ឥតិ បញ្ចប្បភេទេន     បវុត្តោ សព្វសង្គហោ ។

ធម៌ដែលជាសច្ចវិមុត្តិ ដែលប្រកបជាមួយ នឹងមគ្គ មានចំនួន ២៩ គឺ អញ្ញសមានា ១០ សោភណចេតសិក១៨ (វៀរអដ្ឋមគ្គ៨) និងមគ្គចិត្ត៤ (ចិត្ត៤រាប់តែ១) ហៅថា មគ្គចិត្តុប្បាទ ២៩; ដែលប្រកបជាមួយនឹងផល មានចំនួន៣៧ គឺ អញ្ញសមានា១៣ សោភណចេតសិក២៣ និង ផលចិត្ត៤ ហៅថា ផលចិត្តុប្បាទ៣៧ ។

៥- សំ. ពាក្យថា សព្វសង្គហៈ មានន័យយ៉ាង ណា ? និងបរិយាយនូវខន្ធ ដែលបាលីពោលទុកថា រាសដ្ឋេន រាសិអដ្ឋេន ខន្ធោ

ចំ. ពាក្យថា សព្វសង្គហៈ មានន័យថា ពួកដែលសម្ដែង ការសង្គ្រោះបរមត្ថធម៌ទាំងអស់ ឈ្មោះថា សព្វសង្គហៈ ។

បរិយាយនូវខន្ធដែលបាលីពោលទុកថា រាសដ្ឋេន រាសិអដ្ឋេន ខន្ធោ នោះ មានសេចក្ដីដូច្នេះ ឈ្មោះថា ខន្ធ ព្រោះអត្ថថា ជាក្រុម ជាកង ជាគំនរ គឺធម៌ដែលជាបច្ចុប្បន្ន អតីត អតីត អនាគត ១ ។ល ។

ដោយហេតុនេះ វេទនាចេតសិក១ និងសញ្ញាចេតសិក ១ ក៏ ជាវេទនាខន្ធ និងសញ្ញាខន្ធបាន ។

៦- សំ. ហេតុអ្វីបានជាលោកពោលថា និព្វានជា ខន្ធវិមុត្ត ? ចូរលើកហេតុផលមកអធិប្បាយឱ្យបានល្អិតល្អន់

ចំ. បានជាលោកពោលថា និព្វានជាខន្ធវិមុត្តនោះ ព្រោះ

ថា មិនមានប្រភេទដែលផ្សេងគ្នា ពោលគឺ និព្វានមិនមានប្រភេទ នៃបច្ចុប្បន្ន អតីត អនាគត មានតែកាលវិមុត្ត តែម្យ៉ាង, និព្វាន ជាពហិទ្ធៈ មិនជាអជ្ឈត្តៈទេ, និព្វានជាសុខុមៈ មិនជាឱឡារិកៈទេ, និព្វានជាបណីតៈ មិនជាហីនៈទេ, និព្វាន ជាទូរៈ មិនជាសន្តិកៈ ទេ,(មិនគ្រប់១១ប្រភេទ) ដូច្នោះ ទើបមិនមែនជាខន្ធ; ដែល ពោលថា និព្វានជាកាលវិមុត្ត ពហិទ្ធៈ សុខុមៈ បណីតៈ ទូរៈ ទាំងនេះ ក៏មិនហៅថា និព្វាន មាន៥ ប្រភេទឡើយ, និព្វានមាន ត្រឹមតែ១ប្រភេទ គឺ និព្វានដែលជាកាលវិមុត្ត ក៏ជាពហិទ្ធៈ សុខុមៈ បណីតៈ ទូរៈ ផងដែរ ។

៧- សំ. ធម៌ដែលជាអាហាររបស់ទុក្ខផ្សេង ៗ មាន ជាតិ ជរា ព្យាធិ មរណៈ ជាដើមនោះ គឺជាអ្វី ? បើអាហារទាំង នេះ មិនមានទេ តើជាតិ ជរា ជាដើមនោះ មានដែរទេ ? ចូរ អធិប្បាយនិងលើកបាលីមកផង

ចំ. ធម៌ដែលជាអាហាររបស់ទុក្ខផ្សេង ៗ មានជាតិ ជរា

ព្យាធិ មរណៈ ជាដើមនោះ បានដល់ ខន្ធ៥ គឺ រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ, បើអាហារទាំងនេះ មិនមានទេ ជាតិ ជរា ជាដើមនោះ ក៏កើតឡើងមិនបាន ។

អធិប្បាយថា ជាតិ ជរា ព្យាធិ មរណៈ ទាំងនេះ ជាអាការៈប្រព្រឹត្តទៅរបស់ខន្ធ៥ មិនមែនថា មានឡើងចំពោះ ៗ ទេ ពោលគឺ ការកើតឡើងរបស់ខន្ធ ៥ ហៅថា ជាតិ, ការចម្រើនធំធាត់និងចាស់ទ្រុឌទ្រោម ហៅថា ជរា, ការឈឺចុកចាប់របស់រូប ហៅថា ព្យាធិ, ការបែកធ្លាយរលត់ ទៅរបស់ខន្ធ ៥ ក្នុងភពមួយ ៗ ហៅថា មរណៈ ។

ដូចមាន វចនត្ថៈថា ៖

អនេកធុក្ខេហិ ខជ្ជន្តីតិ = ខន្ធា ធម៌ទាំងឡាយ ដែលត្រូវទុក្ខផ្សេង ៗទំពាស៊ី ដូច្នោះ ឈ្មោះថា ខន្ធ ។ សំដៅដល់ខន្ធ៥នេះ ជាទីកើតនៃជាតិ ជរា ព្យាធិ មរណៈ ជាដើម បើមិនមានខន្ធហើយ ទុក្ខផ្សេង ៗទាំងនេះ ក៏កើតឡើងមិនបាន ។

៨- សំ. ចូរពណ៌នាអំពីខន្ធ តាមវចនត្ថៈ ដែលសម្តែងថា សុញ្ញាគារំ ធារេន្តីតិ = ខន្ធា

ចំ. ពណ៌នាអំពីខន្ធ តាមវចនត្ថៈ ដែលសម្តែងថា សុញ្ញាគារំ ធារេន្តីតិ = ខន្ធា នោះ មានសេចក្តីដែលគប្បីពណ៌នាដូចតទៅ ពួកធម៌ដែលសម្តែងនូវអាការៈទទេចាកអត្តៈ ដូច្នោះ ធម៌ពួកនេះ ឈ្មោះថា ខន្ធ ធម្មតាសត្វទាំងឡាយក្នុងលោកនេះ ។ល ។ ចំណែកការដឹងដល់ភាពអនត្តារបស់រូបនាមទាំងនេះ នឹងដឹងច្បាស់កំរិតណានោះ ក៏ស្រេចតែកម្លាំងរបស់បញ្ញានោះ ៗ តាមលំដាប់ ។

៩- សំ. ព្រះពុទ្ធទ្រង់សម្តែងឧបាទានក្ខន្ធ ដោយញែកចេញពីខន្ធ ៥ ដោយពិស្តារទៀតនោះ ព្រោះហេតុអ្វី ? ចូរសម្តែងវចនត្ថៈរបស់ពាក្យថា ឧបាទានក្ខន្ធផង

ចំ. ក្នុងការដែលព្រះពុទ្ធទ្រង់សម្តែងឧបាទានក្ខន្ធ ដោយញែកចេញពីខន្ធ៥ ដោយពិស្តារទៀតនោះ ក៏ដើម្បីជាប្រយោជន៍

ក្នុងការចម្រើនវិបស្សនា ។ល។ ដោយហេតុនេះ ទើបទ្រង់សម្តែងឧបាទានក្ខន្ធដោយចំពោះទៀត ដូចមានវចនត្ថៈ សម្តែងថា ឧបាទានានំ គោចរា ខន្ធា = ឧបាទានក្ខន្ធា ខន្ធ ដែលជាអារម្មណ៍របស់ឧបាទាន ឈ្មោះថា ឧបាទានក្ខន្ធ ។

១០- សំ. ចូរសម្តែងផលដែលកើតឡើងអំពីអាយតនៈ ១២ ដោយចំពោះ ៗ និងដែលលោកពោលថា ចក្ខុបសាទជាដើម ឈ្មោះថា អាយតនៈ ព្រោះមានសភាពដូចជាថា មានសេចក្តីព្យាយាមដើម្បីញ៉ាំងផលរបស់ខ្លួនឱ្យកើតឡើងនោះ តើមានសេចក្តីព្យាយាមយ៉ាងណា ? ចូរអធិប្បាយ

ចំ. ផលដែលកើតឡើងអំពីអាយតនៈ ១២ ដោយចំពោះ ៗនោះ មានដូច្នេះ គឺ

១-ចក្ខុវិញ្ញាណ ការឃើញ ជាផលរបស់ចក្ខាយតនៈ និងរូបាយតនៈ

២-សោតវិញ្ញាណ ការបានឮ ជាផលរបស់សោតាយតនៈ

និងសទ្ទាយតនៈ

៣-ឃានវិញ្ញាណ ការដឹងក្លិន ជាផលរបស់ឃានា យតនៈ និងគន្ធាយតនៈ

៤-ជិវ្ហាវិញ្ញាណ ការដឹងរសេ ជាផលរបស់ ជិវ្ហាយតនៈ និងរសាយតនៈ

៥-កាយវិញ្ញាណ ការដឹងសម្ផស្ស ជាផលរបស់កាយា យតនៈនិងផោដ្ឋព្វាយតនៈ

៦-ចិត្ត ៧៦ (វៀរទ្វិបញ្ចវិញ្ញាណ១០ មនោធាតុ៣) មាន ការដឹងអារម្មណ៍ និងនឹកគិតក្នុងរឿង រ៉ាវទាំងពួង ជាផលរបស់មនាយតនៈ និងធម្មាយតនៈ ។

ដែលលោកពោលថា ចក្ខុបសាទជាដើមនេះ ឈ្មោះថា អាយតនៈ ព្រោះមានសភាពដូចជាថា មានសេចក្តីព្យាយាម ដើម្បីញ៉ាំងផលរបស់ខ្លួន ឱ្យកើតឡើងនោះ អធិប្បាយថា សេចក្តី

ព្យាយាមរបស់អាយតនៈទាំងនេះ ជាហេតុសំខាន់ ទាំងមានកម្លាំង ក្នុងការធ្វើផលរបស់ខ្លួន មានការឃើញ ការបានឮជាដើម កើតឡើងនោះឯង ហេតុនិងផលទាំងពីរយ៉ាងនេះ រមែងប្រព្រឹត្តទៅតាមសភាវៈអត្តាទាំងអស់ អាយតនៈផ្សេង ៗទាំងនេះ មិនបានមានសេចក្តីព្យាយាមកើតឡើង យ៉ាងណាមួយទេ តែសភាពនៃការប្រព្រឹត្តទៅរបស់អាយតនៈ ផ្សេង ៗទាំងនេះ ដូចជាថាមានមានការខ្វល់ខ្វាយព្យាយាម ដើម្បីឱ្យផលរបស់ខ្លួនកើតឡើង ។

១១- សំ. លោកពោលថា អាយតនៈខាងក្នុង៦ អាយតនៈ ខាងក្រៅ៦ទាំងនេះ ធ្វើឱ្យចិត្តចេតសិកទាំងពីរ ទូលំទូលាយ រីកចម្រើនឡើង តើអាយតនៈខាងក្នុង៦ អាយតនៈខាងក្រៅ៦នោះ គឺជាអ្វី ? និងធ្វើឱ្យចិត្ត ចេតសិកទាំងពីរ ទូលំទូលាយ រីកចម្រើនឡើង ដោយអាស្រ័យអាយតនៈទាំង នេះយ៉ាងណា ?

ចំ. អាយតនៈខាងក្នុង ៦ គឺ

១. ចក្ខាយតនៈ ២. សោតាយតនៈ

៣. ឃានាយតនៈ ៤. ជិវ្ហាយតនៈ

៥. កាយាយតនៈ ៦. មនាយតនៈ

អាយតនៈខាងក្រៅ ៦ គឺ

១. រូបាយតនៈ ២. សទ្ទាយតនៈ

៣. គន្ធាយតនៈ ៤. រសាយតនៈ

៥. ផោដ្ឋព្វាយតនៈ ៦. ធម្មាយតនៈ ។

ការដែលធ្វើឱ្យចិត្ត ចេតសិកទាំងពីរ ទូលំទូលាយរីកចម្រើនឡើងនោះ ក៏ព្រោះថា កាលអាយតនៈខាងក្នុង និងអាយតនៈខាងក្រៅទាំងនេះ មានការប៉ះខ្ទប់គ្នាហើយ វិថីចិត្តផ្សេង ៗ មានចក្ខុទ្វារវិថីចិត្តជាដើមរមែងកើតឡើង វិថីចិត្ត ដែលកើតឡើងនោះ ក៏មិនមែនកើតឡើងតែមួយវិថី រមែងកើតឡើងច្រើនវិថី ដ៏រាប់រាប់មិនបាន និងក្នុងវិថីចិត្តនិមួយ ៗ ក៏មាន

ចិត្តកើតច្រើនប្រភេទផងដែរ គឺ កុសល ឬអកុសលខ្លះ វិបាក ឬកិរិយាខ្លះ ការកើតឡើងរបស់វិថីចិត្តច្រើនវិថី និងច្រើនប្រភេទ ដូច្នេះឯង ទើបបានឈ្មោះថា ចិត្ត ចេតសិក ទូលំទូលាយ រីកចម្រើនឡើង ដែលជាយ៉ាងនេះ ក៏ដោយអាស្រ័យអាយតនៈខាងក្នុង និងខាងក្រៅនោះឯង ។

មួយទៀត អកុសលធម៌ មានលោភៈ ទោសៈ ជាដើម កុសលធម៌ មានសទ្ធា សតិ បញ្ញា ជាដើមទាំងនេះ ខណៈដែលកើតឡើងគ្រាដំបូងនោះ មានកម្លាំងខ្សោយ កាលវិថីចិត្តដែលមានកុសល ឬអកុសលទាំងនេះ កើតឡើងវិលវល់ច្រើនដុំហើយ កម្លាំងនៃកុសល ឬអកុសលទាំងនេះ ក៏ចម្រើនច្រើនឡើង ៗតាមលំដាប់ ដរាបដល់សម្រេចជាសុចរិតឬទុច្ចរិតបាន, នេះក៏បានឈ្មោះថា ចិត្ត ចេតសិក មានការទូលំទូលាយ រីកចម្រើនឡើង ដែលជាយ៉ាងនេះ ក៏ដោយអាស្រ័យអាយតនៈ ខាងក្នុង និងខាងក្រៅឱ្យកើតឡើង

ផងដែរ ។

១២- សំ. ចូរពណ៌នា សេចក្ដី ៥ យ៉ាង របស់អាយតនៈ

ចំ. អត្ថន័យ៥យ៉ាង របស់អាយតនៈនោះ មានដូច្នេះ គឺ

១. សញ្ជាតិទេសដ្ឋៈ មានន័យថា ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ។ល ។ មិនកើតទីដទៃ ត្រូវកើត តាមអាយតនៈពួកនេះទាំងនោះ ។

២. និវាសដ្ឋៈ សំដៅសេចក្ដីថា ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ។ល ។ ដូចដែលពោលមកហើយ ។ តែថាបើមានហេតុបច្ច័យបរិបូណ៌ ហើយ ក៏កើតឡើងប្រាកដ ដូចទីនវិថីចិត្តនោះ នៅក្នុងអាយតនៈទាំងនោះ ដូចដែលពោលមកហើយ ។

៣. អាករដ្ឋៈ សំដៅសេចក្ដីថា ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ។ល ។ មិនថា ទីនជាមនុស្ស ទេវតា

សត្វតិរច្ឆាន ក៏ត្រូវមានភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ដូចគ្នាទាំងអស់ ។

៤. សមោសរណដ្ឋះ សំដៅសេចក្តីថា រូបាយនៈ ជាដើម ។ល ។ ការទទួលអារម្មណ៍របស់វិថីចិត្តពួកនេះ ស្រដៀងនឹងការចូលទៅប្រជុំក្នុងអារម្មណ៍ មានរូបារម្មណ៍ ជាដើម ដែលខ្លួនទទួលបាន ។

៥. ការណដ្ឋះ សំដៅសេចក្តីថា អាយតនៈខាងក្នុង ៦ និងខាងក្រៅ៦ ។ល ។ បើមិនមានអាយតនៈទាំងនេះហើយ វិថីចិត្តក៏កើតឡើងមិនបាន ។

១៣. សំ. ចក្ខុបសាទ ជាដើម ឈ្មោះថា ធាតុ ព្រោះមិនមែនសត្វ មិនមែនជីវៈ តែជាសភាវៈពិត ៗនោះ ប្រព្រឹត្តទៅ បានយ៉ាងណា, ឱ្យអធិប្បាយ នឹងចូរអធិប្បាយពាក្យតាម វចនត្ថៈថា អត្តនោ សភាវំ ធរេតិ = ធាតុ

ចំ. ចក្ខុបសាទជាដើមឈ្មោះថា ធាតុ ព្រោះមិនមែនសត្វ មិន

មែនជីវៈ តែជាសភាវៈពិត ៗនោះ អធិប្បាយថា ធម្មតាសត្វទាំងឡាយ ដែលកើតក្នុងលោកនេះ ។ល ។ ដូច្នោះ សភាពមាននៅរបស់ធាតុ ទាំង ១៨ នេះ ទើបហៅថា និស្សត្តៈ គឺមិនមែនជាសត្វ មិនមែនជាបុគ្គល សេចក្តី ពេញចិត្តថាមនុស្សនោះ មនុស្សនេះស្លាប់ តែវិញ្ញាណមិនស្លាប់ ។ល ។ ដូច្នោះ សភាវៈរស់នៅរបស់ធាតុទាំង១៨ ទើបហៅថា និជ្ជីវៈ គឺ មិនមែនជីវៈ អត្តៈ ។

ពាក្យថា ធាតុ តាមវចនត្ថៈថា អត្តនោ សភាវំ ធារេតីតិ = ធាតុ ធម្មជាតិណា ទ្រទ្រង់ទុកនូវសភាពរបស់ខ្លួន ព្រោះដូច្នោះ ធម្មជាតិនោះ ឈ្មោះថា ធាតុ មានន័យថា ធម្មតាធាតុទាំង ១៨ នោះ ។ល ។ ដូច្នោះ សភាវៈ រស់នៅរបស់ធាតុទាំង១៨នេះ ទើបហៅថា ជាធម្មជាតិដែល ទ្រទ្រង់ទុកនូវសភាពរបស់ខ្លួន ៗ មិនមានការប្រែប្រួល ។

១៤- សំ. លោកពោលថា ទុក្ខ សមុទយ និរោធ មគ្គ

ទាំង៤ នេះ ឈ្មោះថា អរិយសច្ចៈ ឈ្មោះថា បុថុជ្ជនសច្ចៈ មិនបាន ព្រោះអ្វី ? ចូរអធិប្បាយ សភាពជាសេចក្តីពិត មិនប្រែប្រួលរបស់អរិយសច្ចៈទាំងនេះផង

ចំ. លោកពោលថា ទុក្ខ សមុទយ និរោធ មគ្គ ទាំង៤ នេះ ឈ្មោះថា អរិយសច្ចៈ ឈ្មោះថា បុថុជ្ជនសច្ចៈ មិនបាននោះ ព្រោះសេចក្តីពិត ៤យ៉ាង ដែលព្រះពុទ្ធទ្រង់សម្តែងទុកនោះ បណ្តាបុថុជ្ជនទាំងឡាយ សូម្បីបានឮ បានស្តាប់ក៏ដោយ តែសភាពដែលជាសេចក្តីពិត ព្រះអង្គទ្រង់សម្តែងថា ធម៌នេះ ជាទុក្ខ ធម៌នេះជាហេតុឱ្យកើតទុក្ខ ធម៌នេះជាគ្រឿងរលត់ទុក្ខ ធម៌នេះជាផ្លូវឱ្យដល់ទីរលត់ទុក្ខទាំងនេះ បុថុជ្ជនទាំងនោះ រមែងឃើញមិនជ្រាលជ្រៅតាមសេចក្តីពិត មិនខ្លាំងក្លាដូចព្រះអរិយៈ ដូច្នោះទើបមិនឈ្មោះថា បុថុជ្ជនសច្ចៈ ។

សភាពពិត មិនប្រែប្រួលរបស់អរិយសច្ចៈទាំងនេះ អធិប្បាយថា លោកិយរូប នាមខន្ធ ៥ ដែលឈ្មោះថា ទុក្ខ

នោះ មិនថានឹងមានដល់អ្នកណា នឹងកើតឡើងក្នុងភូមិណា ក៏ដោយ រមែងធ្វើឱ្យសត្វទាំងឡាយ បានទទួលសេចក្ដីលំបាក មិនមានការប្រែប្រួល ប្រព្រឹត្តទៅយ៉ាងដទៃ ដូច្នោះ ទើបជាសេចក្ដីពិត សមនឹងការដែលតាំងឈ្មោះទុក, លោភៈ ដែលបានឈ្មោះថា សមុទយសច្ចៈនោះ មិនថា នឹងជាលោភៈរបស់អ្នកណាកើតឡើងក្នុងភូមិណា ៗក៏ដោយ ក៏រមែងជាហេតុឱ្យមានសេចក្ដីទុក្ខផ្សេង ៗ កើតដល់សត្វទាំងឡាយ មិនមានការប្រែប្រួល ប្រព្រឹត្តទៅយ៉ាងដទៃ ដូច្នោះ ជាសេចក្ដីពិត សមនឹងការដែលតាំងឈ្មោះទុក, និព្វានដែលឈ្មោះថា និរោធសច្ចៈនោះ មិនថានឹងជានិព្វានរបស់សេក្ខបុគ្គល ឬអសេក្ខបុគ្គល រហូតដល់អនុបាទិសេសនិព្វានទាំងនោះ សូម្បីនឹងប្រាកដក្នុងភូមិណា ៗក៏ដោយ ក៏រមែងធ្វើឱ្យទុក្ខផ្សេង ៗរលត់ទៅពិត មិនមានការប្រែប្រួល ប្រព្រឹត្តទៅយ៉ាងដទៃ ដូច្នោះ ទើបជាសេចក្ដីពិតសមនឹងការដែលតាំងឈ្មោះទុក, អរិយមគ្គអង្គ ៨ ដែលឈ្មោះ

ថា មគ្គនោះ មិនថា នឹងជាមគ្គខាងក្រោម ឬខាងលើ នឹងប្រាកដកើតឡើងក្នុងភូមិណា ៗក៏ដោយ ក៏រមែងជាផ្លូវឱ្យដល់នូវទីរំលត់ទុក្ខ មិនមានការប្រែប្រួលប្រព្រឹត្តទៅយ៉ាងដទៃ ដូច្នោះ ទើបជាសេចក្តីពិត សមនឹងការដែលតាំងឈ្មោះទុក, ។

១៥- សំ. ចូរចែកអរិយសច្ចៈ៤ ដោយហេតុផល និងលោកិយ លោកុត្តរជាដើម

ចំ. ចែកអរិយសច្ចៈ៤ ដោយហេតុផល និងលោកិយលោកុត្តរនោះ មានដូច្នេះ

ទុក្ខសច្ចៈ ជាផល សមុទយសច្ចៈ ជាហេតុ

និរោធសច្ចៈ ជាផល មគ្គសច្ចៈ ជាហេតុ

សមុទយសច្ចៈ } ទាំងពីរនេះ ជាលោកិយធម៌
ទុក្ខសច្ចៈ } និងជាលោកិយសច្ចៈ

និរោធសច្ចៈ } ទាំងពីរនេះ ជាលោកុត្តរធម៌
មគ្គសច្ចៈ } និងជាលោកុត្តរសច្ចៈ

\+ ទុក្ខសច្ចៈ ជាសច្ចៈដែលមានការប្រព្រឹត្តិទៅក្នុងវដ្តសង្សារ ឈ្មោះថា បវត្តិសច្ចៈ

\+ សមុទយសច្ចៈ ជាសច្ចៈដែលជាហេតុឱ្យទុក្ខសច្ចៈកើតឡើង ប្រព្រឹត្តទៅក្នុងវដ្តសង្សារ ឈ្មោះថា បវត្តិហេតុសច្ចៈ

\+ និរោធសច្ចៈ ជាសច្ចៈដែលថយចេញពីវដ្តទុក្ខ ឈ្មោះថា និវត្តិសច្ចៈ

\+ មគ្គសច្ចៈ ជាសច្ចៈដែលជាហេតុឱ្យដល់សេចក្តីថយចេញពីវដ្តទុក្ខ ឈ្មោះថា និវត្តិហេតុសច្ចៈ ។

១៦- សំ. ក្នុងវត្ថុធម៌ ៧២ នោះ វត្ថុធម៌ ដែលសម្តែងទុក ក្នុងអកុសលសង្គហៈ មិស្សកសង្គហៈ ពោធិបក្ខិយសង្គហៈ សព្វសង្គហៈ តែមួយពួក ៗ មានចំនួនប៉ុន្មាន ? អ្វីខ្លះ

ចំ. ក្នុងវត្ថុធម៌ ៧២ នោះ

\+ វត្ថុធម៌ ដែលសម្តែងទុកក្នុងអកុសលសង្គហៈ មាន ១៤ គឺ អកុសលចេតសិក ១៤

សំនួរ-ចម្លើយ ក្នុងសព្វសង្គហៈ

\+ វត្ថុធម៌ ដែលសម្តែងទុកក្នុងមិស្សកសង្គហៈ មាន ៣៦ គឺ ចិត្ត ១ ចេតសិក ២៦ រូប ៩ ។

\+ វត្ថុធម៌ ដែលសម្តែងទុកក្នុងពោធិបក្ខិយសង្គហៈ មាន ១៤ គឺ ចិត្ត១ ចេតសិក១៣

\+ វត្ថុធម៌ ដែលសម្តែងទុកក្នុងសព្វសង្គហៈ មាន ៧២ គឺ ចិត្ត១ ចេតសិក៥២ និប្ផន្នរូប ១៨ និព្វាន១

**ចប់ សំនួរ-ចម្លើយក្នុងសព្វសង្គហៈ**

**ចប់ បរិច្ឆេទទី ៧ សមុច្ចយសង្គហវិភាគ**